# វត្តប្រតិបត្តិព្រះពុទ្ធសាសនា

# ចំពូកទី ១

# វិធីធ្វើឲ្យចានបរិសុទ្ធ

## I

## វិធីធ្វើឲ្យចិត្តចានបរិសុទ្ធ

1. *សត្វលោកមានតណ្ហាលោកិយដែលបណ្តាលឲ្យកើតមានការភាន់ច្រឡំ និងទុក្ខវេទនា។ មានវិធី៥ ដើម្បីនឹងរំដោះខ្លួនឲ្យផុតពីចំណងនៃតណ្ហាលោកិយ។*

*ទី១ គឺត្រូវមានគតិត្រឹមត្រូវចំពោះវត្ថុទាំងអស់ គឺគតិប្រកបដោយការសង្កេតយ៉ាងពិនិត្យពិច័យជាគ្រឹះហើយត្រូវចេះយល់នូវហេតុនិងផលគឺយល់ន័យនៃហេតុនិងផលនេះឲ្យបានត្រឹមត្រូវ។ ទុក្ខវេទនាស្ថិតនៅក្នុងចំណង់និងការជំពាក់នៃចិត្ត ចំណង់និងការជំពាក់នៃចិត្តទាក់ទងនឹងការយល់ខុសអំពីការថាមានអាត្មាអញ ហើយមិនគិតដល់អត្ថន័យនៃច្បាប់ស្តីអំពីហេតុ និងផល ហើយរឿងទាំងអស់នេះកើតមកអំពីការពិចារណាខុសចំពោះវត្ថុជាតុ។ ហេតុនេះ សេចក្តីសុខស្ងប់*

នឹងអាចកើតឡើងបាន លុះណាតែចិត្តលះបង់ឲ្យដាច់ស្រឡះពីតណ្ហាលោកិយទាំងនេះ។

ទី២ គឺមនុស្សលោកអាចលះបង់ចោលការយល់ខុសទាំងនេះ ហើយចាកផុតពីតណ្ហាទាំងឡាយ ដែលចេញមកពីការយល់ខុសទាំងនេះបាន លុះណាតែចេះអត់ធ្មត់គ្រប់គ្រងចិត្តឲ្យបានហ្មត់ចត់។ ដោយសារការចេះគ្រប់គ្រងចិត្តឲ្យបានស័ក្តិសិទ្ធិនេះ មនុស្សអាចចៀសផុតពីចំណង់ទាំងឡាយ ដែលកើតឡើងពីវិញ្ញាណអារម្មណ៍នៃភ្នែក ត្រចៀក ច្រមុះ អណ្តាត ស្បែកនិងសកម្មភាពនៃចិត្ត ហើយដោយសារអំពើនេះ មនុស្សលោកអាចកាត់ផ្តាច់បាននូវឫសកែវនៃគ្រប់តណ្ហាលោកិយ។

ទី៣ គឺមនុស្សលោកត្រូវចេះគិតគូរប្រើប្រាស់វត្ថុទាំងឡាយឲ្យបានត្រឹមត្រូវតាមគន្លង។ ពោលគឺចំពោះចំណីអាហារ និងសំលៀកបំពាក់ មនុស្សលោកមិនត្រូវទុកដូចជាប្រភពនៃសុខុមាលភាព និងសេចក្តីសប្បាយរីករាយទេ គឺទុកដូចត្រឹមតែជាគ្រឿងឧបត្ថម្ភផ្គត់ផ្គង់សេចក្តីត្រូវការនៃរូបកាយ តែប៉ុណ្ណោះបានហើយ។ សំលៀកបំពាក់ ជាគ្រឿងចាំបាច់សម្រាប់ការពារអង្គប្រាណនឹងកំដៅថ្ងៃ និងធាតុអាកាសត្រជាក់ហួសប្រមាណ

និងសំរាប់បិទបាំងកេរខ្មាស។ ចំណីអាហារជាវត្ថុចាំបាច់សម្រាប់ទ្រទ្រង់រូបកាយក្នុងពេលដែលគេកំពុងធ្វើវត្តប្រតិបត្តិឆ្ពោះទៅរកពន្លឺត្រាស់ដឹង និងពុទ្ធភាវៈ។ តណ្ហាលោកិយទាំងឡាយមិនអាចកើតមានឡើងបានទេ បើគេចេះរបៀបបរិះគិតពិចារណាដ៏ត្រឹមត្រូវនេះ។

ទី៤ គឺមនុស្សលោកត្រូវរៀនឲ្យចេះអត់ធន់ៈ ត្រូវរៀនឲ្យចេះអត់ទ្រាំនឹងភាពមិនសុខស្រួល ដែលបណ្ដាលមកអំពីកំដៅថ្ងៃ អំពីធាតុអាកាសត្រជាក់ និងអំពីការស្រេកឃ្លាន។ ត្រូវរៀនឲ្យចេះមានការអំណត់ កាលណាមានគេប្រព្រឹត្តអំពើអាក្រក់មកលើខ្លួន ឬគេប្រមាថមើលងាយខ្លួន។ ដោយសារការហាត់រៀនឲ្យចេះអត់ធន់នេះមនុស្សលោកអាចពន្លត់ភ្លើងតណ្ហាលោកិយ ដែលឆេះរោលរាលអង្គប្រាណនោះបាន។

ទី៥ គឺមនុស្សលោកត្រូវរៀនចៀសវាងនូវគ្រោះថ្នាក់ទាំងឡាយ។ ដូចជាបណ្ឌិតគេចចៀសពីសេះព្រៃ និងឆ្កែកាចមនុស្សលោក ក៏មិនត្រូវចងមិត្តនឹងមនុស្សកំណាច ឬទៅកន្លែងណាដែលបណ្ឌិតចៀសវាងនោះដែរ។ បើគេហាត់រៀនឲ្យចេះប្រយ័ត្នប្រយែងយ៉ាងនេះបាន ភ្លើងតណ្ហាលោកិយ

ដែលឆេះពេលពាលជីវពល មនុស្សលោកនឹងវិនាសសូន្យ។

2. ចំណង់លោកិយចែកចេញជា ៥ ចំពូកគឺៈ ចំណង់ដែលកើតឡើងពីភ្នែកមើលឃើញ១ ចំណង់ដែលកើតឡើងពីត្រចៀកស្តាប់ឮ១ ចំណង់ដែលកើតឡើងពីគន្ធដែលច្រមុះធុំក្លិន១ ចំណង់ដែលកើតឡើងពីរសជាតិដែលអណ្តាតភ្លក់ក្រេប១ ចំណង់ដែលកើតឡើងពីការស្ទាបប៉ះនៃកាយវិញ្ញាណ១។ គឺមកអំពីចំណង់ទាំង៥ចំពូកនេះហើយ ដែលបណ្តាលឲ្យមានការចាប់ចិត្តស្រឡាញ់ចំពោះសុខុមាលភាពនៃរូបកាយ។

បុគ្គលជាច្រើន ដោយលុះក្នុងចំណាចនៃសេចក្តីស្រឡាញ់សុខុមាលភាពនៃរូបកាយនេះ មិនបានចាប់ភ្ញឹកគិតដល់ហេតុផលអាក្រក់ ដែលកើតឡើងអំពីសេចក្តីនេះទេ ហើយបុគ្គលទាំងនោះត្រូវបានជាប់អន្ទាក់បិសាចចង្រៃ ដូចជាសត្វប្រើសជាប់អន្ទាក់ព្រានដូច្នោះដែរ។ ជាការពិតណាស់ ចំណង់ទាំងប្រាំចំពូក ដែលកើតឡើងពីវិញ្ញាណបសាទទាំងប្រាំនេះ ជាអន្ទាក់ប្រកបដោយគ្រោះថ្នាក់ធំជាទីបំផុត។ មនុស្សលោកដោយបណ្តោយខ្លួនឲ្យជាប់អន្ទាក់ទាំងនេះ ក៏ត្រូវបានជាប់ជំពាក់នឹង

តណ្ហាលោកកិយ ហើយក៏ត្រូវរងទុក្ខវេទនា។ មនុស្សលោកត្រូវបេះវិធីរំដោះខ្លួនឲ្យរួចពីអន្ទាក់នៃចំណង់ទាំងប្រាំចំពូកនេះ។

3. ពុំមែនមានតែផ្លូវមួយទេ ដើម្បីរំដោះខ្លួនឲ្យឱ្យរួចពីអន្ទាក់តណ្ហាលោកិយនេះ។ ឧបមាថាបើគេចាប់ពស់១ ក្រពើ១ សត្វស្លាប១ ឆ្កែ១ កញ្ជ្រោង១ និងស្វា១ សត្វ៦ប្រភេទដែលមានចរិតខុសគ្នាស្រឡះ ហើយចងសត្វទាំងនោះនឹងខ្សែជាប់មាំមួយជាមួយគ្នា សត្វទាំង៦នោះនឹងខំរំដោះខ្លួនរត់ត្រឡប់ទៅទីជម្រកតែសព្វខ្លួនវិញ តាមរបៀបផ្ទាល់ខ្លួនវានីមួយៗ។ ពស់នឹងខំលូនទៅរកទ្រុបស្មៅ ក្រពើនឹងខំវារសំដៅទៅរកទឹក បក្សីនឹងខំហើរសំដៅទៅរកផ្ទៃអាកាស ឆ្កែនឹងខំរើរត់សំដៅទៅរកភូមិ កញ្ជ្រោងនឹងខំរត់សំដៅទៅរកកៀនស្ងាត់ ស្វានឹងខំប្រះរត់សំដៅទៅរកដើមឈើក្នុងព្រៃ។ ការល្បងរត់ត្រឡប់ទៅរកទីជម្រកផ្សេងៗគ្នាតែសព្វខ្លួននេះ បណ្តាលឡើងជាការប្រយុទ្ធមួយ តែដោយសត្វទាំងនេះត្រូវបានចងភ្ជាប់គ្នានឹងពួរតែមួយ សត្វដែលខ្លាំងជាងគេនឹងអូសទាញសត្វឯទៀតៗ។

មនុស្សលោក ក៏ដូចជាសត្វទាំងប្រាំមួយក្នុងរឿងឧបមានេះដែរ។ មនុស្សលោកមានបំណងទៅលើចំណង់នៃញាណប្រសាទទាំងប្រាំមួយ ពោលគឺភ្នែក ត្រចៀក ច្រមុះ អណ្តាតស្បែក និងខួរក្បាល ហើយត្រូវបានលុះទៅក្នុងអំណាចនៃចំណង់ដែលខ្លាំងលើសលុបជាងគេ។

បើគេចងសត្វទាំងប្រាំមួយនោះ ភ្ជាប់នឹងបង្គោលមួយវានឹងខំត្រដរដោះខ្លួនរហូតដល់អស់កម្លាំងជាចុងក្រោយប៉ុន្តែទីបំផុតវាត្រូវដេកដួលនៅក្បែរបង្គោលនោះ។ យ៉ាងណាមិញបើមនុស្សលោកហាត់បំពត់ចិត្តរបស់ខ្លួនបានហើយ ញាណប្រសាទប្រាំឯទៀតនោះ នឹងលែងញាំញីបានតទៅទៀតហើយ។ បើបំពត់ចិត្តបានហើយ មនុស្សលោកនឹងបានសេចក្តីស្ងប់សុខ មិនត្រឹមតែក្នុងពេលបច្ចុប្បន្ននេះទេ ទៅក្នុងអនាគតក៏បានសុខដែរ។

4. មនុស្សលោកស្រឡាញ់ចំណង់អត្តទត្តដែលបណ្តាលមកពីការចង់បានកេរ្តិ៍ឈ្មោះ និងការចង់ឲ្យគេអួតសរសើរ។ ប៉ុន្តែការមានកេរ្តិ៍ឈ្មោះ និងការបានគេអួតសរសើរនេះ វាដូចជា

ធូបដែលឆេះ ហើយរលត់អស់ទៅក្នុងរយៈពេលដ៏ខ្លីដូច្នេះដែរ។ បើមនុស្សលោកខំស្វែងរកកិត្តិយស និងការបានគេអបអរសាទរ ហើយលះបង់ចោលផ្លូវនៃសេចក្ដីពិត មនុស្សលោកទាំងនោះនឹងធ្លាក់ក្នុងមហាគ្រោះថ្នាក់ ហើយកំពុងតែបណ្ដាលនូវហេតុ ដែលនឹងត្រូវបានស្ដាយក្រោយជាមិនខាន។

បុគ្គលដែលស្វែងរកកិត្តិនាម សម្បត្តិទ្រព្យ និងសេចក្ដីស្នេហា ប្រៀបបាននឹងកូនក្មេងលិទ្ធទឹកឃ្មុំ ដែលជាប់នៅលើមុខកាំបិត។ ក្នុងពេលដែលកូនក្មេងនោះក្រេបរស់ជាតិផ្អែមឆ្ងាញ់នៃទឹកឃ្មុំ វានឹងមុតអណ្ដាតនឹងកាំបិតនោះ។ម្យ៉ាងទៀត គេអាចប្រៀបបានទៅនឹងបុរសកាន់ចន្លុះដើរច្រាសខ្យល់ អណ្ដាតភ្លើងចន្លុះ នឹងឆេះដៃនិងមុខបុរសនោះជាមិនខាន។

មិនត្រូវបណ្ដោយខ្លួន ឲ្យលុះទៅតាមចំណង់នៃចិត្តនោះទេ ព្រោះចិត្តពោរពេញទៅដោយក្ដីលោភលន់ ក្ដីក្រោធខឹង និងក្ដីភាន់ច្រឡំ។ មិនត្រូវបណ្ដោយឲ្យចិត្តប្រព្រឹត្តទៅដោយសេរីទេ ត្រូវតែត្រួតត្រាវាយ៉ាងតឹងរឹង។

5. គ្មានអ្វីពិបាកជាងការត្រួតត្រាចិត្តឲ្យបានល្អឥតខ្ចោះនោះ

ទេ។ បុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែចៀសវាងភ្លើងតណ្ហា ដូចជាអ្នកពាក់ស្បែកជើងធ្វើអំពីចំបើងហាលស្ងួតចៀសវាងផ្កាភ្លើងយ៉ាងនោះដែរ។

ប៉ុន្តែ ចំពោះបុគ្គលដែលខ្វេះគ្រាប់ភ្នែករបស់ខ្លួនចេញដើម្បីកុំឲ្យមានចំណង់នឹងសោភណភាពនៃរូបទម្រង់នោះ ជាអំពើឆ្កួតស្រឡះ។ ពីព្រោះចិត្តជាចៅហ្វាយ បើកាលណាគ្រប់គ្រងចិត្តបានហើយ ចំណង់ទាំងឡាយដែលនៅក្រោមអំណាចនៃចិត្តនោះ នឹងវិនាសអស់ហោង។

ដើរតាមមាគ៌ាទៅកាន់ពន្លឺត្រាស់ដឹង ជាការពិបាក។ ប៉ុន្តែវារឹតតែពិបាកណាស់ទៅទៀត បើកាលណាគ្មានចិត្តតម្រង់ឆ្ពោះទៅរកការស្វែងរកមាគ៌ានោះ។ បើគ្មានពន្លឺត្រាស់ដឹងទេ បុគ្គលនឹងត្រូវរងទុក្ខវេទនាមិនចេះចប់ ក្នុងការវិលរស់វិលស្លាប់នេះ។

បុគ្គលណាស្វែងរកមាគ៌ានៃពន្លឺត្រាស់ដឹង ប្រៀបបានទៅនឹងគោដែលអូសរទេះផ្ទុករបស់យ៉ាងធ្ងន់ ឆ្លងកាត់វាលភក់។ បើគោនោះខំយ៉ាងពេញសមត្ថភាព ដោយគ្មានគិតរវល់នឹងអ្វីៗ ក្រៅឯទៀតនោះ វានឹងឆ្លងវាលភក់រួច ហើយទីបំផុត នឹង

អាចសម្រាកកម្លាំងបាន។ យ៉ាងណាមិញចិត្តក៏ដូចនោះដែរ តែកាលណាត្រូវគ្រប់គ្រងបានហើយ ដាក់ឲ្យនៅក្នុងគន្លងផ្លូវត្រឹមត្រូវល្អហើយ ភក់ជ្រាំដែលកើតឡើងអំពីតណ្ហាដែលជាឧបសគ្គចំពោះចិត្តនោះនឹងលែងមាន ហើយទុក្ខវេទនាទាំងឡាយនឹងវិនាសសូន្យ។

6. បុគ្គលណាដែលស្វែងរកមាគ៌ាពន្លឺត្រាស់ដឹង មុនដំបូងបង្អស់ ត្រូវលះបង់ចោលនូវអភិមានះ និងការលើកតម្កើងខ្លួន ហើយមានចិត្តជ្រះថ្លាពបសាចង់ទទួលនូវពន្លឺពុទ្ធឱវាទ។ កំណប់សម្បត្តិទ្រព្យក្នុងលោកនេះ មាសប្រាក់ កិត្តិយស មិនអាចយកទៅប្រដូចនឹងព្រហ្មចរិយធម៌ និងគុណធម៌បានទេ។

ដើម្បីមានសុខភាពល្អ ដើម្បីផ្តល់នូវសុភមង្គលពិតប្រាកដដល់គ្រួសារ និងដើម្បីផ្តល់នូវសន្តិភាពដល់អ្នកផងទាំងពួង មុនដំបូងបង្អស់ ត្រូវតែបំពត់ត្រួតត្រាចិត្តរបស់ខ្លួនឯងសិន។ បើបុគ្គលណាអាចបំពត់ចិត្តខ្លួនឯងបានហើយ បុគ្គលនោះអាចរកឃើញនូវមាគ៌ាពន្លឺត្រាស់ដឹង ពេលនោះហើយព្រហ្មចរិយធម៌និងគុណធម៌ នឹងមករកបុគ្គលនោះដោយឯកឯង។

ដូចជាកំណាប់ធនធានផុសចេញពីក្នុងដី គុណធម៌សាចចេញឡើងពីការប្រព្រឹត្តល្អ ហើយព្រហ្មចរិយធម៌ផុសចេញឡើងពីចិត្តបរិសុទ្ធស្ងប់។ ដើម្បីដើរដោយសុខសាន្តនៅក្នុងភាពសាំញ៉ាំនៃជីវិតលោកិនេះ គេត្រូវការពន្លឺពោលគឺសតិប្រាជ្ញា និងអ្នកនាំផ្លូវ ពោលគឺគុណធម៌។

សេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលពន្យល់មនុស្សលោកអំពីរបៀបបំបាត់ចោលការលោភលន់ ការខឹងក្រោធ និងការភាន់គតិ ជាសិក្ខាបទមួយដ៏ប្រសើរ ហើយបុគ្គលណាប្រតិបត្តិតាមសិក្ខាបទនេះ នឹងបានសម្រេចនូវសុភមង្គលនៃជីវិតដ៏ប្រសើរបំផុត។

7. មនុស្សលោកមានបំណងដើរឆ្ពោះទៅរកទិសដែលគំនិតរបស់ខ្លួនតម្រង់ឆ្ពោះទៅ។ បើគេរក្សាគំនិតលោភលន់ គេនឹងទៅជាមនុស្សលោភលន់កាន់តែខ្លាំងឡើងៗ។ បើគេរក្សាគំនិតក្រោធខឹង គេនឹងទៅជាមនុស្សមានកម្រោធកាន់តែច្រើនឡើងៗ។ បើគេចិញ្ចឹមគំនិតសងសឹក ជើងរបស់គេនឹងនាំគេឆ្ពោះទៅរកទិសនោះឯង។

នៅរដូវប្រមូលកាត់ អ្នកស្រែចំការចងគោក្របីរបស់ខ្លួនទុកក្នុងក្រោល ដោយខ្លាចវាបំបាក់របងរត់ទៅក្នុងវាលស្រែ ស៊ីដំណាំគេឯង នាំឲ្យគេសម្លាប់វា ឬនាំឲ្យមានការប្តឹងផ្តល់គ្នា។ យ៉ាងណាមិញ យើងត្រូវតែរក្សាគ្រប់គ្រងចិត្តរបស់យើងឲ្យហ្មត់ចត់ចំពោះអំពើទុច្ចរិត និងអំពើកាចឃោរឃៅ។ យើងត្រូវតែលះបង់ចោលគំនិត ដែលបណ្តាលឲ្យមានការលោភលន់ ការខឹងក្រោធ និងការយល់ច្រឡំ ហើយខិតខំបណ្តុះគំនិតដែលបណ្តាលឲ្យមានមេត្តាធម៌ និងចិត្តល្អ។

កាលណារដូវផ្ការីកមកដល់ហើយ វាលស្មៅនានាមានស្មៅខៀវខ្ចីដុះពាសពេញ អ្នកស្រែចំការទាំងឡាយដឹកក្របីគោរបស់ខ្លួនទៅកាន់វាលស្មៅទាំងនោះ។ ក្នុងពេលនោះទៀតក៏អ្នកស្រែចំការទាំងនោះនៅតែចាំឃ្លាំមើលហ្វូងសត្វពាហនៈរបស់ខ្លួនដែរ។ ចិត្តរបស់មនុស្សលោកក៏ដូច្នោះដែរ ទោះបីនៅក្នុងកាលៈទេសៈ ដ៏គាប់ប្រសើរយ៉ាងណាក៏ដោយ ក៏ត្រូវតែត្រួតពិនិត្យចិត្តនោះដែរ។

8. មានមួយពេលនោះ ព្រះពុទ្ធសក្យមុនី ទ្រង់និមន្តទៅគង់

ក្នុងក្រុងកោសម្ពី។ នៅក្នុងក្រុងនោះ មានបុរសម្នាក់ចងគំនុំនិងព្រះអង្គ ហើយញុះញង់ពួកមនុស្សខិលខូចឲ្យដើរនិយាយអាក្រក់ពីព្រះអង្គគ្រប់បែបយ៉ាង។ ក្នុងស្ថានភាពដ៏ជូរចត់បែបនេះ សាវ័កទាំងឡាយរបស់ព្រះអង្គពិបាកនិមន្តទៅបិណ្ឌបាតចង្ហាន់ឲ្យបានគ្រប់គ្រាន់ណាស់ នៅក្នុងក្រុងនោះ ទៅកន្លែងណាក៏មានគេជេរត្មះតិះដៀលដែរ។

ព្រះអានន្ទទូលព្រះពុទ្ធថា: «គួរតែកុំនៅក្នុងក្រុងនេះតទៅទៀត។ មានក្រុងល្អៗជាងនេះជាច្រើនទៀត ដែលយើងអាចទៅសំណាក់នៅបាន។ យើងចាកចេញអំពីទីក្រុងនេះទៅល្អជាង»។

ព្រះពុទ្ធជាម្ចាស់ត្រាស់ឆ្លើយថា: «បើក្រុងឯទៀតវារបៀបនេះដែរ តើយើងនឹងធ្វើដូចម្ដេច? យើងនឹងទៅនៅក្នុងក្រុងមួយទៀតឬយ៉ាងណាហ្ន៎!»។

ព្រះពុទ្ធជាម្ចាស់ត្រាស់បន្តទៅទៀតថា: «អានន្ទអើយ រឿងនេះមិនចប់ទៅយ៉ាងនេះទេ។ រស់នៅទីកន្លែងនេះហើយខំអត់ទ្រាំនឹងការជេរប្រមាថ រហូតដល់វាបាត់អស់ទៅវិញ ជាការប្រសើរជាង រួចហើយសឹមយើងទៅកន្លែងផ្សេង

ទៀត»!

ព្រះអង្គមានពុទ្ធដីកាជាបន្ថែមទៀតថា: «នៅក្នុងលោកនេះ វាមានចំណេញនិងខាត វាមានកិត្តិយស និងការប្រមាថមើលងាយ វាមានការអួតសរសើរ និងការជេរត្មះតិះដៀល។ បណ្ឌិតមិនមានការទាក់ទងនឹងរឿងសំបកខាងក្រៅទាំងនេះទេ។ រឿងជាខាងក្រៅទាំងនេះ នឹងបាត់ទៅវិញយ៉ាងឆាប់រហ័ស ដូចជាកាលដែលវាកើតឡើងមកនោះដែរ»។

II

## របៀបប្រព្រឹត្តល្អ

1. បុគ្គលទាំងឡាយដែលស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែចងចាំជានិច្ចថា ការរក្សាកាយ វាចា និងចិត្តឲ្យបាននៅបរិសុទ្ធជានិច្ចជាការចាំបាច់។ ដើម្បីរក្សាកាយឲ្យបរិសុទ្ធត្រូវចៀសវាងការសម្លាប់សត្វមានជីវិត ត្រូវចៀសវាងការលួចប្លន់ ត្រូវចៀសវាងការផិតក្បត់។ ដើម្បីរក្សាវាចាឲ្យបរិសុទ្ធ ត្រូវចៀសវាងការ

និយាយកូតកុហក ត្រូវចៀសវាងការនិយាយបង្កាច់បង្ខូច ត្រូវចៀសវាងការជេរប្រមាថ និងត្រូវចៀសវាងការនិយាយច្រើនឥតប្រយោជន៍។ ដើម្បីរក្សាចិត្តឲ្យបរិសុទ្ធត្រូវចៀសវាងការលោភលន់ ការក្រោធខឹង និងការយល់ច្រឡំ។

តែកាលណាហើយ ចិត្តឡើងជាមិនបរិសុទ្ធ អំពើដែលហូរចេញពីចិត្តមិនបរិសុទ្ធនោះ នឹងទៅជាមិនបរិសុទ្ធដែរ។ តែកាលណាហើយ អំពើមិនបរិសុទ្ធ ទុក្ខវេទនានឹងកើតមានឡើង។ ដូច្នេះ ការរក្សាកាយនិងចិត្តឲ្យបាននៅបរិសុទ្ធជាការសំខាន់បំផុត។

2. សម័យមួយនោះ មានស្រីមេម៉ាយអ្នកមានស្តុកស្តម្ភម្នាក់មានឈ្មោះល្បីល្បាញណាស់ ដោយសារមានការចេះគួរសមសុភាពរម្យទម និងឫកពារទន់ភ្លន់របស់គាត់។ គាត់មានក្មេងបម្រើស្រីម្នាក់ ឆ្លាតរៀសរវៃណាស់។

ថ្ងៃមួយក្មេងបម្រើស្រីនោះគិតថា: «ចៅហ្វាយស្រីអញមានឈ្មោះល្បីល្បាញណាស់។ អញចង់ដឹងណាស់ តើគាត់ល្អពីកំណើត ឬគាត់ល្អដោយសារទេសកាល។ អញនឹងសាកល្បង

គាត់មើល អញនឹងបានដឹងច្បាស់ជាពុំខាន»។

ព្រឹកស្អែកឡើង ក្មេងបម្រើស្រីនោះ ដល់ថ្ងៃជិតត្រង់ ទើបទៅគាល់បម្រើចៅហ្វាយស្រីខ្លួន។ ចៅហ្វាយស្រីខឹងណាស់ ហើយជេរប្រទេចខ្ញុំបម្រើស្រីនោះ គ្មានឈប់ឈរទេ។ ស្រីបម្រើឆ្លើយឡើងថា: «ខ្ញុំខ្ជិលច្រអូស តែក្នុងមួយថ្ងៃពីរថ្ងៃប៉ុណ្ណោះ ចៅហ្វាយមិនត្រូវអស់ការអត់ធ្មត់ទេ»។ ចៅហ្វាយស្រីរឹតតែខឹងប្រទ្បោតឡើងថែមទៀត។

ថ្ងៃបន្ទាប់មកទៀត ស្រីបម្រើនោះក្រោកពីដេកយឺតយូរទៀត។ ចៅហ្វាយស្រីខឹងណាស់ ហើយយកដំបងវាយខ្ញុំបម្រើស្រីនោះ។ រឿងហេតុនេះឮដល់អ្នកជិតខាង ហើយស្រីមេម៉ាយអ្នកមានស្តុកស្តម្ភនោះក៏អស់ឈ្មោះល្បីល្បាញទៅ។

3. បុគ្គលជាច្រើន ប្រៀបបាននឹងស្រីមហាសេដ្ឋីនេះដែរ។ កាលណាទេសកាលល្អហុចឲ្យ បុគ្គលទាំងនោះឡើងជា ស្លូតបូតមានចិត្តចេះគួរសមរម្យទមរាក់ទាក់។ ប៉ុន្តែកាលណាទេសកាលមានការផ្លាស់ប្តូរទៅ ហើយមិនស្របទៅតាមចិត្តរបស់គេ តើបុគ្គលទាំងនោះនៅតែល្អដដែលឬ? នេះជាបញ្ហាមួយ

ដែលគួររិះគិតឲ្យបានយល់។

បុគ្គលណាចេះរក្សាចិត្តឲ្យបរិសុទ្ធស្ងប់ ហើយនៅតែបន្តការប្រព្រឹត្តល្អជានិច្ច ទោះបីមានពាក្យអាក្រក់ចូលក្នុងត្រចៀករបស់គេក៏ដោយ ទោះបីអ្នកឯទៀតបញ្ចេញនូវភាពឃោរឃៅមកលើគេក៏ដោយ ទោះបីគេត្រូវខ្វះចំណីអាហារមិនបានបរិបូណ៌ ខ្វះសម្លៀកបំពាក់ និងផ្ទះសម្បែងមិនបានសមរម្យក៏ដោយ បុគ្គលនោះទើបបានហៅថាបុគ្គលល្អពិតមែន។

ដូច្នេះហើយ បុគ្គលទាំងឡាយដែលធ្វើអំពើល្អ ហើយរក្សាចិត្តស្ងួតបូតតែក្នុងពេលទេសកាល បានសមប្រកបចំពោះខ្លួននោះ បុគ្គលទាំងនោះមិនពិតជាបុគ្គលល្អទេ។ មានតែបុគ្គលដែលបានទទួលការប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយបានហាត់បំពត់ចិត្តនិងកាយទៅតាមការប្រៀនប្រដៅនោះទេ ដែលអាចត្រូវបានហៅថា បុគ្គលល្អ សុភាព រម្យទមស្ងួតបូត ពិតប្រាកដ។

4. មានពាក្យជាគូផ្ទុយនឹងគ្នាប្រាំគូគឺៈទី១ ពាក្យដែលគេអាចប្រើប្រាស់បានក្នុងទេសកាលខ្លះ និងពាក្យដែលគេអាចប្រើប្រាស់បានតែក្នុងទេសកាលផ្សេងទៀត។ ទី២ ពាក្យដែលស្រប

នឹងអំពើ និងពាក្យដែលមិនស្របនឹងអំពើ។ ទី៣ ពាក្យដែលមានសំឡេងចេញមកគួរឲ្យរីករាយ និងពាក្យដែលមានសំឡេងចេញមកយ៉ាងគ្រោតគ្រាត។ ទី៤ ពាក្យដែលផ្តល់សេចក្តីល្អនឹងពាក្យដែលផ្តល់សេចក្តីអាក្រក់។ ទី៥ ពាក្យដែលបង្កើតមិត្តនឹងពាក្យដែលបង្កើតសត្រូវ។

ពាក្យណាក៏ដោយដែលយើងប្រើប្រាស់ យើងតោងតែជ្រើសរើសឲ្យបានហ្មត់ចត់ ពីព្រោះអ្នកស្តាប់ឮពាក្យសំដីនោះនឹងលុះទៅក្នុងអំណាចនៃពាក្យសំដីនោះ ក្នុងន័យអាក្រក់ ក៏ដូចជាក្នុងន័យល្អ។ បើចិត្តរបស់យើង វាពោរពេញទៅដោយមិត្តភាពនិងករុណាធម៌ យើងនឹងមិនត្រូវបានរំខានដោយសារតែពាក្យសំដីដែលយើងបានឮនោះទេ។ យើងមិនត្រូវបណ្តោយឱ្យពាក្យសំដីមិនសមហេតុផល វាហូរចេញតាមបបូរមាត់យើងទេ ពីព្រោះវាបណ្តាលឲ្យកើតមានមនោសញ្ចេតនាក្រោធខឹងនិងសម្អប់។ពាក្យដែលយើងស្តីនិយាយ តោងតែជាពាក្យជាមិត្តភាព និងប្រកបដោយគតិបណ្ឌិតជានិច្ច។

ឧបមាថា មានបុរសម្នាក់ ប៉ងបោសច្រាសដីឲ្យបានស្អាតល្អ ដោយយកដំបងមួយ និងបង្គីមួយមកប្រើប្រាស់ ហើយគាត់ខំ

ហោសសម្រាមដោយសេចក្ដីព្យាយាម តែគាត់មិនបានសម្រេចសោះ។ យើងទាំងឡាយក៏ដូចជាបុរសចម្កួតនេះដែរ បើយើងសង្ឃឹមថានឹងអាចបំបាត់ពាក្យពេចន៍ទាំងអស់ចោលបាន។ យើងតោងតែហាត់បំពត់ចិត្តរបស់យើង ហើយយកភាពជាមិត្តមកបំពេញវា ដើម្បីកុំឲ្យចិត្តយើងវាមានការរីករវរំជួលដោយសារពាក្យពេចន៍គ្រប់បែបយ៉ាង ដែលអ្នកដទៃស្រដីមកកាន់យើង។

គេអាចនឹកស្រមៃយកជក់ជ្រលក់ទឹកថ្នាំពណ៌ ហើយគូររូបមួយនៅលើផ្ទៃមេឃខៀវស្រងាត់បាន តែការវិចិត្ររូបគំនូរនេះ មិនអាចប្រព្រឹត្តទៅដោយពិតបានទេ។ម្យ៉ាងទៀតគេមិនអាចធ្វើឲ្យទឹកក្នុងទន្លេដ៏ធំមួយរីងហួត ដោយយកគប់ចំបើងមួយទៅដុតកំដៅនោះបានទេ ឬបង្កើតសូរសំឡេងលាន់ប្រឹបៗដោយយកស្បែកដែលសម្ងាប់ទន់ល្អពីរបន្ទះ មកសង្កួតគ្នា នោះក៏ជាការពុំអាចធ្វើកើតដែរ។ ដូចជា ឧទាហរណ៍ទាំងនេះដែរ បុគ្គលគ្រប់រូបតោងតែហាត់ពត់ចិត្តរបស់ខ្លួន កុំឲ្យវាមានការរីករវរំដើបរំជួល នឹងពាក្យពេចន៍បែបណាក៏ដោយដែលបានឮ។

បុគ្គលទាំងឡាយត្រូវបង្ហាត់ចិត្តរបស់ខ្លួន ហើយរក្សាវាឲ្យបានទូលាយធំធេងដូចផែនដី ឲ្យបានល្អល្ហេវដូចផ្ទៃមេឃ ឲ្យ

បានជ្រៅដូចមហាសមុទ្រ ឲ្យបានទន់ដូចស្បែកសម្ងាប់ទន់ល្អ។

ទោះបីសត្រូវរបស់អ្នក ចាប់អ្នកយកទៅធ្វើទារុណកម្មក៏ដោយបើអ្នកកើតមានចិត្តចងគំនុំ បានន័យថា អ្នកមិនធ្វើតាមឱវាទព្រះពុទ្ធទេ។នៅក្នុងទេសកាលបែបណាក៏ដោយអ្នកត្រូវរៀនរិះគិតថា:«ចិត្តអញ មិនចេះរំជួលជាដាច់ខាត ពាក្យសំដីជាកំហឹងនិងសម្អប់ នឹងមិនចេញតាមបបូរមាត់ អញជាដាច់ខាត។ អញនឹងយកការរិះគិតក្នុងភាពជាមិត្ត និងករុណាអាសូរ ទៅគ្របលើសត្រូវរបស់អញ ការរិះគិតដែលហូរចេញពីចិត្តពោរពេញទៅដោយសេចក្ដីស្រឡាញ់ ចំពោះគ្រប់សត្វមានជីវិតទាំងអស់»។

5. មានរឿងល្បើកមួយនិទានថា ថ្ងៃមួយនោះបុរសម្នាក់ប្រទះឃើញសំបុកស្រមោចមួយ នៅពេលថ្ងៃមានភ្លើងឆេះឡើងនៅពេលយប់មានផ្សែងហុយឡើង។ បុរសនោះទៅរកអ្នកប្រាជ្ញបណ្ឌិតម្នាក់ហើយសួរថា តើគួរធ្វើដូចម្ដេចដែរចំពោះសំបុកស្រមោចនោះ។ អ្នកប្រាជ្ញបណ្ឌិតបង្គាប់ឲ្យយកដាវជីកកកាយមើលខាងក្នុងសំបុកស្រមោចនោះ។ បុរសនោះក៏

ធ្វើតាម ហើយបានប្រទះឃើញជាបន្តបន្ទាប់ វនុកទ្វារមួយ ពពុះទឹកមួយពំនូក ច្បូកមួយ ប្រអប់មួយ អណ្តើកមួយ កាំបិតហាន់សាច់មួយ សាច់មួយដុំ។ ជាចុងក្រោយបង្អស់ បុរសនោះប្រទះឃើញនាគមួយចេញមក។ បុរសក៏យករឿងដែលបានប្រទះឃើញទាំងនោះ ទៅជម្រាបលោកបណ្ឌិត។ លោកបណ្ឌិតពន្យល់បុរសនោះអំពីន័យនៃវត្ថុទាំងនោះសព្វគ្រប់ ហើយបង្គាប់ថា «ចូរអ្នកយកវត្ថុទាំងនោះបោះចោលឲ្យឆ្ងាយ ទុកតែនាគមួយនោះបានហើយ។ ចំពោះនាគនោះ ចូរអ្នកទុកវាឲ្យនៅតែម្នាក់វា កុំរំខានវាឡើយ»។

ក្នុងរឿងប្រឌិតនេះ សំបុកស្រមោចជារូបកាយមនុស្សលោក។ រឿងដែលសំបុកស្រមោចមានភ្លើងឆេះឡើងនៅពេលថ្ងៃ បានន័យថា នៅពេលថ្ងៃមនុស្សទាំងឡាយបំពេញកិច្ចការដែលគេបានគ្រោងទុកពីយប់។ រឿងដែលសំបុកស្រមោចមានផ្សែងហុយឡើងនៅពេលយប់ បានន័យថា នៅពេលយប់មនុស្សទាំងឡាយរំឭកឡើងវិញ ដោយចិត្តរីករាយ ឬសោកស្តាយនូវអ្វីៗ ដែលគេបានធ្វើពីពេលថ្ងៃ។

នៅក្នុងរឿងប្រឌិតនេះទៀត បុរសនោះគឺបុគ្គលដែលរក

ពន្ទីត្រាស់ដឹង។ លោកបណ្ឌិតគឺព្រះពុទ្ធ។ ដាវគឺគតិបណ្ឌិត បរិសុទ្ធ។ ការជីករកមើលដល់ទីជម្រៅ គឺការខំប្រឹងប្រែង ប្រតិបត្តិ ដើម្បីឲ្យបានដល់ពន្ទឺត្រាស់ដឹង។

ម្យ៉ាងទៀត ក្នុងរឿងប្រឌិតនេះ រនុកទ្វារគឺសេចក្ដីល្ងង់ខ្លៅ ពពុះទឹកគឺកំសួលនៃទុក្ខវេទនា ហើយនិងទោសៈ ចង្រូកគឺការ វង្វេងហើយនិងការពិបាក ប្រអប់គឺការប្រមូលផ្ដុំទុកនូវសេចក្ដី លោភលន់ សេចក្ដីខឹងក្រោធ សេចក្ដីខ្ជិលច្រអូស ចរិតសាវ៉ា សេចក្ដីសោកស្ដាយហើយនិងការខកចិត្ត អណ្ដើក គឺចិត្ត កាំបិតហាន់សាច់គឺការរួមផ្ដុំតណ្ហាទាំងឡាយដែលកើតឡើង ពីវិញ្ញាណទាំងប្រាំ ដុំសាច់សំដៅទៅលើចំណង់ដែលរុញច្រាន មនុស្សលោកឲ្យពួនពីក្រោយសេចក្ដីពេញចិត្ត។ វត្ថុទាំងប៉ុន្មាន នេះ វាចង្រៃចំពោះមនុស្សលោក ហេតុនេះហើយ បានជាព្រះ ពុទ្ធត្រាស់ថាៈ «ចូរយកវត្ថុទាំងនាំបោះចោលឲ្យអស់»។

ជាបញ្ចប់ ពស់នាគគឺវិញ្ញាណដែលកំចាត់បង់ នូវតណ្ហា លោកិយទាំងអស់។ បុគ្គលណាយកដាវគតិធម៌ជីករកវត្ថុឲ្យ ដល់ទីជម្រៅ បុគ្គលនោះនឹងបានទៅដល់នាគ នៅវេលាចុង ក្រោយបំផុត។ «ចូរទុកវាឲ្យនៅតែម្នាក់ឯង កុំរំខានវាឡើយ»

បានន័យថា ត្រូវស្វែងរកតែវិញ្ញាណដែលមិនជាប់ជំពាក់នឹងចំណង់លោកិយ។

6. ព្រះបិន្ទោលដែលជាសាវ័កមួយអង្គរបស់ព្រះពុទ្ធ នៅពេលក្រោយបានទៅដល់ពន្លឺត្រាស់ដឹងហើយ ក៏ត្រឡប់មកកាន់ក្រុងកោសម្ពី ដែលជាស្រុកកំណើតរបស់ព្រះអង្គវិញដើម្បីនឹងថ្លែងអំណរគុណ ដល់ជនទាំងឡាយនៅទីនោះ ដែលបានស្រឡាញ់រាប់អានព្រះអង្គ។ក្នុងកិច្ចថ្លែងអំណរគុណនេះព្រះអង្គបានកាប់ឆ្ការដីមួយដុំ ដើម្បីសាបព្រោះសំណាបពុទ្ធសាសនា។

នៅក្នុងសង្កាត់ជាយក្រុងកោសម្ពី មានសួនឧទ្យានមួយតូចបិតនៅតាមផ្លូវតូចតាមមាត់ទន្លេគង្គា។ ទីនោះ មានដើមដូងដុះជាជួរមើលដាច់កន្ទុយភ្នែក ចោលម្លប់ត្រឈឹងត្រឈៃមានខ្យល់ត្រជាក់បក់ល្វើយៗ មិនចេះដាច់។

ថ្ងៃមួយនារដូវក្ដៅ ព្រះបិន្ទោលអង្គុយភាវនា នៅក្រោមម្លប់ត្រជាក់នៃដើមឈើមួយដើម។ នៅពេលនោះមហាសេដ្ឋីឧទេន នាំប្រពន្ធគាត់ទាំងអស់មកកំសាន្តនៅក្នុងសួននោះដែរ។ ក្រោយពីស្ដាប់ភ្លេងនិងកំសាន្តសប្បាយមក គាត់ក៏លង់លក់

នៅក្រោមម្លប់ឈើទៅ។

ក្នុងពេលដែលមហាសេដ្ឋីសម្រាន្តលក់នោះ ប្រពន្ធ និង ស្រីអ្នកបម្រើទាំងអស់របស់គាត់នាំគ្នារត់លេង ទៅដល់កន្លែង ដែលព្រះបិន្ទោលគង់ភាវនា។ ស្រីទាំងនោះ យល់ឃើញថា ព្រះអង្គជាបុគ្គលបរិសុទ្ធ ក៏ថ្វាយបង្គំសុំឲ្យព្រះអង្គប្រៀនប្រដៅ ធម៌ ហើយក៏បត់ជើងអង្គុយស្តាប់ព្រះធម្មទេសនាទៅ។

នៅពេលដែលមហាសេដ្ឋីភ្ញាក់ឡើង មិនឃើញប្រពន្ធនិង ស្រីបម្រើ គាត់ក៏ដើររក ហើយទៅប្រទះឃើញស្រីទាំងនោះ នៅព័ទ្ធជុំវិញព្រះបិន្ទោល កំពុងតែស្តាប់ធម្មទេសនា។ ដោយ មានចិត្តប្រច័ណ្ឌ និងខ្វះសីលធម៌ មហាសេដ្ឋីខឹងច្រឡោតឡើង ហើយជេរប្រោសផ្តេះព្រះបិន្ទោលថា «បុគ្គលបរិសុទ្ធដែល នៅកណ្តាលហ្វូងស្រីៗ ហើយនិយាយសំណេះសំណាល បែ ចង់របៀបអ្នកឯងនេះ មិនគួរអត់ឱនទោសបានទេ»។ ព្រះបិ ន្ទោលទ្រង់បិទព្រះនេត្រសន្សឹមៗ ហើយគង់នៅដោយស្ងៀម ស្ងាត់ទៅ។

ដោយកំហឹងក្រោធ មហាសេដ្ឋីដកដាវឡើង ហើយគំរាម ព្រះបិន្ទោល តែបុគ្គលបរិសុទ្ធនៅតែស្ងាត់ស្ងៀមនឹងថ្កល់បីដូច

ជាផ្ទាំងសីលាជានិច្ច។ មហាសេដ្ឋីរឹតតែខឹងថែមឡើងជាខ្លាំង គាត់កាប់កំចាយសំបុកស្រមោច យកកំទេចដីដែលជាប់ស្រមោចពេញចោលទៅលើព្រះអង្គ តែព្រះបិន្ទោលនៅតែអង្គុយភាវនាឥតកម្រើក អត់ទ្រាំដោយអំណត់នឹងការជេរត្មះតិះដៀលហើយនិងសេចក្ដីឈឺចាប់។

ដល់ពេលនេះ មហាសេដ្ឋីដឹងខ្លួនខុស ហើយស្ដាយនូវអំពើឃោរឃៅដែលខ្លួនបានប្រព្រឹត្ត គាត់ក៏ថ្វាយបង្គំសុំទោសព្រះបិន្ទោល។ ក្រោយពីឧប្បត្តិហេតុនោះមក ព្រះពុទ្ធសាសនាក៏ត្រូវបានចូលមកក្នុងវិមានមហាសេដ្ឋីនោះ ហើយផ្សព្វផ្សាយចេញទៅពេញទាំងនគរ។

7. ប៉ុន្មានថ្ងៃក្រោយមក មហាសេដ្ឋីឧទេន ទៅថ្វាយបង្គំព្រះបិន្ទោលនៅក្នុងអាស្រមព្រះអង្គក្នុងព្រៃ ហើយទូលសួរព្រះអង្គថា: «ព្រះជាម្ចាស់ តើសាវ័កទាំងឡាយរបស់ព្រះពុទ្ធធ្វើដូចម្ដេចក៏អាចរក្សារូបកាយនិងចិត្តឲ្យនៅបរិសុទ្ធបាន ហើយមិនលុះទៅក្រោមតណ្ហា? ហើយព្រះសាវ័កទាំងនោះច្រើនតែបុគ្គលនៅក្មេងផង!» ។

ព្រះបិណ្ឌោលឆ្លើយថាៈ «មហាសេដ្ឋីដ៏ចម្រើន ព្រះពុទ្ធបានប្រដៅយើង ឲ្យគោរពគ្រប់ស្រីទាំងអស់។ លោកបានប្រដៅយើង ឲ្យទុកស្រីចំណាស់ទាំងអស់ជាម្តាយរបស់យើង ទុកស្រីដែលមានអាយុស្មើនឹងយើង ជាបងប្អូនស្រីរបស់យើង ហើយទុកស្រីដែលមានអាយុតិចជាងយើង ជាកូនស្រីរបស់យើង។ ដូច្នេះហើយ បានជាសាវ័កទាំងឡាយរបស់ព្រះពុទ្ធអាចរក្សារូបកាយនិងចិត្តរបស់ខ្លួនឲ្យនៅបរិសុទ្ធបាន ហើយមិនលុះទៅក្នុងអំណាចតណ្ហា ទោះបីគេនៅកំពុងពេញវ័យក៏ដោយ"។

«ប៉ុន្តែ ព្រះជាម្ចាស់! គេអាចនៅតែមានគំនិតមិនបរិសុទ្ធចំពោះស្ត្រីដដែល ទោះបីស្រីនោះមានវ័យជាមាតារបស់គេក៏ដោយ ជាបងស្រីរបស់គេក៏ដោយ ឬជាកូនរបស់គេក៏ដោយ! តើព្រះសាវ័កទាំងឡាយរបស់ព្រះពុទ្ធ គ្រប់គ្រងសង្កត់ចំណង់របស់ខ្លួនយ៉ាងដូចម្តេចទៅ?»។

«សេដ្ឋីដ៏ចម្រើន ព្រះពុទ្ធជាម្ចាស់បានប្រដៅយើងឲ្យក្រឡេកមើលខ្លួនឯង ដែលបញ្ចេញវត្ថុអសោចគ្រប់បែបយ៉ាងដូចជាឈាម ខ្ទុះ ញើស ខ្ញាញ់ ជាដើម។ ដោយគិតទៅដល់វត្ថុអសោចទាំងនោះ ទោះបីជាយើងមានវ័យនៅក្មេងក៏ដោយ

យើងអាចរក្សាចិត្តរបស់យើង ឲ្យនៅបរិសុទ្ធបាន»។

មហាសេដ្ឋីមានវាចាទៀតថាៈ «ព្រះជាម្ចាស់ ដ៏ប្រសើរអើយ ! ចំពោះព្រះអង្គ ការប្រព្រឹត្តបែបនេះ វាស្រួលណាស់ ពីព្រោះព្រះអង្គបានហាត់ហ្វឹកហ្វឺនបំពត់រូបកាយ និងចិត្តជាស្រេចហើយ ហើយបានដុសខាត់សតិបញ្ញាឲ្យភ្លឺស្វាងរួចជាស្រេចហើយ ប៉ុន្តែចំពោះបុគ្គលដែលមិនទាន់បានទទួលការហាត់ហ្វឹកហ្វឺនរបៀបនេះម្តងណាសោះនោះ ជាការពិបាកណាស់។ បុគ្គលទាំងនោះអាចខំប្រឹងគិតអំពីភាពអសោចទាំងនោះបាន តែភ្នែករបស់គេ វាជាប់ជំពាក់ទៅលើទ្រង់ទ្រាយដ៏សោភណដែលគេមើលឃើញ។ បុគ្គលទាំងនោះអាចខំប្រឹងគិតអំពីភាពមិនសមរម្យ តែគេនៅតែមានចិត្តប៉ុនប៉ងទៅលើសោភណភាពជាចុងក្រោយបង្អស់ដដែល។ ហេតុនេះ វាត្រូវតែមានហេតុជាសមធម៌ផ្សេងទៀត ដែលនាំឲ្យព្រះសាវ័កក្មេងៗរបស់ព្រះពុទ្ធអាចរក្សាចិត្តរបស់ខ្លួនឲ្យនៅបរិសុទ្ធបាន»។

ព្រះបិណ្ឌោលឆ្លើយថាៈ «ព្រះបរមគ្រូប្រដៅយើងថា ឲ្យចេះរក្សាការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំរបស់យើង។

កាលណា យើងឃើញរូបស្រស់ពណ៌ល្អនៅនឹងភ្នែកយើង កាលណាយើងឮសូរសព្ទពីរោះនៅនឹងត្រចៀកយើង កាលណាយើងធុំក្លិនក្រអូបនៅនឹងច្រមុះយើង កាលណាយើងត្រេកអរសជាតិឆ្ងាញ់នៅនឹងអណ្តាតយើង ហើយកាលណាយើងស្ទាបវត្ថុទន់ល្មៃនៅនឹងដៃយើង យើងនឹងមិនជាប់ជំពាក់នឹងវត្ថុដែលទាក់ទាញយើង ឬក៏យើងគេចចេញពីវត្ថុដែលរុញច្រានយើងចេញនោះ។ យើងបានរៀនការពារយ៉ាងល្អិតល្អន់ នូវមាត់ទ្វារនៃវិញ្ញាណទាំងប្រាំនេះ។ គឺដោយសារ ការទូន្មានដែលព្រះបរមគ្រូ បានផ្តល់ឲ្យយើងនេះហើយ បានជាសូម្បីសាវ័កក្មេងៗក៏ដោយ ក៏អាចរក្សារូបកាយ និងចិត្តរបស់គេឲ្យបាននៅបរិសុទ្ធបាននោះដែរ»។

«សេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ ពិតជាប្រសើរល្អជាទីបំផុត។ តាមការពិសោធន៍របស់អាត្មាផ្ទាល់ អាត្មាដឹងថា តែកាលណាអាត្មាជួបប្រទះនឹងវត្ថុល្អស្រស់គួរឲ្យចាប់ចិត្ត អាត្មាតែងតែរំភើបញាប់ញ័រដោយសារការចាប់ចិត្តមានអារម្មណ៍ដែលកើតចេញឡើងពីវិញ្ញាណទាំងប្រាំនោះ នៅពេលណាដែលអាត្មាមិនបានប្រុងប្រយ័ត្ន។ ដូច្នេះ ការប្រុងប្រយ័ត្ន

ការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំនេះ ជាការសំខាន់បំផុត ដើម្បីរក្សាអំពើទាំងឡាយរបស់យើង ឲ្យបានបរិសុទ្ធនៅគ្រប់ពេលវេលា»។

8. នៅពេលណាក៏ដោយ តែកាលណាគេបញ្ចេញ គំនិតអ្វីមួយតែងតែមានការប្រឆាំងកើតឡើងជានិច្ច។ កាលណាគេជេរអ្នក អ្នកនឹងមានបំណងជេរតបទៅវិញ ឬនឹងធ្វើការសងសឹក។ គេត្រូវតែប្រយ័ត្ននឹងប្រតិកម្មជាធម្មជាតិនេះ។ គឺដូចជាគេស្តោះទឹកមាត់បញ្ច្រាសខ្យល់ ទឹកមាត់នោះគ្មានទៅប្រឡាក់អ្នកណា ក្រៅពីខ្លួនគេផ្ទាល់នោះទេ។ គឺដូចជាគេបោលកំទេចសំរាមបញ្ច្រាសខ្យល់ គេគេចមិនផុត អំពីសំរាមនោះទេ គេមុខតែប្រឡាក់ខ្លួនគេនឹងកំទេចសំរាមនោះហើយ។ វាសនាអាក្រក់ ដើរតាមប្រកិតនឹងបុគ្គលដែលបណ្តោយខ្លួនឲ្យមានបំណងសងសឹក។

9. គឺជាអំពើល្អណាស់ ដែលចេះទាត់ចោលនូវការលោភលន់ហើយចិញ្ចឹមចិត្តមានមេត្តាធម៌។ ប៉ុន្តែរឹតតែប្រសើរណាស់ទៅ

ទៀត ដែលបេះរក្សាចិត្តឲ្យប្រុងប្រៀបទទួលគោរពតាមគន្លង ព្រះធម៌ដ៏ឧត្តម។

គេត្រូវតែបោះបង់ចោលនូវចិត្តអត្តទត្ថៈ ដែលគិតតែពីខ្លួនឯងផ្ទាល់ ហើយប្រកាន់យកចិត្តបេះជួយយកអាសា អ្នកដទៃមកជំនួសវិញ។ កាលណាគេយកអាសាជនណាម្នាក់ឲ្យបានប្រកបសេចក្ដីសុខ កិច្ចនេះនឹងបណ្ដាលឲ្យជននោះជួយយកអាសាជនម្នាក់ទៀតឲ្យបានប្រកបសេចក្ដីសុខ ហើយសុកមង្គលនឹងកើតមានឡើង ដោយសារអំពើទាំងនេះឯងហោង។

គេអាចដុតទៀនមួយពាន់ដើមឲ្យឆេះឡើងបាន ដោយសារតែទៀនមួយដើមគត់ ហើយទៀនមួយដើមនោះ ក៏មិនមានអាយុខ្លី ដោយសារតែការដុតបន្តពីមួយទៅមួយនោះទេ យ៉ាងណាមិញ សុកមង្គល ក៏មិនចុះអន់ថយ ដោយសារតែការចែករំលែកទៅអ្នកឯទៀតនោះដែរ។

បុគ្គលណាដែលស្វែងរកពន្លឺត្រាស់ដឹង តោងតែប្រុងប្រយ័ត្ននូវជំហានទីមួយរបស់ខ្លួន។ ទោះបីជាសេចក្ដីប្រាថ្នារបស់ខ្លួនវាខ្ពស់យ៉ាងណាក៏ដោយ ក៏តោងតែឈានទៅកាន់ពន្លឺត្រាស់ដឹងនោះ មួយជំហានម្ដងៗ។ ជំហានដើរតាមផ្លូវទៅ

កាន់ពន្លឺត្រាស់ដឹងនេះ ត្រូវតែប្រព្រឹត្តឡើងជារៀងរាល់ថ្ងៃនៃជីវិតរបស់យើង: ថ្ងៃនេះ ថ្ងៃស្អែក ថ្ងៃខានស្អែក និងថ្ងៃជាបន្តៗទៅទៀត។

10. នៅខាងដើមផ្លូវឆ្ពោះទៅកាន់ពន្លឺត្រាស់ដឹងមានកិច្ចកម្រ ២០ យ៉ាង ដែលយើងត្រូវបំពេញនៅក្នុងលោកនេះគឺ: ១-បុគ្គលដែលក្ររហេមរហាម ហើយឲ្យមានចិត្តទូលាយនោះជាការក្រ។ ២-បុគ្គលដែលមានអភិមានះឡឹតហើយ ឲ្យរៀនរបៀបដើរទៅកាន់ពន្លឺត្រាស់ដឹងជាការក្រ។ ៣-ការស្វែងរកពន្លឺត្រាស់ដឹងដោយធ្វើពលិកម្មខ្លួនឯង ជាការក្រ។ ៤-ការកើតនៅពេលមានព្រះពុទ្ធមួយព្រះអង្គគង់ក្នុងលោកនេះ ជាការក្រ។ ៥-ការបានស្តាប់ឮសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធជាការក្រ។ ៦-ការរក្សាចិត្តឲ្យបរិសុទ្ធតទល់នឹងសភាវៈរូបកាយជាការក្រ។ ៧-ការមិនចង់បានវត្ថុស្រស់ល្អដែលទាក់ទាញចិត្តជាការក្រ។ ៨-មនុស្សដែលខ្លាំង ហើយកុំឲ្យប្រើកម្លាំងដើម្បីបំពេញបំណងខ្លួន ជាការក្រ។ ៩-ការមិនខឹងតបកាលណាគេជេរ ជាការក្រ។ ១០-ការទប់ចិត្តមិនឲ្យភ្ញើតភ្ញើនជ្រួលច្របល់

ទៅតាមទេសៈកាលៈ ដែលកើតឡើងភ្លាមៗ ជាការក្រៅ ១១-ការបង្ខំខ្លួនដោយខ្លួនឯង ឲ្យស្រង់យកនូវចំណេះវិជ្ជាទូលំទូលាយ ល្អិតល្អន់ ជាការក្រៅ ១២-ការមិនប្រកាន់មើលងាយអ្នកចំណូលថ្មី ជាការក្រៅ ១៣-ការធ្វើខ្លួនឲ្យរាបសា ជាការក្រៅ ១៤- ការរកមិត្តល្អ ជាការក្រៅ ១៥- ការទ្រាំទ្រនឹងវិន័យដែលដឹកនាំទៅកាន់ពន្លឺត្រាស់ដឹង ជាការក្រៅ ១៦-ការមិនរឹកររចិត្តនឹងសភាពជាខាងក្រៅ ហើយនឹងទេសកាលជាការក្រៅ ១៧-ការបង្រៀនប្រដៅអ្នកដទៃ ដោយសម្របទៅតាមសមត្ថភាពអ្នកទាំងនោះ ជាការក្រៅ ១៨-ការរក្សាចិត្តឲ្យស្ងប់ ជាការក្រៅ ១៩-ការមិនជជែករកខុសរកត្រូវ ជាការក្រៅ ២០-ការស្វែងរករៀនសូត្រវិធីល្អ ជាការក្រៅ

11. មនុស្សល្អនិងមនុស្សអាក្រក់ ខុសគ្នាទៅតាមចរិតរបស់មនុស្សទាំងនោះៗ មនុស្សអាក្រក់មិនមើលឃើញអំពើដែលជាទោស ថាខុសទេ។ បើគេសម្គាល់ឃើញកំហុសណាមួយដែលគេបានធ្វើ គេមិនឈប់ប្រព្រឹត្តកំហុសនោះទេ ហើយគេមិនចង់ឲ្យនរណារំឭកកំហុសនោះដល់គេទេ។ មនុស្សប្រកប

ដោយគតិបណ្ឌិតធាប់ដឹងសេចក្ដីល្អ និងសេចក្ដីអាក្រក់ណាស់។ គេឈប់ធ្វើអំពើដែលអាក្រក់ភ្លាម កាលណាគេឃើញថា អំពើនោះមិនគាប់ប្រសើរ។ គេដឹងគុណដល់អ្នកដែលរំឭកអំពីកំហុសរបស់គេប្រាប់គេ។

ដូច្នេះឃើញថា មនុស្សល្អនិងមនុស្សអាក្រក់ខុសគ្នាយ៉ាងដាច់ស្រឡះ។ មនុស្សអាក្រក់ មិនដែលទទួលស្គាល់នូវសេចក្ដីគួរសម ដែលអ្នកឯទៀតបានផ្ដល់ដល់ខ្លួនម្ដងណាទេ។ ចំណែកមនុស្សល្អវិញគេទទួលយកសេចក្ដីគួរសមនេះ ដោយចិត្តមានអំណរគុណ។ មនុស្សដែលប្រកបដោយគតិបណ្ឌិត ខំប្រឹងប្រែងសម្ដែងនូវចិត្តមានអំណរគុណនេះ ដោយបញ្ចេញឲ្យឃើញនូវសេចក្ដីគួរសមតបទៅវិញ មិនត្រឹមតែចំពោះអ្នកដែលបានធ្វើគុណដល់ខ្លួននោះទេ គេថែមទាំងបេះគួរសមចំពោះអ្នកឯទៀតទៀតផង។

III

# សេចក្ដីឧត្ដមតាមរឿងព្រេងប្រឌិត

1. កាលពីព្រេងនាយ មានស្រុកមួយមានទំនៀមទម្លាប់ពិសេសចម្លែក គឺគេយកមនុស្សចាស់ជរាទៅបំបរបង់ចោលនៅក្នុងព្រៃភ្នំឆ្ងាយដាច់ស្រយាល ដែលគ្មាននរណាទៅដល់។

មានឧត្តមមន្ត្រីម្នាក់ឃើញថា ទំនៀមទម្លាប់នេះលំបាកនឹងប្រតិបត្តិតាមណាស់ ក្នុងករណីឪពុកបង្កើតរបស់លោក។ ហេតុនេះ លោកក៏សង់លេណដ្ឋានក្រោមដីមួយ ហើយយកឪពុកលោកទៅលាក់ក្នុងលេណដ្ឋាននោះ។

ថ្ងៃមួយ អាទិទេពមួយព្រះអង្គ និម្មិតឲ្យឃើញឡើងនៅចំពោះព្រះភក្ត្រព្រះមហាក្សត្រនគរនោះ ហើយចោទប្រស្នាមួយយ៉ាងពិបាក។ ព្រះអាទិទេពនោះដាក់ខសន្យាថា បើស្ដេចមិនអាចដោះប្រស្នានេះឲ្យបានត្រឹមត្រូវសមរម្យទេ យើងនឹងកំទេចនគរនេះចោល។ ប្រស្នានោះមានសេចក្ដីថា: «មានពស់ពីរ ចូរស្ដេចបញ្ជាក់ប្រាប់យើង តើពស់មួយណាឈ្មោលពស់មួយណាញី»។

ទាំងព្រះមហាក្សត្រ ទាំងនាម៉ឺនមន្ត្រីទាំងអស់នៅក្នុងព្រះបរមរាជវាំង គ្មាននរណាម្នាក់អាចដោះប្រស្នានោះរួចឡើយ។ ហេតុនេះព្រះមហាក្សត្រក៏ប្រកាសសន្យាថា នឹងប្រទានរង្វាន់

ធំដល់អ្នកណាដែលអាចដោះប្រស្នានោះរួច។

លោកឧត្តមមន្ត្រីទៅជួបនឹងឪពុករបស់លោក នៅក្នុងទីលាក់បំពួន ហើយសួរអំពីប្រស្នានោះ។ ឪពុកជរាឆ្លើយថា: «ប្រស្នានេះស្រួលដោះស្រាយណាស់។ ចូរដាក់ពស់ទាំងពីរនោះលើកម្រាលព្រំទន់ល្មើយមួយ ពស់ណាកម្រើក គឺពស់ឈ្មោល ពស់ដែលនៅស្ងៀមជាពស់ញី»។ ឧត្តមមន្ត្រីយកចម្លើយនោះទៅទូលព្រះមហាក្សត្រ ហើយប្រស្នាក៏ត្រូវដោះស្រាយរួចប្រកបដោយជោគជ័យ។

កាលនោះ ព្រះឥន្ទ្របានដាក់ប្រស្នាពិបាកៗផ្សេងទៀតជាច្រើន។ ព្រះមហាក្សត្រក្តី នាម៉ឺនមុខមន្ត្រីគ្រប់ជាន់ថ្នាក់ក្តី ពុំអាចដោះប្រស្នាទាំងនោះបានឡើយ។ តែលោកឧត្តមមន្ត្រីតែងតែទៅសួរឪពុកជរារបស់លោក ហើយដោះប្រស្នាទាំងនោះរួចយ៉ាងប្រសើរ។

ប្រស្នាខ្លះៗហើយនិងចម្លើយ មានដូចតទៅនេះ «បុគ្គលដែលដេកលក់ ហើយហៅថាភ្ញាក់រលឹក តើបុគ្គលបែបណាដែរ? បុគ្គលដែលភ្ញាក់រលឹក ហើយហៅថាដេកលក់ តើបុគ្គលបែបណាដែរ?»។ ចម្លើយមានដូចតទៅនេះ «គឺបុគ្គលដែ ល

ហាត់រៀន ដើម្បីឆ្ពោះទៅរកពន្លឺត្រាស់ដឹង។ បើប្រដូចទៅបុគ្គល មិនស្វែងរកពន្លឺត្រាស់ដឹង បុគ្គលនោះហៅថា ភ្ញាក់រលឹក តែបើប្រដូចទៅបុគ្គល ដែលបានទៅដល់ពន្លឺត្រាស់ដឹងហើយនោះ បុគ្គលនោះហៅថាដេកលក់»។

«តើគេអាចថ្លឹងដំរីធំមួយ របៀបណាបាន»?។ ចម្លើយ: «ចូរយកដំរីធំនោះដាក់ក្នុងទូកធំមួយ ហើយគូសចំណាំជម្រៅដែលទូកលិចទៅក្នុងទឹក។ បន្ទាប់មកចូរយកដំរីចុះចេញពីទូក ហើយយកដុំថ្មផ្ទុកក្នុងទូករហូតដល់ទូកលិចទៅដល់ខ្សែគំនូសចំណាំនោះ។ រួចហើយ យកដុំថ្មនោះមកថ្លឹង ជាការស្រេច!»។

«តើពាក្យថា: ទឹកមួយកែវ ច្រើនជាងទឹកមួយសមុទ្រ បានន័យដូចម្ដេច?»។ ចម្លើយ: «ទឹកមួយកែវដែលផ្ដល់ឲ្យដល់មាតាបិតា ឬដល់អ្នកជម្ងឺម្នាក់ ដោយចិត្តស្មោះសរ និងករុណាអាសូរ បានបុណ្យធំធេងគ្មានទីចប់។ តែចំពោះទឹកសមុទ្រវិញ ថ្ងៃណាមួយគង់នឹងរីងហួតវិនាសអស់មិនខាន»។

ព្រះឥន្ទ្រក្លែងខ្លួនឡើងម្ដងទៀត ជាមនុស្សអត់ឃ្លានរហាម មានតែស្បែកដណ្ដប់ឆ្អឹង ហើយថ្លែងថា: «នៅក្នុងលោកនេះ តើមាននរណា ដែលអត់ឃ្លានជាងអញនេះទៅទៀតដែរឬ

ទេ?»។ ចម្លើយ: «បុគ្គលដែលប្រកបដោយអត្តទត្តភាព និង សេចក្តីលោភលន់ រហូតដល់មិនជឿនូវរតនៈទាំងបី គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយមិនដឹងគុណមាតាបិតា គ្រូអាចារ្យ បាធ្យាយ មិនត្រឹមតែអត់ឃ្លានទេ បុគ្គលនោះនឹងធ្លាក់ទៅក្នុង ភពប្រេតអសុរកាយអត់ឃ្លាន ហើយនឹងទទួលក្តីវេទនាអត់ ឃ្លានគ្មានទីបំផុត»។

«បន្ទះឈើចន្ទន៍មួយបន្ទះនេះ តើខាងណាជាចុង ខាង ណាជាខាងគល់?។ ចម្លើយ: «ចូរយកបន្ទះឈើនោះទៅដាក់ បណ្តែតទឹក ខាងណាលិចទៅក្នុងទឹកជ្រៅជាងនោះជាខាង គល់»។

«សេះពីរដែលមានកំពស់និងកិនភាគដូចគ្នាបេះបិទនេះ តើសេះណាជាមេ សេះណាជាកូន?»។ ចម្លើយ: «ចូរយក ចំបើងមកដាក់ឲ្យសេះទាំងពីនោះស៊ី សេះជាមេនឹងរុញច្រាន ចំបើងនោះទៅដាក់នៅមុខកូនវា»។

ចម្លើយចំពោះប្រស្នាដ៏ពិបាកៗទាំងនោះ ធ្វើឲ្យព្រះឥន្ទ្រ និងព្រះមហាក្សត្រពេញព្រះទ័យណាស់។ ព្រះមហាក្សត្រ ទ្រង់សព្វព្រះរាជហឫទ័យ ដោយបានដឹងថា ចម្លើយទាំង

នោះបានមកពីមនុស្សជរាម្នាក់ ដែលកូនយកទៅលាក់ក្នុងបន្ទប់ក្រោមដី។ ព្រះអង្គក៏បញ្ជាឲ្យលុបទំនៀមទម្លាប់យកមនុស្សជរាទៅបំបរបង់ចោល នៅក្នុងព្រៃភ្នំនោះចោលទៅ ហើយទ្រង់បញ្ជាឲ្យថែរក្សាគោរពមនុស្សចាស់ជរា ដោយចិត្តសប្បុរសធម៌។

2. នៅប្រទេសឥណ្ឌា មានកាលមួយនោះ ព្រះមហាក្សត្រិយានីស្ដេចវិទេហៈ ទ្រង់សុបិននិមិត្តឃើញដំរីសមួយ មានដុះភ្លុកប្រាំមួយ។ ព្រះអគ្គមហេសីនឹកចង់បានភ្លុកដំរីសនោះ ក៏ទូលអង្វរព្រះមហាក្សត្រឲ្យរកយកមកថ្វាយ។ ព្រះមហាក្សត្រ ទោះបីយល់ថា ការនេះប្រហែលជាមិនបានសម្រេចទេយ៉ាងនេះ ក៏ដោយ តែដោយក្ដីស្នេហាចំពោះព្រះអគ្គមហេសី ព្រះអង្គទ្រង់ប្រកាសថានឹងប្រទានរង្វាន់ធំដល់ព្រានព្រៃណាដែលបានប្រទះឃើញដំរីរបៀបនេះ ហើយយកដំណឹងមកថ្វាយព្រះអង្គ។

កាលនោះនៅក្នុងព្រៃហិមពាន្ត មានដំរីមួយមានភ្លុកប្រាំមួយរស់នៅពិតប្រាកដមែន។ ដំរីសនោះ កំពុងតែហាត់ហ្វឹកហ្វឺន ដើម្បីបានសម្រេចពន្លឺត្រាស់ដឹង។ មានថ្ងៃមួយ ដំរីស

បានជួយសង្គ្រោះព្រានព្រៃម្នាក់ ឲ្យរួចផុតពីគ្រោះថ្នាក់ធំដល់ជីវិតនាកណ្ដាលព្រៃភ្នំ។ ព្រានព្រៃនោះក៏បានរួចរស់មានជីវិតត្រឡប់មកដល់ផ្ទះវិញដោយសុខសាន្ត។ កាលនោះ ព្រានព្រៃដោយវង្វេងស្មារតីនឹងការនឹកសង្ឃឹមចង់បានមហារង្វាន់ ក៏ភ្លេចអស់នូវគុណ ដែលដំរីសបានធ្វើដល់ខ្លួន។ ព្រានព្រៃត្រឡប់ចូលទៅក្នុងព្រៃភ្នំវិញ ដើម្បីសម្លាប់ដំរីស។

ដោយដឹងថា ដំរីសកំពុងតែបំពេញសេចក្ដីព្យាយាមដើម្បីសម្រេចពន្លឺត្រាស់ដឹង ព្រានព្រៃក៏ក្លែងខ្លួនជាបព្វជិតមួយអង្គលបចូលទៅបាញ់ត្រូវដំរីស ដែលពុំបានប្រុងប្រយ័ត្ននឹងព្រួញពិសមួយ។

ដំរីសដឹងខ្លួនថា នឹងជិតដល់នូវទីអវសាននៃជីវិតហើយៗដឹងទៀតថា ព្រានព្រៃងប់ងល់នឹងចំណង់លោកិយដោយចង់បានរង្វាន់។ ដំរីសក៏មានចិត្តអាណិតអាសូរព្រានព្រៃ ហើយយកជើងរាំងពាការពារព្រាននោះនឹងដំរីឯទៀត ដែលប្រុងនឹងប្រហារព្រាន ដើម្បីជាការសងសឹក។ ដំរីសសួរទៅព្រានថាហេតុដូចម្ដេចក៏អ្នកប្រព្រឹត្តអំពើឆ្កួតលេលាបៀបនេះ។ ព្រានព្រៃនិយាយអំពីរឿងរង្វាន់ប្រាប់ទៅដំរីស ហើយវាចាថា ចង់

ដកយកក្ដុកទាំងប្រាំមួយនោះ។ ភ្លាមនោះ ដំរីក៏បោលជល់នឹងដើមឈើ កាច់យកក្ដុកប្រគល់ឲ្យទៅព្រានព្រៃ ហើយថ្លែងថាៈ «ដោយខ្ញុំបានធ្វើទាននេះ ខ្ញុំបានចប់ការព្យាយាមរបស់ខ្ញុំដើម្បីទៅកាន់ពុទ្ធញ្ញាណហើយ ហើយខ្ញុំនឹងទៅកើតក្នុងដែនដីបរិ-សុទ្ធ។ កាលណាខ្ញុំបានត្រាស់ជាព្រះពុទ្ធ ខ្ញុំនឹងជួយអ្នកឲ្យបានចាកផុតពីព្រួញពិសទាំងបីគឺៈ ការលោភលន់ ការក្រោធខឹង និងការយល់ច្រឡំ»។

3. នៅក្នុងដង្ហុំព្រៃឫស្សីនាជើងភ្នំហិមពាន្ត មានសត្វសេកមួយរស់នៅជាមួយនឹងម្រឹគីម្រឹគា បក្សាបក្សីឯទៀតៗ ជាច្រើន។ ថ្ងៃមួយដោយត្រូវខ្យល់បក់ខ្លាំង ដើមឫស្សីពីរដើមកកិតគ្នាបង្កើតបានជាភ្លើងឆេះព្រៃឫស្សីទាំងមូល។ ម្រឹគ បក្សីទាំងឡាយមានការភិតភ័យជាខ្លាំង។ សត្វសេកមានចិត្តអាណិតម្រឹគបក្សីដែលកំពុងរងទុក្ខភ័យ ហើយនឹកដល់គុណដែលសត្វទាំងនោះបានផ្ដល់ដល់ខ្លួនឲ្យបានរស់នៅដោយសុខសាន្តក្នុងព្រៃឫស្សីនោះ ក៏ខំជួយសង្គ្រោះសត្វទាំងនោះ យ៉ាងអស់សមត្ថភាព។ សត្វសេក លោតមុជទៅក្នុងបឹងនៅជិតនោះ ស្រូបពាំយកទឹក

ហើរឡើងទៅលើភ្លើង ហើយព្រួសទឹកចុះមក ដើម្បីពន្លត់អគ្គី-ភ័យ។ សត្វសេកព្យាយាមធ្វើកិច្ចនេះ ដោយចិត្តអាណិតអាសូរ និងដឹងគុណដល់ដង្ហុំព្រៃឫស្សី ។

ចិត្តមានប្រណីមេត្តា និងពលិកម្មនៃសត្វសេកនោះ បានដឹងដល់ព្រះឥន្ទ្រ។ ព្រះឥន្ទ្រក៏ចុះពីឋានសួគ៌មក ហើយមានព្រះបន្ទូលទៅកាន់សេកថា: «អ្នកមានចិត្តក្លាហានក៏ពិតមែនហើយ តែវាបានប្រយោជន៍អ្វី ដែលអ្នកព្រួសដំណក់ទឹកបន្តិចបន្តួចទៅលើភ្លើងដ៏ធំយ៉ាងនេះ ? » ។ សេកឆ្លើយថា «គ្មានអ្វីដែលមិនអាចបំពេញបាន ដោយចិត្តដឹងគុណ និងជាពលិ-កម្មនោះទេ។ ខ្ញុំនឹងខំបំពេញហើយខំទៀត រហូតដល់អនាគតជាតិនៃខ្ញុំជាខាងក្រោយៗទៀត»។ ព្រះឥន្ទ្រាធិរាជ ទ្រង់រំភើបនឹងចិត្តដ៏ប្រសើរនៃសេកនោះ ហើយជួយលត់មហាអគ្គីភ័យនោះឲ្យបានរលត់ទៅ។

4. កាលមួយនោះ នៅក្នុងព្រៃហិមពាន្ត មានបក្សីមួយមានអង្គកាយមួយ និងក្បាលពីរ។ មានមួយថ្ងៃ ក្បាលមួយបានឃើញក្បាលមួយទៀត ស៊ីផ្លែឈើដ៏ឆ្ងាញ់ពិសា ក៏កើតក្តីប្រណែន

ហើយនិយាយទៅកាន់ខ្លួនឯងថា: «អញនឹងស៊ីផ្លែឈើមានពិសពុល»។ គិតដូច្នោះហើយ ក្បាលនោះក៏ស៊ីផ្លែឈើមានពិសពុល ហើយអង្គបក្សីទាំងមូលក៏ក្សិណក្ស័យទៅ។

5. មានមួយកាល កន្ទុយនិងក្បាលនៃសត្វពស់មួយឈ្លោះដណ្ដើមគ្នាលូនទៅមុខ។ កន្ទុយនិយាយទៅកាន់ក្បាលថា: «មិនយុត្តិធម៌ទេ! ពេលខ្លះ ឯងគួរតែទុកឲ្យអញនាំមុខផង»។ ក្បាលឆ្លើយថា «នេះជាច្បាប់ធម្មជាតិរបស់យើង ដែលអញត្រូវតែនៅខាងក្បាល អញមិនអាចប្តូរកន្លែងជាមួយនឹងឯងបានទេ»។

ការឈ្លោះប្រកែកគ្នានេះ ចេះតែមានជាបន្តបន្ទាប់ ដរាបទៅរហូតដល់មានមួយថ្ងៃ កន្ទុយទៅរៀនព័ន្ធព័ទ្ធនឹងដើមឈើធំមួយ បណ្ដាលឲ្យក្បាលទៅមុខមិនរួច។ នៅពេលដែលក្បាលអស់កម្លាំងប្រយុទ្ធលែងកើត កន្ទុយក៏លូនឆ្ពោះទៅតាមទិសដែលខ្លួនចង់ទៅនោះទៅ។ ពស់ក៏ធ្លាក់ទៅក្នុងគប់ភ្លើង ហើយក៏ដល់នូវក្តីមរណៈទៅ។

នៅក្នុងធម្មជាតិ តែងតែមានលំដាប់លំដោយមួយ ហើយ

អ្វីៗទាំងអស់សុទ្ធតែមានមុខងារពិសេសផ្ទាល់ផ្សេងៗគ្នា។ បើកាលណាលំដាប់លំដោយនោះមានការរីករវរហើយ ដំណើរការទាំងអស់នឹងឈប់ដើរ ហើយលំដាប់លំដោយទាំងមូលមុខតែនឹងឆ្ពោះទៅរកក្ដីវិនាសជាទីបំផុត។

6. ក្នុងសម័យមួយនោះ មានបុរសម្នាក់ឆេវឆាវឆាប់ខឹងជាពន់ពេក។ ថ្ងៃមួយ មានបុរសពីរនាក់សន្ទនាគ្នាអំពីបុរសឆាប់ខឹងនៅមុខផ្ទះបុរសនោះថា: «គាត់ជាមនុស្សគួរជាទីរាប់អានស្រឡាញ់តែគាត់ខ្វះសេចក្ដីអំណត់។ គាត់មានចរិតឆេវឆាវ ឆាប់ច្រឡោតខឹងណាស់»។ បុរសឆាប់ខឹងភ្ញាក់នឹងការសន្ទនាគ្នានេះ ក៏ស្ទុះចេញពីផ្ទះដោយកំពោល ទៅប្រវាយប្រតប់ទាត់ធាក់បុរសពីរនាក់ដែលសន្ទនាគ្នានោះ បណ្ដាលឲ្យគ្នាមានរបួសជាច្រើនអន្លើ។

មនុស្សប្រកបដោយគតិបណ្ឌិត កាលណាឮអ្នកដទៃនិយាយអំពីកំហុសរបស់គេ គេយករឿងនោះទៅពិចារណា ហើយគេកែចរិយាអាក្រក់របស់គេ។ ផ្ទុយទៅវិញមនុស្សពាលកាលណាមានគេបង្ហាញឲ្យឃើញនូវចរិយាអាក្រក់របស់ខ្លួន

បុគ្គលឆ្កួតពាលនោះ មិនត្រឹមតែមិនយកចិត្តទុកដាក់នឹងការព្រមាននោះទេ គេរឹតតែខំប្រព្រឹត្តកំហុសដដែលនោះជាថ្មីបន្តទៅទៀតផង។

7. កាលនោះ មានជនម្នាក់ជាអ្នកមានស្ដុកស្ដម្ភ តែឆ្កួតលេលា។ នៅពេលដែលអ្នកមានស្ដុកស្ដម្ភទៅឃើញផ្ទះ របស់ជនម្នាក់ទៀតមានជាន់ទី៣យ៉ាងល្អឆើត គាត់ក៏កើតចិត្តចង់ឲ្យគេសង់ផ្ទះមួយមានជាន់ទី៣ ល្អដូចរបស់ជនម្នាក់ទៀតនោះដែរ។ គាត់ឲ្យគេហៅជាងធ្វើផ្ទះមក ហើយបង្គាប់ឲ្យសង់ជាន់ទី៣មួយឲ្យគាត់។ ជាងធ្វើផ្ទះទទួលយល់ព្រម ចាប់ផ្ដើមចាក់គ្រឹះជាដំបូងស្ថាបនាជាន់ទី១ រួចហើយសង់ជាន់ទី២ ហើយជាចុងក្រោយបង្អស់សង់ជាន់ទី៣។ នៅពេលដែលអ្នកមានស្ដុកស្ដម្ភឃើញការសង់ផ្ទះរបៀបនេះ គាត់ខឹងច្រឡោតឡើង ហើយស្រែកថា: «អញមិនត្រូវការគ្រឹះ ជាន់ទី១ និងជាន់ទី២ នោះទេ ! អ្វីដែលអញចង់បាន គឺជាន់ទី៣ យ៉ាងល្អឆើតមួយតែប៉ុណ្ណោះ ចូរសង់ឲ្យអញភ្លាមមក ! » ។

មនុស្សឆ្កួត គិតតែពីលទ្ធផលមួយមុខប៉ុណ្ណោះ គេគ្មាន

គិតដល់ការខំប្រឹងប្រែងជាចាំបាច់ ដើម្បីទៅដល់លទ្ធផលនោះទេ ព្រោះមនុស្សបែបនេះ ខ្វះក្តីអំណត់។ គ្មានការប្រសើរណាកើតដោយឯង ៗ ដោយអត់បានធ្វើការខំប្រឹងប្រែងនោះទេ បើពុំនោះទេ គឺដូចជាគេចង់សង់ជាន់ទី៣ ដោយអត់បានចាក់គ្រឹះសង់ជាន់ទី១ និងជាន់ទី២ ជាបន្តបន្ទាប់ដូច្នោះដែរ។

8. កាលមួយនោះ មានបុរសលេលាម្នាក់ ដាំរំងាស់ទឹកឃ្មុំ។ មិត្តរបស់គេម្នាក់មកដល់ បុរសលេលានោះនឹកចង់ឲ្យមិត្តផឹកទឹកឃ្មុំ។ តែទឹកឃ្មុំវាក្តៅពេក បុរសលេលាក៏តាំងផ្លុំដើម្បីឲ្យបានត្រជាក់ដោយមិនបានយកទឹកឃ្មុំចេញពីភ្លើងទេ។ ភាពត្រជាក់ត្រជុំនៃគតិបណ្ឌិតក៏ដូច្នោះដែរ គេមិនអាចទទួលបាននូវគតិបណ្ឌិតដ៏ត្រជាក់នោះទេ បើគេមិនពន្លត់ភ្លើងនៃតណ្ហាលោកិយជាមុនសិននោះទេ។

9. ម្តងនោះ មានបិសាចពីររូបឈ្លោះប្រកែកគ្នាមួយថ្ងៃវាល់ល្ងាច ដណ្តើមគ្នាយកប្រអប់មួយ ដំបងមួយ និងស្បែកជើងមួយគូ។ មានបុរសម្នាក់ដើរកាត់តាមទីនោះ សួរទៅថា: «ហេតុ

អ្វីក៏លោកឈ្លោះប្រកែកគ្នា ដោយសាររបស់អស់ទាំងនេះ ? តើរបស់អស់ទាំងនេះ មានឥទ្ធិពលទិព្វដូចម្ដេចដែរ បានជាលោកដណ្ដើមគ្នាដូច្នេះ ? » ។

បិសាចពន្យល់ទៅបុរសនោះថា ប្រអប់ទិព្វនេះអាចផ្ដល់វត្ថុគ្រប់បែបយ៉ាងដែលប្រាថ្នាចង់បាន ដូចជាចំណីអាហារ សម្លៀកបំពាក់ សម្បត្តិទ្រព្យ ជាដើម។ ដំបងទិព្វនេះ មានឥទ្ធិ-ឫទ្ធិអាចបង្ក្រាបសត្រូវគ្រប់ទិសទីបាន។ ហើយស្បែកជើងទិព្វមួយគូនេះ អាចពាក់ហោះហើរលើអាកាសបាន។

ឮសេចក្ដីនេះហើយ បុរសនោះស្រដីថា: «តើលោកទាស់គ្នាធ្វើអ្វី បើលោកចេញពីទីនេះតែមួយភ្លែត ខ្ញុំអាចធ្វើការបែងចែករបស់ទាំងនេះដល់លោកដោយយុត្តិធម៌»។ បិសាចទាំងពីរក៏ថយចេញឆ្ងាយបន្តិចទៅ។ ភ្លាមនោះបុរសក៏ពាក់ស្បែកជើងទិព្វ ឆក់យកប្រអប់និងដំបងទិព្វ ហើយស្ទុះហោះទៅលើអាកាសាបាត់ទៅ។

បិសាចទាំងពីរនោះ តំណាងពួកអ្នកកាន់សាសនាផ្សេងពីព្រះពុទ្ធសាសនា។ ប្រអប់ទិព្វតំណាងទេយ្យទាន ដែលកើតមានឡើងនៅក្នុងចិត្តប្រកបដោយសប្បុរសធម៌ មនុស្សលោក

មិនយល់ថា តើកំណាប់ទ្រព្យដ៏ច្រើនប៉ុនណា ដែលហូរចេញពីទេយ្យទានប្រកបដោយចិត្តសប្បុរសនេះទេ។ ដំបងទិព្វ តំណាងការព្យាយាមសង្រួមចិត្តៈ មនុស្សលោកមិនយល់ថា គឺដោយសារការព្យាយាមសង្រួមចិត្តនេះហើយ ដែលគេអាចបង្ក្រាបតណ្ហាលោកិយទាំងអស់បាន។ ស្បែកជើងទិព្វមួយគូនោះ តំណាងវិន័យល្អបរិសុទ្ធនៃគំនិតនិងចរិយា ដែលជាយានដឹកនាំសត្វលោកឲ្យផុតពីចំណង់ និងជម្លោះទាស់ទែងទាំងឡាយ។ ដោយមិនយល់នូវសេចក្តីទាំងនេះ មនុស្សលោកឈ្លោះប្រកែកគ្នាដណ្តើមយកប្រអប់ទិព្វ ដំបងទិព្វ និងស្បែកជើងទិព្វ។

10. កាលមួយនោះ មានបុរសម្នាក់ធ្វើដំណើរម្នាក់ឯង ទៅដល់ផ្ទះមួយគ្មានមនុស្សនៅ ក៏សម្រេចចិត្តចូលដេកក្នុងផ្ទះនោះ ដល់ពាក់កណ្តាលអធ្រាត្រ មានបិសាចមួយលីសពមួយ ចូលមកក្នុងផ្ទះនោះ ហើយដាក់សពទៅលើរនាបផ្ទះ។ បន្តិចមកទៀត មានបិសាចមួយទៀតចូលមក ហើយទាមទារខ្មោចនោះថាជារបស់ខ្លួន។ បិសាចទាំងពីរក៏ចាប់ឈ្លោះប្រកែកគ្នា។

បិសាចទី១ ស្តីឡើងថា ឈ្លោះគ្នាបន្តយូរទៅទៀតជាការ

ឥតប្រយោជន៍ហើយស្នើថា គួរតែរកចៅក្រមកាត់សេចក្តីឲ្យ តើខ្មោចនេះជារបស់អ្នកណា?។ បិសាចទី២យល់ព្រម ក្រឡេក ទៅឃើញបុរសដេកនៅកៀនជញ្ជាំង ក៏ស្នើសុំឲ្យបុរសនោះ កាត់សេចក្តីឲ្យ។ បុរសមានសេចក្តីភិតភ័យជាខ្លាំង ដោយគិត ថា: «ទោះបីអញកាត់ក្តីបែបណាក៏ដោយ ក៏បណ្តាលឲ្យបិសាច ដែលចាញ់ខឹងជាប្រាកដ។ វានឹងសងសឹកអញហើយសម្លាប់ អញជាមិនខាន»។ បុរសក៏ដាច់ចិត្តនិយាយការពិត ដែលគាត់ បានឃើញនឹងភ្នែក។

ឃើញថាជាការអត់អំពើ បិសាចទី២ ខឹងច្រឡោតឡើង ហើយចាប់កន្ត្រាក់ដៃបុរសម្ខាងរបេះចេញអំពីដងខ្លួនទៅ។ តែបិសាចទី១ យកដៃខ្មោចមកដាក់ជំនួសឲ្យវិញ។ បិសាច ដែលច្រឡោតខឹងចាប់យកដៃបុរសម្ខាងទៀត បិសាចទី១ យកដៃខ្មោចម្ខាងទៀត មកដាក់ជំនួសឲ្យភ្លាមមួយរំពេច ទៀត។ ការនេះចេះតែប្រព្រឹត្តិទៅជាបន្តបន្ទាប់រហូតដល់ ដៃទាំងពីរ ជើងទាំងពីរ ក្បាល និងដងខ្លួននៃបុរសត្រូវបាន ដាក់ជាជំនួសដោយអវយវៈរបស់ខ្មោច។ បន្ទាប់មកបិសាច ទាំងពីរឃើញអវយវៈបុរសនៅរាត់រាយពេញលើរនាប

ក៏ស្ទុះទៅរើសស៊ីអស់ ហើយសើចតិចៗដើរចេញបាត់ទៅ។

បុរសកំសត់ដែលជ្រកក្នុងផ្ទះឥតមនុស្សនៅនោះ មានចិត្តញាប់ញ័រជាខ្លាំងនឹងសំណាងអាក្រក់របស់ខ្លួន។ អវយវៈទាំងឡាយដែលបិសាចស៊ីអស់ទៅនោះ ជាអវយវៈដែលមាតាបិតាបានចែកឲ្យ តែអវយវៈដែលជាប់នឹងខ្លួនក្នុងពេលនេះ ជាអវយវៈរបស់ខ្មោចៗ ទីបំផុតទៅតើខ្លួនជានរណា ? បុរសដោះស្រាយរឿងនេះពុំរួច ទៅជាមនុស្សឆ្កួតលេលាដើរវង្វេងវង្វាន់ចេញពីផ្ទះនោះទៅ។ បុរសដើរតម្រង់ទៅវិហារមួយ ចូលទៅក្នុងវិហារ ហើយថ្លែងរឿងទុក្ខព្រួយប្រាប់ទៅបព្វជិតទាំងឡាយ ដែលគង់ក្នុងវិហារ។ បុគ្គលទាំងឡាយអាចយល់ន័យពិត អំពីភាពគ្មានអាត្មាអញ តាមដោយរឿងនិទាននេះ។

11. កាលមួយនោះ មានស្រីស្រស់ប្រិមប្រិយស្លៀកពាក់ស្អាតបាតម្នាក់ ចូលទៅលេងផ្ទះគេមួយ។ ម្ចាស់ផ្ទះសួរទៅស្រីនោះថា នាងស្រីជានរណា? ស្រីកញ្ញាឆ្លើយថា ខ្ញុំជាទេពធីតានៃ

សម្បត្តិទ្រព្យ។ ម្ចាស់ផ្ទះត្រេកអរជាអនេក ហើយទទួលស្រីកញ្ញាយ៉ាងរាក់ទាក់។

បន្តិចក្រោយមកទៀត មានស្រីម្នាក់ទៀតអាក្រក់គួរខ្លាចស្លៀកពាក់រយីករយាក ដើរចូលមក។ ម្ចាស់ផ្ទះសួរទៅស្រីនោះថា អ្នកឯងជានរណាដែរ ? ។ ស្រីនោះឆ្លើយថា ខ្ញុំជាទេពធីតានៃសេចក្ដីក្រខ្សត់។ ម្ចាស់ផ្ទះភ័យជាខ្លាំង ហើយល្បួងបណ្ដេញស្រីនោះឲ្យចេញពីផ្ទះ។ ប៉ុន្តែស្រីនោះពុំព្រមចេញថែមទាំងនិយាយថា:«ទេពធីតានៃទ្រព្យសម្បត្តិត្រូវជាបងស្រីខ្ញុំ។ យើងបានសន្យាគ្នាថា នឹងមិននៅបែកគ្នាជាដាច់ខាត។ បើអ្នកបណ្ដេញខ្ញុំ បងស្រីខ្ញុំត្រូវតែទៅជាមួយនឹងខ្ញុំដែរ»។ យ៉ាងជាក់ស្ដែង គ្រាន់តែស្រីរូបអាក្រក់ចេញផុតទៅ ស្រីរូបល្អក៏បាត់រូបទៅដែរ។

ការកើតទៅជាមួយនឹងការស្លាប់។ សំណាងល្អទៅជាមួយនឹងសំណាងអាក្រក់។ វត្ថុអាក្រក់ដើរតាមវត្ថុល្អជានិច្ចកាល។ បុគ្គលគ្រប់រូបត្រូវតែដឹងយល់រឿងនេះ។ មនុស្សឆ្កួតលេលាខ្លាចសំណាងអាក្រក់ ហើយរត់តាមសំណាងល្អ។ ប៉ុន្តែបុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹងត្រូវតែឈ្នះនូវសំណាងអាក្រក់ និងសំណាង

ល្អនេះ ហើយចាកផុតពីគ្រប់ចំណង់លោកិយទាំងអស់។

12. សម័យមួយនោះ មានវិចិត្រករក្រខ្សត់ម្នាក់ចាកចោលប្រពន្ធនិងផ្ទះសម្បែង ដើម្បីស្វែងរកទ្រព្យ។ ក្រោយពីការខិតខំយ៉ាងលំបាកអស់បីឆ្នាំមក វិចិត្រករកំសត់សន្សំបានកាសមាសបីរយសន្លឹក ហើយសម្រេចចិត្តត្រឡប់មកផ្ទះវិញ។ មកដល់ពាក់កណ្ដាលផ្លូវ គាត់ប្រទះនឹងវត្តធំមួយ គេកំពុងតែធ្វើបុណ្យដាក់ទាន។ គាត់ជាប់អារម្មណ៍ជាខ្លាំង ហើយគិតក្នុងចិត្តថា:«មកទល់ពេលនេះ អញគិតតែអំពីបច្ចុប្បន្នកាល អញមិនដែលបានគិតអំពីសុភមង្គល ទៅអនាគតកាលសោះ ។ អញមកដល់កន្លែងល្អនេះ ជាសំណាងល្អរបស់អញហើយ។ អញត្រូវតែឆ្លៀតដាំបណ្ដុះគ្រាប់ពូជជាកុសលបុណ្យក្នុងពេលនេះ»។ គិតឃើញដូច្នោះហើយ គាត់ក៏ឲ្យប្រាក់ដែលសន្សំបានទាំងប៉ុន្មាន ទៅវត្តនោះអស់ទៅ ហើយត្រឡប់ទៅផ្ទះវិញគ្មានប្រាក់មួយកាក់សោះ។ មកដល់ផ្ទះប្រពន្ធជេរស្ដីគាត់ថា គ្មានរកបានប្រាក់សូម្បីមួយកាក់មកឲ្យ ដើម្បីចិញ្ចឹមជីវិតសោះ។ វិចិត្រករកំសត់ឆ្លើយថា ខ្ញុំរកបានកាសមាសជាច្រើន តែខ្ញុំបាន

ទុកនៅក្នុងទីកន្លែងប្រាកដល្អមួយ។ នៅពេលដែលប្រពន្ធបេះតែជំរឹតសួរឲ្យប្រាប់កន្លែងដែលគាត់លាក់ វិចិត្រករក៏ប្រាប់ត្រង់ថាគាត់បានប្រគេនទៅព្រះសង្ឃនៅក្នុងវត្តមួយអស់ទៅហើយ។

រឿងនេះបណ្តាលឲ្យប្រពន្ធខឹងច្រឡោត ដេរស្តីគ្រប់ចំពូក។ នៅទីបំផុត ប្រពន្ធយករឿងនេះទៅប្តឹងចៅក្រម។ នៅពេលចៅក្រមសួរចម្លើយ វិចិត្រករឆ្លើយថា ខ្លួនពុំបានប្រព្រឹត្តអំពើឆ្គួតលេលាទេ ពីព្រោះខ្លួនសន្សំប្រាក់មាសបាន ដោយសារការខំប្រឹងប្រែងតស៊ូដ៏លំបាកអស់ពេលជាយូរ ហើយខ្លួនមានបំណងយកមាសនេះ ធ្វើជាគ្រាប់ពូជសម្រាប់ជាសម្បត្តិអនាគត។ នៅពេលទៅដល់វត្តមួយ គាត់យល់ថា នៅកន្លែងនេះហើយ ដែលគាត់គួរតែបណ្តុះគ្រាប់ពូជសម្បត្តិអនាគតរបស់គាត់។ គាត់បន្ថែមទៀតថា: «កាលខ្ញុំប្រគេនមាសទៅព្រះសង្ឃខ្ញុំហាក់ដូចជាបានបោះបង់ចោលនូវសេចក្តីលោភលន់ និងសេចក្តីកំណាញ់ ដែលមាននៅក្នុងចិត្តខ្ញុំនៅពេលជាមួយគ្នានោះ។ ខ្ញុំបានយល់ឃើញថា សម្បត្តិពិតប្រាដកពុំមែនមាសនោះទេ គឺចិត្តនោះឯងតែម្តង»។

ចៅក្រមសរសើរការយល់ត្រូវរបស់វិចិត្រករ ហើយអ្នក

ទាំងឡាយដែលបានស្តាប់ឮសេចក្តីនេះ ក៏យល់ស្របតាមហើយ ជួយជ្រោមជ្រែងវិចិត្រករនោះគ្រប់ចំពូក។ ដោយសារហេតុនេះវិចិត្រករនិងប្រពន្ធ ក៏បានសម្បត្តិល្អជានិច្ចនិរន្តរ៍តទៅ។

13. បុរសម្នាក់រស់នៅជិតកន្លែងកប់ខ្មោច នាយប់ស្ងាត់មួយនោះ បានឮសំឡេងស្រែកហៅខ្លួនចេញពីផ្នូរមួយមក។ គាត់ខ្លាចពេកពុំហ៊ានទៅមើលឲ្យដឹងរឿងទេ។ ព្រឹកស្អែកឡើងគាត់យករឿងនោះទៅប្រាប់មិត្តក្លាហានរបស់គាត់ម្នាក់។ មិត្តនោះប៉ងនឹងទៅមើលកន្លែងដែលបុរសតំណាលប្រាប់ ដើម្បីស្តាប់សំឡេងខ្មោចស្រែកហៅ នៅយប់បន្ទាប់។

នៅពេលដែលបុរសកំសាកកំពុងតែភ័យញាក់ មិត្តរបស់គាត់ទៅកន្លែងកប់ខ្មោចនាយប់បន្ទាប់នោះ ហើយឮសំឡេងស្រែកហៅ ចេញពីផ្នូរមួយមកប្រាកដមែន។ បុរសជាមិត្តសួរទៅថា អ្នកជាអ្វី ហើយចង់បានអ្វី។ សំឡេងចេញពីក្នុងដីមកថា «ខ្ញុំជាកំណប់ដែលគេកប់លាក់ទុកជាយូរមកហើយ ហើយខ្ញុំសម្រេចចិត្តផ្តល់ខ្លួនខ្ញុំនេះឲ្យទៅជនណាម្នាក់។ ពីយប់មុន ខ្ញុំបានធ្វើអំណោយខ្លួនខ្ញុំនេះដល់បុរសម្នាក់ តែបុរសនោះកំសាក

ពេក មិនហ៊ានមកយកដោយខ្លួនឯង ហេតុដូច្នេះ អ្នកត្រូវបាន កំណាប់នេះ ពីព្រោះអ្នកស័ក្តិសមនឹងបានកំណាប់។ ស្អែកព្រឹក ខ្ញុំនឹងទៅផ្ទះអ្នកជាមួយនឹងអ្នកបម្រើរបស់ខ្ញុំប្រាំពីរនាក់»។

បុរសជាមិត្តនិយាយថា: «ខ្ញុំនឹងរង់ចាំអ្នក ប៉ុន្តែសុំមេត្តា ប្រាប់ខ្ញុំ តើខ្ញុំត្រូវរៀបចំទទួលអ្នករបៀបដូចម្ដេច?»។ សំឡេង ឆ្លើយឡើងថា: «យើងនឹងទៅផ្ទះអ្នកក្នុងសម្លៀកបំពាក់ជាបព្វជិត។ ចូររៀបចំបន្ទប់មួយ និងទឹកទុកឲ្យយើង។ ចូរអ្នកដុស លាងខ្លួនប្រាណរបស់អ្នក ហើយបោសច្រាសបន្ទប់នោះឲ្យ ស្អាត។ ចូររៀបកៅអីនិងបាយប្រាំបីចានទុកឲ្យយើង។ ក្រោយ ពេលយើងបរិភោគរួច ចូរអ្នកនាំយើងទៅក្នុងបន្ទប់បិទជិតមួយ។ នៅក្នុងបន្ទប់នោះ យើងនឹងប្រែខ្លួនយើងឲ្យទៅជាក្អមប្រាំបី ពេញទៅដោយមាស»។

ព្រឹកស្អែកឡើង បុរសជាមិត្តនោះបោសច្រាសបន្ទប់ដូច បានទទួលបញ្ជាមក រួចហើយរង់ចាំបព្វជិតទាំងប្រាំបីអង្គនិមន្ត មកដល់។ សង្ឃទាំងប្រាំបីអង្គនិមន្តមកដល់ តាមពេលសន្យា។ បុរសនោះទទួលដោយសេចក្តីគោរព។ ក្រោយពេលឆាន់ចង្ហាន់ រួច បុរសនិមន្តបព្វជិតទាំងនោះមួយអង្គម្តងៗទៅក្នុងបន្ទប់បិទ

ជិតមួយៗ បព្វជិតគ្រប់អង្គ ក៏ប្រែខ្លួនក្លាយទៅជាក្អមពោរពេញទៅដោយមាសៗ

កាលនោះ នៅក្នុងភូមិនោះ មានបុរសម្នាក់លោភលន់ជាពន់ពេកៗ នៅពេលគាត់បានដឹងរឿងនោះ គាត់នឹកចង់បានក្អមពោរពេញដោយមាសទាំងនោះដែរៗ គាត់ក៏និមន្តបព្វជិតប្រាំបីអង្គនោះទៅផ្ទះគាត់ៗ នៅពេលឆាន់រួចសព្វគ្រប់ហើយ បុរសលោភលន់នាំបព្វជិតទាំងនោះ ទៅក្នុងបន្ទប់បិទជិតមួយៗ ប៉ុន្តែបព្វជិតទាំងនោះ មិនព្រមប្រែរូបឲ្យទៅជាក្អមពេញដោយមាសទេ ទៅជាច្រឡោតខឹង ហើយនាំគ្នាទៅប្ដឹងក្រុមរក្សាសន្តិសុខៗ ទីបំផុត ក្រុមរក្សាសន្តិសុខចាប់បុរសនោះទៅៗ

ចំណែកបុរសកំសាក នៅពេលបានដឹងថា សំឡេងដែលបន្លឺចេញពីផ្ទះ បានផ្ដល់សម្បត្តិស្ដុកស្ដម្ភដល់បុរសក្វាហានយ៉ាងនេះហើយ ដោយមានចិត្តលោភលន់ គាត់ក៏ទៅផ្ទះបុរសក្វាហាន ទាមទារយកមាសទាំងនោះ ដោយសំអាងថាសំឡេងនោះបានផ្ដោះមករកខ្លួនជាមុនៗ នៅពេលដែលគាត់ឈោងចាប់យកក្អមទាំងនោះ ពស់វែកជាច្រើនបើកវែក លូន

ចេញពីក្អមប្រុងនឹងចឹកគាត់។

ព្រះមហាក្សត្រទ្រង់ជ្រាបរឿងនេះ ក៏ដាក់បញ្ញត្តិថា ក្អមទាំងនោះជារបស់បុរសក្លាហាន។ ហើយព្រះអង្គទ្រង់ពិចារណាថា: «រឿងហេតុទាំងពួង វាតែងតែមានឡើងរបៀបនេះជានិច្ចនៅក្នុងលោកនេះ។ មនុស្សឆ្លួតលេលាពោរពេញទៅដោយចំណង់ ចង់បានប្រយោជន៍ តែកំសាកពេក ពុំហ៊ានខឹតខំស្វែងរក។ អាស្រ័យហេតុនេះ មនុស្សកំសាកទាំងនោះ តែងតែមិនបានសម្រេចជានិច្ច។ មនុស្សរបៀបនេះ ខ្វះទាំងជំនឿទុកចិត្ត ខ្វះទាំងសេចក្ដីក្លាហានក្នុងការតស៊ូតាមផ្លូវចិត្ត ដែលជាមធ្យោបាយតែមួយគត់ដើម្បីបានសម្រេចសេចក្ដីសុខសន្តិភាពពិតប្រាកដ»។

# ចំពូកទី ២

# វិធីប្រតិបត្តិឲ្យបានសម្រេច

## I

## ការស្វែងរកសេចក្តីពិត

1. *កាលណាគេស្វែងរកសេចក្តីពិត គេតែងតែប្រទះនឹងបញ្ហាដែលឥតប្រយោជន៍ទាល់តែសោះខ្ទះ ចោទឡើងជានិច្ច។ សកលលោកនេះធ្វើអំពីអ្វី? សកលលោកនេះឋិតថេរឬទេ? សកលលោកនេះ មានព្រំដែនឬទេ ឬគ្មានទេ? សង្គមមនុស្សលោកនេះ កើតឡើងតាមរបៀបដូចម្តេច? អ្វីទៅដែលជាអង្គការប្រសើរឧត្តមនៃសង្គមមនុស្សលោក?។ បើបុគ្គលណាមួយរង់ចាំរកឲ្យឃើញចម្លើយ ចំពោះបញ្ហាទាំងនេះជាមុនសិន ទើបបានចាប់ស្វែងរក និងប្រតិបត្តិដើម្បីទៅកាន់ពន្លឺត្រាស់ដឹង បុគ្គលនោះនឹងស្លាប់មុនរកឃើញផ្លូវនោះជាពុំខាន។*

*ឧបមាថា បុរសម្នាក់ត្រូវព្រួញពិស ជាប្រាកដណាស់*

មុខតែឪពុកម្ដាយ មិត្តភក្តិរបស់គេមកជុំគ្នា ហើយអញ្ជើញគ្រូពេទ្យមកដកព្រួញចេញ ថែមុខរបួស បន្សាបពិស។

បើសិនជាអ្នករបួសប្រកែកថា: «សុំចាំបន្តិចសិន! មុននឹងលោកដកព្រួញនេះ ខ្ញុំចង់ដឹងថា តើនរណាបាញ់ខ្ញុំ?។ តើអ្នកបាញ់នោះ ប្រុសឬស្រី តើជាអភិជន ឬអ្នកស្រែចំការ។ តើធ្នូធ្វើអំពីអ្វី តើធ្នូតូច ឬធ្នូធំ តើធ្វើអំពីឈើ ឬអំពីឫស្សី តើខ្សែធ្នូធ្វើអំពីអ្វី តើធ្វើអំពីសរសៃឈើ ឬស្បែកសត្វ តើព្រួញធ្វើអំពីផ្ដៅ ឬអំពីស្រល់។ តើគេយកស្លាបសត្វអ្វីប្រើ។ មុននឹងលោក ដកព្រួញនេះ ខ្ញុំចង់ដឹងសេចក្ដីទាំងនេះសិន»។ ក្នុងកាលៈទេសៈបែបនេះ តើបុរសនោះនឹងទៅជាយ៉ាងណា?

មុននឹងបានដំណឹងពិតឥតស្មៀងទាំងនោះ ពិសមានពេលគ្រប់គ្រាន់នឹងបញ្ចេញសកម្មភាព ហូរចូលទៅក្នុងសរសៃឈាម អាចបណ្ដាលឲ្យបុរសនោះស្លាប់បាន។ ករណីមុនដំបូង ដែលត្រូវធ្វើគឺដកយកព្រួញចេញ ហើយបង្ខាំងពិសកុំឲ្យជ្រួតជ្រាបសព្វសាយទាន់។

ក្នុងពេលដែលភ្លើងតណ្ហាកំពុងតែធ្វើឲ្យលោកនេះ មានគ្រោះថ្នាក់ ការរកឲ្យដឹងថា តើលោកនេះកើតឡើងអំពីអ្វី ជា

ការបានប្រយោជន៍តិចតួចស្តួចស្តើងណាស់។ ហេតុនេះ ការរកឲ្យយល់នូវសភាពជាក់លាក់ នៃសង្គមមនុស្សលោកនោះ មិនបានប្រយោជន៍ស្មើនឹងការរត់គេចពីភ្លើង ដែលកំពុងឆេះនោះទេ។

រឿងរកឲ្យដឹងថា តើលោកនេះមានព្រំដែនឬទេ តើឋិតថេររហូតឬទេនោះ អាចរង់ចាំបានរហូតដល់ពេលរកឃើញមធ្យោបាយរំលត់ភ្លើងនៃការកើត ជរា ឈឺ និងស្លាប់។ នៅចំពោះមុខភ្លើងទុក្ខព្រួយ ភ្លើងឈឺចាប់ ភ្លើងវេទនា ជាដំបូងបង្អស់ត្រូវរកឲ្យឃើញផ្លូវរំលត់ភ្លើងទាំងនោះ ហើយតាំងចិត្តប្រតិបត្តិតាមផ្លូវនោះ។

សាសនាព្រះពុទ្ធ ពន្យល់យើងអំពីរឿងមានប្រយោជន៍ដែលយើងត្រូវតែដឹង មិនពន្យល់អំពីរឿងអត់ប្រយោជន៍ទេ។ បានន័យថា យើងត្រូវរៀនអ្វីដែលត្រូវរៀន លះបង់អ្វីដែលត្រូវលះបង់ បណ្តុះបណ្តាលអ្វីដែលត្រូវបណ្តុះបណ្តាល ទទួលចំណេះវិជ្ជាអ្វីដែលត្រូវទទួល។

ហេតុដូច្នេះ មុនដំបូងបុគ្គលគ្រប់រូបត្រូវយល់នូវរឿងដែលសំខាន់ជាងគេបំផុត យល់នូវបញ្ហាទាំងឡាយដែលត្រូវ

ដោះស្រាយជាដំបូងគេបំផុត ហើយយល់នូវបញ្ហាដែលបន្ទាន់ជាងគេបង្អស់។ ដើម្បីកិច្ចនេះ ជាដំបូងបង្អស់ បុគ្គលគ្រប់រូបចាំបាច់ត្រូវតែព្យាយាមហាត់បំពត់ចិត្តរបស់ខ្លួន គឺជាត្រូវបេះគ្រប់គ្រងចិត្តគំនិតរបស់ខ្លួន។

2. ឧបមាថា មានបុរសម្នាក់ចូលទៅក្នុងព្រៃ ដើម្បីរកជ័រឈើដែលមាននៅក្នុងដើមរុក្ខជាតិ តែបុរសនោះកាប់យកបានតែមែកនិងស្លឹកមួយបាច់ត្រឡប់មកផ្ទះវិញ ហើយជឿក្នុងចិត្តថាខ្លួនរកបានរបស់ដែលខ្លួនស្វែងរក។ តើបុរសនោះមិនឆ្កួតទេឬ? ដែលសប្បាយចិត្តនឹងបានសំបកឈើ សាច់ឈើស្រាយៗជាជំនួសជ័រឈើ ដែលខ្លួនចេញទៅរកនោះ? ប៉ុន្តែ មានមនុស្សជាច្រើន ដែលតែងតែធ្វើរបៀបនេះ!។

ដូចជាបុរសម្នាក់ស្វែងរកផ្លូវដើម្បីឲ្យបានចាកផុតពីការកើត ការចាស់ជរា ការឈឺ ការស្លាប់ ការទុក្ខព្រួយ ការឈឺចាប់និងការវេទនា។ នៅពេលសម្គាល់ឃើញថា ខ្លួនបានជឿនលឿនទៅមុខខ្លះហើយនោះ ក៏តាំងកើតចិត្តឡើត ក្រអឺតក្រអោងឡើងអំនួត វាយឫកធំ។ បុរសនោះ មិនខុសពីបុរសដែលស្វែង

រកជ័រឈើ ហើយសប្បាយចិត្តដោយរកបានមែកឈើនិងស្លឹកមួយបាច់នោះទេ។

មានបុរសម្នាក់ទៀតត្រេកអរសប្បាយ ដោយបានលូតលាស់ខ្លះក្រោយពីខ្លួនបានខំប្រឹងប្រែងបន្តិចបន្តួចមក ហើយតាំងលះបង់ចោលការខំប្រឹងប្រែង ទៅជាមានចិត្តភ្លើតភ្លើនក្រអឺតក្រអោង ឡើងអំនួត។ អាចប្រដូចបានថា បុរសនោះទៅរកបានឯមែកឈើមួយបាច់ ជាជំនួសជ័រឈើ ដែលខ្លួនស្វែងរកនោះទៅវិញ។

មានបុរសម្នាក់ទៀត ឃើញថាចិត្តរបស់ខ្លួនបានស្ងប់បន្តិចហើយៗ គំនិតរបស់ខ្លួនបានភ្លឺថ្លាខ្លះហើយ ក៏តាំងលះបង់ការព្យាយាមចោល ហើយទៅជាក្រអឺតក្រអោង ឡើងអំនួត។ បុរសនោះយកបានឯសំបកឈើ ជាជំនួសជ័រឈើ ដែលខ្លួនស្វែងរកនោះទៅវិញ។

មានបុរសម្នាក់ទៀត ឡើងចិត្តឡឹតអួតអាងដោយសារបានដឹងថា ខ្លួនបានមើលឃើញជម្រៅនៃវត្ថុជាតុខ្លះៗហើយ ។ នេះដូចជាទៅបានឯសាច់ឈើស្រាយៗ ជាជំនួសជ័រឈើដូច្នេះដែរ។ អ្នកសង្វាតរកទាំងនេះ ដែលពេញចិត្តនឹងការព្យាយាម

មិនគ្រប់គ្រាន់ ហើយតាំងឡើងអំនួត មានចិត្តក្រអឺតក្រអោង លះបង់ការព្យាយាមចោល ហើយបណ្តោយខ្លួនឲ្យធ្លាក់យ៉ាងងាយទៅក្នុងភាពទំនេរខ្ជិលច្រអូស។ បុគ្គលទាំងនោះនឹងបានជួបប្រទះនឹងទុក្ខវេទនាវិញ ជាពុំខាន។

អ្នកស្វែងរកផ្លូវពិតប្រាកដទៅកាន់ពន្លឺត្រាស់ដឹង មិនត្រូវគិតសង្ឃឹមលើការងាយស្រួល លើការដែលនឹងត្រូវតែបានគេគោរព ឬលើកកិត្តិយស និងភក្តីភាពដែលគេត្រូវតែផ្តល់ឲ្យនោះទេ។ ម្យ៉ាងទៀតក្នុងការប្រាថ្នារកសេចក្តីសុខស្ងប់ រកការត្រាស់ដឹងនេះ គេមិនត្រូវព្យាយាមដោយខ្ជីខ្ជាទេ។

មុនដំបូងបង្អស់ គេត្រូវយល់ក្នុងចិត្តឲ្យច្បាស់អំពីសភាពពិតដែលជាគ្រឹះសំខាន់នៃពិភពកើតនិងស្លាប់នេះ។

3. លោកនេះ គ្មានសារជាតិឋិតថេរជារបស់ខ្លួនពិតប្រាកដទេ។ វាគ្រាន់តែជាការប្រមូលផ្តុំដ៏ធំធេងមួយនៃហេតុនិងផលតែប៉ុណ្ណោះ។ ហើយហេតុនិងផលនេះទៀត មានដើមកំណើតពីសកម្មភាពទាំងឡាយនៃចិត្ត ដែលបណ្តាលមានឡើងដោយសារសេចក្តីល្ងង់ខ្លៅ ការរមិលឃើញខុស ការចង់បាន ហើយ

និងការដំពាក់ចិត្ត។ លោកនេះ គឺជារូបបញ្ចាំងនៃគំនិតយល់ខុស ដែលស្ថិតមាននៅក្នុងចិត្តៈ វាគ្មានសារជាតិអ្វីជាប្រាកដមួយឡើយ។ គឺដោយសារដំណើរនៃចិត្តនោះឯង ដែលពិភពលោកនេះកើតមានឡើង។ ចិត្តបញ្ចាំងនូវគតិភាន់ច្រឡំរបស់ខ្លួនផ្ទាល់។ ពិភពលោកនេះ មានគ្រឹះនៅក្នុងចំណង់ទាំងឡាយនៃចិត្ត នៅក្នុងក្ដីទុក្ខសោកកង្វល់ដែលកើតឡើងពីចំណង់កំហឹង និងគតិភាន់ច្រឡំ។ បុគ្គលស្វែងរកផ្លូវពន្លឺត្រាស់ដឹង ត្រូវតែប្រុងប្រៀបខ្លួនប្រយុទ្ធតទល់នឹងចិត្តរបៀបនេះ ដើម្បីនឹងបានទៅដល់គោលដៅ។

4. ឱចិត្តរបស់ខ្ញុំ! ម្ដេចក៏អ្នកហោះហើរមិនចេះឈប់ឈរនៅក្នុងដំណើរប្រែប្រួលនៃជីវិតដូច្នេះ? ម្ដេចក៏អ្នកធ្វើឲ្យខ្ញុំច្របូកច្របល់ រកពេលសម្រាកគ្មានដូច្នេះ? ម្ដេចក៏អ្នកបង្ខំខ្ញុំឲ្យប្រមូលទុកនូវវត្ថុដ៏ច្រើនមហិមាយ៉ាងនេះ? អ្នកបីដូចជានង្គ័លដែលបាក់មុនគេចាប់ផ្ដើមភ្ជួរដី អ្នកបីដូចជាចង្កូតកប៉ាល់ដែលគេដោះបោះចោលនៅពេលដែលគេកំពុងតែ រង្វើងរង្វាន់នាកណ្ដាលមហាសមុទ្រនៃការកើតនិងការស្លាប់។ តើបានប្រយោជន៍អ្វីទៅ

ក្នុងការកើតឡើងវិញជាច្រើនដងរាប់មិនអស់នេះ បើអ្នកមិនចេះប្រើប្រាស់ជីវិតនេះឲ្យបានប្រយោជន៍ល្អ?។

ឱចិត្តរបស់ខ្ញុំ ! ម្តងអ្នកបណ្តាលឲ្យខ្ញុំទៅកើតជាស្តេចផែនដី រួចហើយអ្នកបណ្តាលឲ្យខ្ញុំទៅកើតជាអ្នកងារ ដើរសុំទានគេស៊ី។ ជួនកាលអ្នកបណ្តាលឲ្យខ្ញុំទៅកើតនៅក្នុងឋានសួគ៌ សោយសម្បត្តិទិព្វរួចហើយ អ្នកទម្លាក់ខ្ញុំទៅក្នុងឋាននរកដ៏សែនជ្រៅ។

ឱចិត្តចម្លួតរបស់ខ្ញុំ ! ឆ្លួតគ្មានសល់ចន្លោះ ! អ្នកបានដឹកនាំឲ្យដើរតាមផ្លូវដ៏ច្រើនរាប់មិនអស់ ហើយខ្ញុំបានគោរពធ្វើតាមអ្នកដោយគ្មានរើសរូស ! តែពេលនេះ ខ្ញុំបានស្តាប់ឮសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធហើយ សូមឈប់ធ្វើឲ្យខ្ញុំរឹករវទៀតទៅ ឈប់ធ្វើឲ្យខ្ញុំឈឺចាប់ទៀតទៅ សូមទុកឲ្យខ្ញុំមានខន្តីខំសង្វាតស្វែងរកពន្លឺត្រាស់ដឹងផង !

ឱ ចិត្តរបស់ខ្ញុំ ! បើអ្នកអាចដឹងតែម្យ៉ាងគត់ថា អ្វីៗទាំងអស់គ្មានសារជាតិទេ អ្វីៗទាំងអស់សុទ្ធតែមិនឋិតថេរ ! បើអ្នកអាចរៀនតែម្យ៉ាងគត់គឺ កុំទាក់ទាមនឹងវត្ថុ កុំប្រាថ្នាចង់បានវត្ថុ កុំបណ្តោយឲ្យលុះទៅក្នុងសេចក្តីលោភលន់ សេចក្តីខឹងក្រោធ

និងសេចក្តីឆ្គួតក្ងីក្ងើ ! ពេលនោះ យើងនឹងអាចមានដំណើរជីវិតសុខស្ងប់។ ដូច្នេះ បើយើងយកដាវនៃគតិបណ្ឌិត កាត់ផ្តាច់ចំណងនៃតណ្ហាទាំងឡាយ បើយើងលែងត្រូវបានរឹកររនឹងដំណើរប្រែប្រួលនៃកាលៈទេសៈ លែងទាក់ទាមនឹងការមានអត្ថប្រយោជន៍ ឬគ្មានអត្ថប្រយោជន៍ នឹងភាពល្អឬភាពអាក្រក់ នឹងការចំណេញឬខាត នឹងការបានគេសរសើរ ឬបានគេប្រមាថ យើងនឹងអាចរស់ក្នុងសុខសន្តិភាព។

ឱ ចិត្តជាទីស្រឡាញ់របស់ខ្ញុំ ! ជាដំបូងបង្អស់ អ្នកបានរំឭកដាស់តឿនខ្ញុំ ឲ្យមានជំនឿក្នុងការស្វែងរកពន្លឺត្រាស់ដឹង ចុះហេតុដូចម្តេច ក៏អ្នកបណ្តោយឲ្យសេចក្តីលោភលន់ ការស្រឡាញ់ភាពឧត្តុងឧត្តម្ភ ការស្រើបស្រាលសប្បាយរំជើបរំជួលវាចេញចូលបានដោយសេរី ងាយៗ យ៉ាងនេះ?

ឱ ចិត្តរបស់ខ្ញុំ ! ហេតុដូចម្តេចក៏អ្នកលោតទៅខាងនេះបន្តិច ខាងនោះបន្តិច គ្មានគោលដៅអ្វីឲ្យប្រាកដប្រជាដូច្នេះ? សូមទុកឲ្យខ្ញុំបានឆ្លងសមុទ្រថ្លីនក្អែកគួរឲ្យខ្លាចនេះរួចផង។ មកទល់ពេលនេះ ខ្ញុំបានប្រព្រឹត្តតាមដោយចំណង់របស់អ្នកទាំងអស់ តែឥឡូវនេះ គឺអ្នកឯងនេះហើយដែលត្រូវតែប្រព្រឹត្ត

តាមខ្ញុំម្តងវិញ គឺយើងទាំងអស់គ្នាត្រូវប្រតិបត្តិតាមសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ។

ឱ ចិត្តជាទីស្រឡាញ់របស់ខ្ញុំ ! ភ្នំទាំងនេះ ស្ទឹងទាំងនេះ សមុទ្រទាំងនេះ សុទ្ធតែប្រែប្រួល ហើយជាភពនៃទុក្ខ។ ដូច្នេះ នៅក្នុងពិភពថ្លឹងក្អែកនេះ តើយើងនឹងរកឃើញសេចក្តីសុខស្ងប់នៅកន្លែងណាទៅ ? យើងគួរតែដើរតាមគន្លងធម៌របស់ព្រះពុទ្ធ ហើយឆ្លងទៅត្រើយម្ខាងទៀតដែលជាត្រើយនៃពន្លឺត្រាស់ដឹង !

5. បុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹង ដោយពិតប្រាកដមែនន៎ះ គេតែងតែដាក់កម្រិតបញ្ញាចិត្តរបស់គេជានិច្ច។ ដូច្នេះ បុគ្គលទាំងនោះជឿនទៅមុខ ដោយប្តេជ្ញាចិត្តយ៉ាងស្វាហាប់។ ទោះបីគេត្រូវបានអ្នកខ្លះជេរប្រទេច អ្នកខ្លះទៀតប្រមាថមើលងាយក៏ដោយ ក៏គេបេះតែទៅមុខជានិច្ច ដោយមិនរឹករវឡប់ស្មារតី។ ទោះបីនរណាវាយតប់គេ យកដុំថ្មគប់គេឬយកដាវកាប់គេ បណ្តាលឲ្យមានរបួសក៏ដោយ ក៏គេមិនខឹងតបទៅវិញដែរ។

ទោះបីសត្រូវរបស់គេកាត់ក្បាលគេ ក៏ចិត្តរបស់គេមិនត្រូវបានរឹកររដែរ។ បើគេបណ្ដោយឲ្យចិត្តរបស់គេឡើងល្អក់ដោយសាររឿងដែលបណ្ដាលឲ្យឈឺចាប់ នោះគេមិនតាមសេចក្ដីប្រៀនប្រដៅរបស់ព្រះពុទ្ធទេ។ ទោះបីព្រឹត្តិការណ៍បែបណាមកដល់គេក៏ដោយ គេត្រូវតែប្ដេជ្ញាចិត្តឲ្យនៅម៉ឹងម៉ាត់មិនរំភើបញាប់ញ័រ ហើយផ្សព្វផ្សាយនូវចិត្តមានសេចក្ដីប្រណីអាសូរនិងមេត្តាធម៌ជានិច្ច។ ទោះបីត្រូវបានទទួលការប្រមាថឬជួបប្រទះនឹងសំណាងអាក្រក់ក៏ដោយ គេត្រូវតែសម្រេចចិត្តមិនតក់ស្លុត តាំងចិត្តឲ្យស្ងប់ គិតតែផ្ចិតយកនូវឱវាទរបស់ព្រះពុទ្ធ។

ក្នុងបំណងឲ្យបានសម្រេចពន្ធឺត្រាស់ដឹង អញនឹងខំបំពេញអ្វីៗដែលមិនអាចធ្វើបាន ទ្រាំទ្រនឹងអ្វីៗ ដែលពុំអាចទ្រាំបាន។ អញនឹងបូជាអ្វីៗទាំងអស់ ដែលអញមាន។ បើសិនជាមានគេថា ដើម្បីបានសម្រេចពន្ធឺត្រាស់ដឹង អញតោងតែដាក់កំហិតស៊ីបាយតែមួយគ្រាប់ក្នុងមួយថ្ងៃ នោះអញនឹងស៊ីបាយតែមួយគ្រាប់គត់ក្នុងមួយថ្ងៃ។ បើសិនជាផ្លូវទៅកាន់ពន្ធឺត្រាស់ដឹងនោះត្រូវឆ្លងកាត់ភ្លើង អញនឹងឆ្លងកាត់ភ្លើងនោះ។

ប៉ុន្តែគេមិនត្រូវធ្វើកិច្ចទាំងនេះ ក្នុងគោលបំណងណាមួយជាខាងក្រោយនោះទេ។ គេត្រូវគិតថា គេធ្វើកិច្ចទាំងនេះ ពីព្រោះវាប្រកបដោយគតិបណ្ឌិតគួរតែធ្វើ ពីព្រោះវាត្រឹមត្រូវល្អគួរតែធ្វើ។ គេត្រូវធ្វើកិច្ចទាំងនេះដោយចិត្តមានមេត្តាធម៌ប្រណីអាសូរ ដូចជាម្ដាយបំពេញកិច្ចទាំងឡាយចំពោះកូននៅតូច ចំពោះកូនដែលមានជំងឺ ដោយគ្មានគិតដល់កម្លាំងនឿយហត់ ឬសុខុមាលភាពរបស់ខ្លួន។

6. កាលមួយនោះ មានព្រះមហាក្សត្រមួយព្រះអង្គ ស្រឡាញ់ប្រជារាស្ត្រ និងប្រទេសជាតិរបស់ព្រះអង្គណាស់។ ព្រះអង្គគ្រប់គ្រងប្រទេសដោយគតិធម៌និងមេត្តាធម៌ជាទីបំផុត នាំឲ្យប្រទេសព្រះអង្គបានសុខសន្តិភាព ចម្រុងចម្រើនជាទីពន្លឹក។ ព្រះអង្គទ្រង់ស្វែងរកគតិបណ្ឌិត និងពន្លឺត្រាស់ដឹងជានិច្ច ព្រះអង្គរហូតដល់ទៅប្រកាសថា នឹងប្រទានរង្វាន់ដល់អ្នកណាដែលដឹកនាំព្រះអង្គទៅកាន់សិក្ខាបទ ដែលអាចឲ្យព្រះអង្គបានសម្រេច។

ភក្តីភាព និងគតិបណ្ឌិតរបស់ព្រះអង្គ ត្រូវបានដឹងដល់

ទៅព្រះឥន្ទ្រ។ ព្រះឥន្ទ្រក៏ចុះមកសាកល្បងព្រះអង្គដោយក្លែងខ្លួនជាបិសាច ប្រាកដឲ្យឃើញឡើងនៅមុខទ្វារប្រាសាទ។ បិសាចនោះសុំឲ្យគេនាំទៅគាល់ស្តេច ពីព្រោះខ្លួនមានសិក្ខាបទដ៏វិសេសបរិសុទ្ធមួយ នឹងទូលព្រះរាជាឲ្យទ្រង់ព្រះសណ្តាប់។

ព្រះរាជាឮដំណឹងនេះ ទ្រង់មានព្រះទ័យត្រេកអរជាពន់ពេក។ ព្រះអង្គទទួលបិសាចយ៉ាងគួរសម ហើយសុំឲ្យបិសាចបង្រៀនសិក្ខាបទនោះដល់ព្រះអង្គ។ បិសាចក៏ប្រែរូបទៅជាអសុរកាយគួរឲ្យខ្លាចជាពន់ពេក ហើយទាមទាររកចំណីអាហារស៊ី ដោយស្រដីថា វាមិនបង្រៀនជាដាច់ខាត ដរាបណាវាមិនបានទទួលចំណីអាហារដែលវាចង់ស៊ី។ ចំណីអាហារយ៉ាងវិសេសវិសាល ត្រូវបានរៀបថ្វាយបិសាច តែបិសាចនៅតែទទូចទារឲ្យគេយកសាច់មនុស្សនៅក្តៅស្រស់ និងឈាមស្រស់មកឲ្យខ្លួនស៊ី។ ព្រះរាជបុត្របម្រុងរាជ្យ រួចហើយព្រះអគ្គមហេសី បានថ្វាយខ្លួនជាបន្តបន្ទាប់ឲ្យបិសាចស៊ី តែបិសាចនៅតែមិនពេញចិត្ត ហើយវាសុំឲ្យស្តេចដាក់ទានអង្គកាយព្រះអង្គឲ្យវាស៊ី។

ព្រះរាជាទ្រង់យល់ព្រមថ្វាយខ្លួនព្រះអង្គឲ្យបិសាចស៊ី តែ

ទ្រង់ទាមទារសុំឲ្យព្រះអង្គអាចបានស្ដាប់សិក្ខាបទ ដ៏វិសេសវិសុទ្ធនោះជាមុនសិន។

ពេលនោះ ព្រះឥន្ទ្រទ្រង់ប្រកាសពាក្យប្រកបដោយគតិធម៌ថាៈ «ទុក្ខព្រួយមកពីចំណង់ ការខ្លាចមកពីចំណង់។ បុគ្គលដែលបានកំចាត់ចំណង់ចោលចេញ នឹងលែងមានទុក្ខព្រួយលែងមានការខ្លាច»។ ជាបន្ទាប់ភ្លាមនោះ ព្រះឥន្ទ្រក៏ប្រែកាឡាមកជារូបពិតវិញ ចំណែកឯព្រះរាជបុត្រ និងព្រះអគ្គមហេសីក៏រស់ឡើងវិញ។

7. កាលមួយនោះ នៅក្នុងព្រៃហិមពាន្ត មានបុរសម្នាក់ស្វែងរកផ្លូវទៅកាន់សេចក្ដីពិត។ បុរសនោះមិនរវល់នឹងសម្បត្តិលោកិយ ឬសេចក្ដីសប្បាយនៅឋានសួគ៌ ទាល់តែសោះ។ របស់ដែលគេស្វែងរក គឺសិក្ខាបទដែលអាចឲ្យគេបានចាកផុតពីសេចក្ដីភាន់វិញ្ញាណ តែមួយមុខប៉ុណ្ណោះ។

ព្រះឥន្ទ្រមានព្រះទ័យរំភើបនឹងការខំសង្វាត យ៉ាងម៉ឺងម៉ាត់ និងស្មោះត្រង់របស់បុរសនោះ ក៏ចុះមកសាកល្បងបុរស។ ទ្រង់កាឡាខ្លួនជាបិសាចមួយ ដើរស្រែកច្រៀងក្នុងព្រៃហិមពាន្ត

ថា: «អ្វីៗទាំងអស់ប្រែប្រួល អ្វីៗទាំងអស់កើតឡើងហើយវិនាសបាត់ទៅវិញ»។

ពេលដែលបុរសស្វែងរកសេចក្តីពិតឮចម្រៀងនោះ គេសប្បាយជាពន់ពេក។ គេសប្បាយហាក់ដូចជាមនុស្សស្រេកទឹកបានជួបប្រទះនឹងប្រភពទឹកត្រជាក់ ឬហាក់ដូចជាទាសកម្មករបានរួចខ្លួនជាអ្នកជា ដោយមិនដឹងខ្លួនជាមុន។ គេនិយាយតែម្នាក់ឯងថា: «ទីបំផុត អញបានរកឃើញសិក្ខាបទត្រឹមត្រូវពិតប្រាកដ ដែលអញបានខំស្វែងរកជាយូរណាស់មកហើយ!»។ គេដើរតាមសំឡេងចម្រៀងនោះ ហើយទៅដល់កន្លែងដែលបិសាចគួរខ្លាចនោះស្ថិតនៅ។ គេដើរចូលទៅជិតបិសាចដោយអារម្មណ៍មិននឹងន ហើយថ្លែងថា: «តើអ្នកឯងឬដែលច្រៀងចម្រៀងដែលខ្ញុំបានឮអម្បាញ់មិញ? សូមមេត្តាច្រៀងឲ្យខ្ញុំស្តាប់បន្តិចទៀតមក!»។

បិសាចឆ្លើយថា: «ពិតហើយ គឺយើងនេះហើយ ដែលបានច្រៀងអម្បាញ់មិញនេះ។ តែយើងមិនអាចច្រៀងតទៅទៀតបានទេ បើយើងមិនបានបរិភោគចំណី ព្រោះយើងឃ្លានពេកណាស់ ! » ។

បុរសអង្វរបិសាចហើយអង្វរទៀត សុំឲ្យច្រៀងបន្តទៅទៀត។ គេនិយាយថា:«ចម្រៀងនោះ មានន័យពិសិដ្ឋសម្រាប់ខ្ញុំ។ ខ្ញុំបានខំស្វែងរកសិក្ខាបទរបៀបនេះ អស់កាលជាយូរមកហើយ។ ខ្ញុំបានស្តាប់ឮតែមួយផ្នែកនៃចម្រៀងសូមមេត្តាឲ្យខ្ញុំ បានស្តាប់ផ្នែកបន្តទៅទៀតផង!»។

បិសាចនិយាយទៀតថា: «យើងឃ្លានណាស់ បើយើងមិនបានស៊ីសាច់និងឈាមមនុស្សទេ យើងនឹងមិនបញ្ចប់ចម្រៀងនេះជាដាច់ខាត»។

បុរសដោយចង់ស្តាប់សិក្ខាបទនោះជាពន់ពេក ក៏សន្យានឹងបិសាចថា នឹងប្រគល់ខ្លួនឲ្យបិសាចស៊ី ក្រោយពេលបានស្តាប់សិក្ខាបទចប់ហើយ។ បិសាចក៏ចាប់សូត្របញ្ចប់កំណាព្យ:

«អ្វី ៗ ទាំងអស់ សុទ្ធតែប្រែប្រួល
អ្វី ៗ ទាំងអស់ កើតឡើងហើយវិនាសបាត់ទៅវិញ
គេនឹងបានសុខស្ងប់ពេញលេញឥតខ្ចោះ
កាលណាគេបានហួសផុតពីការកើតនិងការស្លាប់!»

ក្រោយបានស្តាប់កំណាព្យនេះហើយ បុរសក៏ចារទុកលើផ្ទាំងថ្មនឹងដើមឈើនៅជុំវិញនោះ រួចហើយឡើងដើមឈើ

លោតទម្លាក់ខ្លួនមកប្របនឹងជើងបិសាច។ ភ្លាមនោះ បិសាចវិនាសបាត់រូបទៅ ចេញឯព្រះឥន្ទ្រប្រកបដោយពន្លឺភ្លឺរន្ទាលនៅឈរវង់ទទួលបុរសនោះឲ្យផុតពីគ្រោះថ្នាក់។

8. ក្នុងសម័យមួយនោះ មានបុរសដើរស្វែងរកផ្លូវពិតប្រាកដម្នាក់ឈ្មោះ **សទប្ររុទិត**។ បុរសនោះលះបង់សេចក្តីប្រាថ្នាចង់បានកម្រៃនិងកិត្តិយសទាំងអស់ គេខំស្វះស្វែងរកផ្លូវទៅកាន់សេចក្តីពិត ដោយមិនខ្លាចអស់ជីវិត។ ថ្ងៃមួយមានសំឡេងឮចេញពីលើមេឃមកថា: «**សទប្ររុទិត** ! ចូរអ្នកដើរតម្រង់ទៅទិសខាងកើត។ ចូរអ្នកកុំគិតពីភាពក្តៅ ឬត្រជាក់ឡើយចូរកុំរវល់នឹងការសរសើរ ឬការប្រមាថរបស់មនុស្សឡើយ ចូរកុំខ្វល់នឹងភាពល្អ ឬភាពអាក្រក់ឡើយ ចូរគិតតែពីដើរតម្រង់ទៅទិសខាងកើតបានហើយ។ កាលណាអ្នកទៅដល់ចុងទិសខាងកើត អ្នកនឹងបានជួបនឹងគ្រូអាចារ្យពិតប្រាកដម្នាក់ ហើយអ្នកនឹងបានទទួលពន្លឺត្រាស់ដឹង»។

**សទប្ររុទិត** ទទួលគោរពតាមបញ្ជាដ៏ជាក់លាក់នោះដោយចិត្តរីករាយជាអនេក។ គេចាប់ចេញដំណើរតម្រង់ទៅ

*ទិសខាងកើតភ្លាមមួយរំពេច។ **សទប្ររុទិត** គិតតែពីដើរទៅមុខយប់កន្លែងណាដេកកន្លែងនោះ ជួនកាលដេកនៅក្នុងវាលស្រែស្ងាត់ជ្រងំ ជួនកាលទៀតគេដេកនៅក្នុងព្រៃភ្នំប្រកបដោយគ្រោះថ្នាក់។ ក្នុងភាពជាជនបរទេស សំណាក់នៅក្នុងប្រទេសគេ បុរសនោះ ត្រូវបានទទួលរងនូវការប្រមាថគ្រប់បែបយ៉ាង។ ម្តងនោះ គេបានលក់ខ្លួនគេជាទាសកម្មករ។ ម្តងនោះទៀត ដោយការស្រេកឃ្លានខ្លាំងពេក គេត្រូវបានលក់សាច់របស់គេ។ តែដល់ទីបំផុត គេបានជួបនឹងគ្រូអាចារ្យពិតប្រាកដ ហើយថ្វាយបង្គំសុំរៀនធម៌។*

*មានភាសិតមួយថា: «វត្ថុដែលល្អវាតែងតែថ្លៃ»។ **សទប្រ-រុទិត** ឃើញថា រឿងខ្លួនដូចជាភាសិតនេះបេះបិទ ពីព្រោះគេបានជួបប្រទះនឹងការលំបាកវេទនាជាច្រើន នៅក្នុងដំណើរស្វែងរកសេចក្តីពិតរបស់គេ។គេគ្មានប្រាក់ដើម្បីទិញផ្កា ធូបទៀន យកទៅបូជាគ្រូ។ គេខំដើររកស៊ីឈ្នួលគេ តែគ្មាននរណាម្នាក់ត្រូវការគេឡើយ។ ហាក់ដូចជាមានយក្សកំណាចតាមរារាំងគេ គ្រប់ពេលដែលគេប្រាថ្នាធ្វើអ្វីមួយ។ ផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ពិបាកពន់ពេកណាស់ ហើយអាចថ្លៃស្មើនឹង*

ជីវិតអ្នកស្វែងរកផ្លូវនោះ។

ជាទីបំផុត **សទប្រុទិត** បានទៅជាសិស្សរបស់លោកគ្រូអាចារ្យនោះ។ តែនៅពេលនោះ គេត្រូវបានប្រទះនឹងការលំបាកមួយទៀត។ គេគ្មានក្រដាស ដើម្បីកត់ត្រាសេចក្តីប្រៀនប្រដៅរបស់លោកគ្រូ គេគ្មានជក់នឹងទឹកខ្មៅដើម្បីសរសេរ។ គេក៏ចាក់កដៃរបស់គេបង្ហូរយកឈាម ដើម្បីសរសេរ។ គឺតាមរបៀបនេះឯង ដែលគេរកឃើញសេចក្តីពិតដ៏ប្រសើរថ្លៃថ្លា។

9. កាលមួយនោះមានកុមារម្នាក់ឈ្មោះ **សុធន** ជាអ្នកប្រាថ្នាពន្លឺត្រាស់ដឹងម្នាក់ដែរ វាខំស្វែងរកផ្លូវទៅកាន់ពន្លឺពោធិញាណនោះយ៉ាងម៉ឺងម៉ាត់។ ក្មេងនោះ បានរៀនវិជ្ជាផ្នែកសមុទ្រពីអ្នកនេសាទត្រីម្នាក់ រៀនចេះមានចិត្តអាណិតអាសូរចំពោះអ្នកជំងឺដែលឈឺចុកចាប់ ពីលោកគ្រូពេទ្យម្នាក់។ អ្នកមានស្តុកស្តម្ភម្នាក់ពន្យល់វាថា ដោយសារការសន្សំ បានជាគាត់បានឡើងជាអ្នកមាននេះ សូម្បីមួយសេន ក៏គាត់សន្សំទុកដែរ។ ក្មេងនោះក៏បានយល់ថា ដើម្បីទៅកាន់ពន្លឺត្រាស់ដឹង ការមិន

បណ្ដោយឲ្យឱកាសសូម្បីតែបន្តិច បាត់បង់ទៅនោះ ជាការចាំបាច់បំផុត។

ដោយសារព្រះសង្ឃគង់ចម្រើនភាវនាមួយអង្គ ក្មេងនោះបានយល់ថា ចិត្តបរិសុទ្ធស្ងប់មានឥទ្ធិពលអស្ចារ្យអាចធ្វើឲ្យចិត្តអ្នកឯទៀតបានបរិសុទ្ធស្ងប់។ ថ្ងៃមួយ ក្មេងនោះបានជួបនឹងនារីប្រកបដោយសីលធម៌ពិសេសម្នាក់ ហើយវារំភើបជាខ្លាំងចំពោះចិត្តមានសប្បុរសធម៌របស់នារីនោះ។ ដោយសារនារីនោះ វាបានដឹងថា សប្បុរសធម៌ជាផលនៃគតិបណ្ឌិត។ មានម្ដងទៀត តាចាស់អនាថាម្នាក់និយាយប្រាប់វាថា ដើម្បីទៅកាន់ទីកន្លែងណាមួយ គាត់ត្រូវតែវារឡើងភ្នំ ប្រកបដោយចម្រូងដាវលំពែង ហើយឆ្លងកាត់ជ្រលងភ្នំ ដែលមានភ្លើងឆេះពាសពេញ។ ដោយសារការពិសោធន៍ទាំងនេះ **សុធន** បានដឹងថា ការស្វែងរកសិក្ខាបទពិតប្រាកដអាចនឹងបានសម្រេចតាមដោយអ្វីៗ ដែលគេឃើញ និងតាមដោយអ្វីៗ ដែលគេឮ។

សុធនកុមារ រៀនចេះមានសេចក្ដីអំណត់ ពីស្រីពិការ ក្រតោកយ៉ាកម្នាក់ រៀនចេះមានសេចក្ដីសប្បាយជាធម្មតា ដោយ

សារមើលកូនក្មេងតូចៗរត់លេងតាមផ្លូវ។ វាបានដឹងអាថ៌កំបាំងក្នុងការរស់នៅដោយសុខសន្តិភាពជាមួយអ្នកផងទាំងពួង ពីមនុស្សសុភាពរាបសាគួរជាទីស្រឡាញ់រាប់អានដែលមិនចេះគិតចង់បានវត្ថុណាដែលមានអ្នកឯទៀតចង់បានដែរ។

វាបានយល់អំពីភាពសុខដុម ដោយសារមើលទៅផ្សេងធូបហុយព័ទ្ធពេនចូលគ្នា។ វាបានយល់អំពីការដឹងគុណ ដោយសារការក្រេងផ្កា។ ថ្ងៃមួយវាដើរកាត់ព្រៃ ទៅឈប់សម្រាកក្រោមដើមពោធិមួយ។ នៅជិតនោះ វាបានសម្គាល់ឃើញមានកូនរុក្ខជាតិតូចមួយដុះពីលើដើមឈើរលំដួលពុកមួយដើម។ ការបានសង្កេតឃើញនេះ នាំឲ្យវាយល់អំពីភាពមិនទៀងទាត់នៃជីវិត។

ពន្លឺព្រះអាទិត្យនៅពេលថ្ងៃ និងពន្លឺចាំងផ្ទេកៗនៃហ្វូងតារានៅពេលយប់ ធ្វើឲ្យចិត្តរបស់ក្មេងនោះ បាននៅល្អស្រស់ជានិច្ច។ របៀបនេះហើយ ដែលកុមារសុធន បានដកស្រង់យកផលប្រយោជន៍ ពីការពិសោធន៍ទាំងឡាយ ក្នុងដំណើរជីវិតដ៏វែងឆ្ងាយរបស់គេ។

អ្នកស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែគិតថា ចិត្តរបស់ខ្លួនជា

ប្រាសាទវិមាន ដែលគេត្រូវតែតាក់តែងសំអាតលំអ។ គេត្រូវតែបើកមាត់ទ្វារប្រាសាទនៃចិត្តរបស់ខ្លួនឲ្យធំសម្រាប់ព្រះពុទ្ធ ហើយមានចិត្តជ្រះថ្លានិមន្តព្រះអង្គចូលទៅក្នុងមណ្ឌលសំខាន់ខាងក្នុង ដើម្បីថ្វាយទៀនធូបជាតំណាងនៃចិត្តភក្តីនិងថ្វាយផ្កាជាតំណាងនៃការដឹងគុណ និងសេចក្តីត្រេកអរចំពោះព្រះអង្គ។

II

# វិធីប្រតិបត្តិ

1. ចំពោះអ្នកស្វែងរកពន្លឺត្រាស់ដឹង មានកិច្ចប្រតិបត្តិបីដែលត្រូវតែយល់ ហើយធ្វើតាម គឺ: ទី១-ការហាត់រៀនឲ្យមានចរិយាល្អ ទី២-ការហាត់រៀនសង្រួមចិត្ត ទី៣-ការហាត់រៀនឲ្យមានគតិបណ្ឌិត។

អ្វីទៅ ដែលហៅថា ការហាត់រៀនឲ្យមានចរិយាល្អ ? មនុស្សលោកទាំងអស់ ទោះបីជាមនុស្សសាមញ្ញក៏ដោយ ឬជាអ្នកស្វែងរកពន្លឺត្រាស់ដឹងក៏ដោយ ត្រូវតែអប់រំខ្លួនឲ្យមាន

ចរិយាល្អ។ គេត្រូវតែពិនិត្យត្រួតត្រាចិត្តរបស់ខ្លួនផងនិងកាយវិការរបស់ខ្លួនផង ហើយត្រូវតែរក្សាការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំរបស់ខ្លួន។ គេត្រូវតែខ្លាចគ្រប់កំហុសទាំងអស់ ទោះបីកំហុសនោះតូចប៉ុនណាក៏ដោយ ហើយត្រូវខំប្រព្រឹត្តតែអំពើល្អ។

អ្វីទៅ ដែលហៅថា ការហាត់រៀនសង្រួមចិត្ត? បានន័យថា គេត្រូវតែបោះបង់ចោលសេចក្ដីលោភលន់ និងបំណងអាក្រក់ក្លាមមួយរំពេច កាលណាការអពមង្គលទាំងនេះ កកើតមានឡើង ហើយខំរក្សាចិត្តរបស់ខ្លួនឲ្យបានបរិសុទ្ធស្ងប់។

អ្វីទៅ ដែលហៅថា គតិបណ្ឌិត ? គឺការយល់ជាក់ច្បាស់និងទទួលស្គាល់ដោយឥតសង្ស័យ នូវការពិតបំផុតទាំងបួនពោលគឺៈ ទុក្ខ កំណើតនៃទុក្ខ ការបំបាត់ទុក្ខ និងផ្លូវប្រសើរខ្ពង់ខ្ពស់ដែលនាំឲ្យអស់មានទុក្ខ។ បុគ្គលដែលពិតជាប្រតិបត្តិតាមវិន័យទាំងបីនេះ អាចហៅថាជា «សាវ័ករបស់ព្រះពុទ្ធ» មែនពិត។

ឧបមាថា សត្វលាមួយ ដែលគ្មានរូបរាង គ្មានសំឡេង គ្មានស្នែង ដូចមេគោ ដើរតាមហ្វូងមេគោ ហើយស្រដីថាៈ «ចូរ

អ្នកទាំងអស់គ្នាមើល៍ រូបអញនេះជាមេគោ ! » ។ តើមានអ្នកណាជឿសំដីសត្វលានោះទេ? ក៏ជាការឆ្កួតលេលាដូចសត្វលានេះដែរ ចំពោះបុគ្គលណាដែលមិនប្រតិបត្តិតាមវិន័យទាំងបីនេះ ហើយប្រកាសខ្លួនថា ដើរតាមផ្លូវប្រសើរឧត្តម ឬថាខ្លួនជាសាវ័ករបស់ព្រះពុទ្ធ។

មុននឹងបេះយកផលដំណាំបាន ជាដំបូងកសិករតោងតែភ្ជួររាស់ដី សាបព្រោះគ្រាប់ពូជ បញ្ចូលទឹកស្រោចដំណាំ ហើយដកស្មៅចេញ។ យ៉ាងណាមិញ បុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹងត្រូវតែប្រតិបត្តិវិន័យទាំងបីនេះ ដូច្នេះដែរ។ អ្នកស្រែមិនអាចដេកសង្ឃឹមរង់ចាំឃើញពន្លកដុះឡើងក្នុងថ្ងៃនេះ ឃើញកូនដំណាំលូតចេញឡើងក្នុងថ្ងៃស្អែក ហើយបេះយកផលក្នុងថ្ងៃខានស្អែក នោះបានទេ។ យ៉ាងណាមិញ អ្នកដែលស្វែងរកពន្លឺត្រាស់ដឹង ក៏មិនត្រូវដេកចាំឲ្យចំណង់លោកិយបាត់អស់អំពីខ្លួនក្នុងថ្ងៃនេះ ឲ្យសេចក្តីជំពាក់ចិត្តនឹងបំណងអាក្រក់ទាំងឡាយវិនាសបាត់អស់ពីខ្លួនក្នុងថ្ងៃស្អែក ហើយបានសម្រេចពន្លឺត្រាស់ដឹងក្នុងថ្ងៃខានស្អែក យ៉ាងដូច្នោះដែរ។

ក្រោយពេលសាបព្រោះហើយ កសិករតែងតែថែទាំដំណាំរបស់គេយ៉ាងអំណត់ ពីរដូវមួយទៅរដូវមួយ រហូតដល់មានផ្លែផ្កា។ យ៉ាងណាមិញ អ្នកស្វែងរកពន្លឺត្រាស់ដឹង ក៏ត្រូវតែមានការអំណត់ព្យាយាមបណ្តុះគ្រាប់ពូជនៃពន្លឺត្រាស់ដឹង ដោយប្រតិបត្តិតាមវិន័យទាំងបីនេះ កុំបីឃ្លៀងឃ្លាតឡើយ។

2. ដើរទៅមុខតាមផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ជាការពិបាកណាស់ដរាបណាគេនៅតែជំពាក់ចិត្តនឹងសុខុមាលភាពហើយ និងប្រណីតភាព ដរាបណាគេបណ្តោយឲ្យតណ្ហានៃវិញ្ញាណទាំងប្រាំចូលលុកលុយរំខានចិត្តរបស់គេ។ មានសភាពខុសគ្នាស្រឡះរវាងសប្បាយរីករាយក្នុងការរស់នៅ និងសប្បាយរីករាយក្នុងការដើរតាមផ្លូវប្រសើរឧត្តម។

ដូចបានស្តីមកហើយ ចិត្តជាប្រភពនៃគ្រប់វត្ថុទាំងឡាយ។ បើចិត្ត វាមានចំណូលនឹងរឿងលោកិយ នឹងការថ្លើនភ្នែកទាំងពួង ទុក្ខវេទនានឹងរត់ដេញតាមជាមិនខាន។ ផ្ទុយទៅវិញ បើចិត្តសប្បាយនឹងដើរតាមផ្លូវប្រសើរឧត្តម សុភមង្គល សេចក្តី

សប្បាយរីករាយ ហើយនិងពន្លឺត្រាស់ដឹង នឹងរត់តាមជាពិតប្រាកដមិនខាន។

ហេតុនេះ បុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែរក្សាចិត្តរបស់ខ្លួនឲ្យបានបរិសុទ្ធ ហើយខំប្រតិបត្តិវិន័យទាំងបីដោយព្យាយាមអំណត់។ បើគេខំសង្វាតហាត់រៀន គោរពប្រតិបត្តិតាមវិន័យទាំងបីនេះ គេនឹងបានសង្រួមចិត្តជាមិនខាន កាលបើគេបានសង្រួមចិត្តហើយ គេនឹងបានបំភ្លឺដោយគតិធម៌ ហើយគតិធម៌នេះនឹងដឹកនាំគេទៅកាន់ពន្លឺត្រាស់ដឹង។

វត្តប្រតិបត្តិទាំងបីប្រការនេះ ពោលគឺ ការប្រតិបត្តិច្បាប់វិន័យមួយ ការសង្រួមចិត្តមួយ និងការមានគតិធម៌មួយ ជាផ្លូវពិតប្រាកដទៅកាន់ពន្លឺត្រាស់ដឹង ដោយហេតុតែមិនប្រតិបត្តិតាមសិក្ខាបទទាំងបីនេះហើយ ដែលតាំងពីយូរអង្វែងមក ហើយមនុស្សលោកបានគរទុកនូវគំនិតភាន់ច្រឡំជាគំនររាប់មិនអស់។ ដូច្នេះ គេមិនត្រូវជជែករកខុសត្រូវជាមួយនឹងមនុស្សផងគ្នា នៅក្នុងលោកនេះទេ គេត្រូវតែសង្រួមចិត្តខំជញ្ជឹងគិតធ្វើវត្តប្រតិបត្តិយ៉ាងអំណត់ ដើម្បីឲ្យបានសម្រេចពន្លឺត្រាស់ដឹង។

3. បើគេរៃកញែកសិក្ខាបទទាំងបីនេះឲ្យបានល្អិតល្អន់ គេនឹងឃើញជាក់ថាសិក្ខាបទទាំងនេះចែកចេញជា ផ្លូវប្រសើរឧត្តម (មគ្គ) ប្រាំបី ទស្សនបទ (សតិបដ្ឋាន) បួន វិធីខំប្រឹងប្រែងដែលត្រឹមត្រូវល្អ (បធាន) បួន ថាមពលដែលត្រូវយកមកប្រើ (ឥន្ទ្រីយ៍) ប្រាំ ហើយនិងគុណធម៌ (បារមី) ប្រាំមួយ។

ផ្លូវប្រសើរឧត្តម (មគ្គ) ប្រាំបីនោះគឺៈ ការមើលឃើញត្រូវ១ ការគិតត្រូវ១ ពាក្យសំដីត្រូវ១ អំពើត្រូវ១ ការរស់នៅត្រូវ១ ការខំសង្វាតត្រូវ១ ការប៉ងប្រាថ្នាត្រូវ១ និងការសង្រួមចិត្តត្រូវ១ ។

ការមើលឃើញត្រូវ មានបីចំណែកគឺៈ ការយល់ជាក់ច្បាស់នូវសេចក្តីពិតខ្ពង់ខ្ពស់ (អរិយសច្ចៈ) ទាំងបួន១ ការទទួលស្គាល់នូវច្បាប់ស្តីអំពីកម្មផល១ ការមិនលុះក្នុងសភាពជាខាងក្រៅនៃវត្ថុហើយ និងក្នុងចំណង់ទាំងឡាយរបស់ខ្លួន១។

ការគិតត្រូវ បានន័យថា សម្រេចចិត្តមិនបម្រើចំណង់របស់ខ្លួន មិនលោភលន់ មិនខឹងក្រោធ មិនប្រព្រឹត្តអំពីអកុសល។

ពាក្យសំដីត្រូវ បានន័យថា ចៀសវាងពាក្យភូតកុហក ពាក្យឥតបានការ ពាក្យជេរប្រមាថ ពាក្យមួលបង្កាច់។

អំពើត្រូវ បានន័យថា មិនត្រូវបំផ្លាញជីវិតគេ មិនត្រូវលួចប្លន់គេ មិនត្រូវប្រព្រឹត្តការផិតក្បត់។

ការរស់នៅត្រូវ បានន័យថា ចៀសវាងការរស់នៅដែលឲ្យទោសដល់អ្នកឯទៀត។

ការខំសង្វាតត្រូវ បានន័យថា ខំយកចិត្តទុកដាក់ធ្វើវត្តប្រតិបត្តិឆ្ពោះទៅរកទិសត្រូវ។

ការប៉ងប្រាថ្នាត្រូវ បានន័យថា ខំប្រុងប្រយ័ត្នរក្សាចិត្តឲ្យបាននៅបរិសុទ្ធជានិច្ច។

ការសង្រួមចិត្តត្រូវ បានន័យថា ខំរក្សាចិត្តឲ្យបាននៅត្រឹមត្រង់ស្ងប់ ដើម្បីឲ្យបានសម្រេចការត្រាស់ដឹង។

4. ទស្សនបទ (សតិបដ្ឋាន) បួននោះគឺ: ទី១ គិតពិចារណាថា រូបកាយប្រកបដោយវត្ថុមិនបរិសុទ្ធ មិនត្រូវជំពាក់ចិត្តនឹងរូបកាយនេះទេ។ ទី២ គិតពិចារណាថា វិញ្ញាណារម្មណ៍ទាំងឡាយជាប្រភពនៃទុក្ខ ទោះបីវាមកជាអារម្មណ៍ព្រួយ ឬជាអារម្មណ៍សប្បាយក៏ដោយ។ ទី៣ គិតពិចារណាថា ចិត្តជាចរន្តដែលហូរមិនចេះឈប់។ ទី៤ គិតពិចារណាថា អ្វីៗទាំងអស់នៅក្នុងលោកនេះ សុទ្ធតែជាលទ្ធផលនៃការទាក់ទងរវាង

ហេតុនិងផល ហើយគ្មានអ្វីដែលអាចនៅគង់វង្សរហូត ដោយមិនប្រែប្រួលនោះទេ។

5. វិធីខំប្រឹងប្រែងដែលត្រឹមត្រូវល្អ (សម្មប្បធាន) ទាំងបួននោះគឺ: ខំការពារកុំឲ្យអំពើអាក្រក់កើតឡើងបាន១ កាលណាអំពើអាក្រក់កើតឡើងហើយ ត្រូវកំចាត់វាចោលភ្លាម១ ខំបង្កើតអំពើល្អ១ ខំធ្វើឲ្យអំពើល្អបានលូតលាស់នៅពេលវាកើតឡើងហើយ១។

6. ថាមពលដែលត្រូវយកមកប្រើ (ឥន្ទ្រីយ៍) ទាំងប្រាំនោះ គឺ: ជំនឿជ្រះថ្លា១ ការមានចេតនានឹងធ្វើការខំប្រឹងប្រែង១ ស្មារតីប្រុងប្រយ័ត្ន១ សមត្ថភាពក្នុងការសង្រួមចិត្ត១ សមត្ថភាពក្នុងការរក្សាគតិធម៌ភ្លឺថ្លា១។

7. គុណធម៌ខ្ពង់ខ្ពស់បំផុត (បារមី) ទាំងប្រាំមួយ ដែលជាយាននាំយើងទៅដាក់ដល់ត្រើយនៃពន្លឺត្រាស់ដឹងនោះគឺ: ទាន១ ការគោរពប្រតិបត្តិច្បាប់វិន័យ (សីល)១ ការមានសេចក្តីអំណត់ (ខន្តី) ១ ការខំប្រឹងប្រែងសង្វាត (វិរិយៈ) ១ ការសង្រួមចិត្ត

(ឈាន) ១ ការមានគតិបណ្ឌិត (បញ្ញា) ១។ បើគេដើរតាមផ្លូវប្រសើរទាំងប្រាំមួយនេះ គេប្រាកដជាអាចឆ្លងរួចផុតពីត្រើយដែលពោរពេញទៅដោយការថ្លឹនភ្នែក ហើយបានទៅដល់ត្រើយពន្លឺត្រាស់ដឹងជាពុំខាន។

ការធ្វើទាន នាំឲ្យចាកផុតពីអត្តទត្តភាព។ ការគោរពប្រតិបត្តិច្បាប់វិន័យ នាំឲ្យចេះយកចិត្តទុកដាក់ចំពោះសិទ្ធិ និងសុខុមាលភាពរបស់អ្នកដទៃ។ ការមានសេចក្ដីអំណត់ នាំឲ្យចេះបង្ក្រាបការខ្លាច និងសេចក្ដីខឹងក្រោធ។ ការសង្វាតប្រឹងប្រែង នាំឲ្យមានសេចក្ដីវៀសវៃ និងសេចក្ដីទៀងត្រង់។ ការសង្រួមចិត្ត នាំឲ្យចេះត្រួតត្រាចិត្តដែលវង្វេងវង្វាន់សាវា។ ការមានគតិបណ្ឌិត បណ្ដាលឲ្យសតិងងឹតងងល់ច្របូកច្របល់បានទៅជាសតិភ្លឺថ្លា ឈ្លាសវៃ។

ទាន និងច្បាប់វិន័យ ជាគ្រឹះសំខាន់ជាចាំបាច់ក្នុងការសង់វិមានប្រាសាទ។ សេចក្ដីអំណត់ និងសេចក្ដីសង្វាតប្រឹងប្រែង ជាកំពែងការពារប្រាសាទ កុំឲ្យសត្រូវមកពីក្រៅចូលបាន។ ការសង្រួមចិត្ត និងការមានគតិបណ្ឌិត ជាគ្រោះសម្រាប់ការពារការវាយលុកនៃការរស់នៅនិងការស្លាប់។

បើគេធ្វើទាន តែក្នុងពេលណា ឃើញប្រយោជន៍ត្រឡប់មកវិញ ឬដោយសារតែធ្វើវាស្រួល ជាជាងមិនធ្វើ ជាពិតប្រាកដណាស់ ទាននោះ ពុំមែនជាទានពិតប្រាកដទេ។ ទានពិតប្រាកដ គឺទានដែលគេធ្វើប្រកបដោយចិត្តជ្រះថ្លា។ ម្យ៉ាងទៀត ទានពិតប្រាកដ ត្រូវធ្វើឡើង ពុំមែនតែម្តងទេ គឺត្រូវធ្វើជានិច្ចកាល។

ក៏ពុំមែនជាទានពិតប្រាកដដែរ បើកាលណាគេធ្វើដោយមានចិត្តស្តាយ ឬដោយប្រាថ្នាចង់បានការអួតសរសើរ ទានពិតប្រាកដ គឺទាន ដែលធ្វើឡើងដោយចិត្តរីករាយ គ្មានគិតថាខ្លួនជាអ្នកឲ្យមិនរំលឹកឡើងវិញអំពីអ្នកទទួល ហើយមិនគិតដល់វត្ថុដែលបានឲ្យជាទាន។

ទានពិតប្រាកដ ចេញមកដោយឯកឯងពីចិត្តមានមេត្តាធម៌ គ្មានទឹកសង្ឃឹមចង់បានមកវិញ ប៉ុន្តែដោយប្រាថ្នាឲ្យបានចូលទៅក្នុងគន្លងផ្លូវនៃពន្លឺត្រាស់ដឹងទាំងអស់គ្នា។

ទានទាំងប្រាំពីរយ៉ាង ដែលសូម្បីតែអ្នកក្រខ្សត់ទ្រព្យសម្បត្តិ ក៏អាចធ្វើបានដែរ។ ទានទី១ គឺការធ្វើទានរូប

កាយ។ ទានក្នុងប្រភេទនេះ គឺយកកម្លាំងកាយធ្វើជាទាន ហើយខ្ពង់ខ្ពស់បំផុតទៅទៀត គឺបូជាជីវិតសម្រាប់ជាទាន ដូចជាមានរឿងនិទានក្នុងវគ្គតទៅនេះ។ ទានទី២ គឺការធ្វើទានចិត្ត គឺផ្តល់នូវចិត្តមានមេត្តាធម៌ ចំពោះអ្នកឯទៀត។ ទានទី៣ គឺការធ្វើទានចក្ខុ គឺផ្តល់នូវខ្សែភ្នែកត្រជាក់ ស្រទន់ដែលជាសញ្ញានៃសេចក្តីសុខស្ងប់សម្រាប់អ្នកឯទៀត។ ទានទី៤ គឺការធ្វើទានទឹកមុខ គឺបញ្ចេញទឹកមុខរីករាយ ស្រទន់ចំពោះអ្នកឯទៀត។ ទានទី៥ គឺការធ្វើទានពាក្យសំដី គឺមានវាចាពាក់ទាក់ ផ្អែមត្រជាក់ ចំពោះអ្នកឯទៀត។ ទានទី៦ គឺការធ្វើទានកន្លែងអង្គុយ គឺឲ្យកន្លែងអង្គុយទៅអ្នកឯទៀត។ ទានទី៧ គឺការធ្វើទានទីជម្រក គឺឲ្យអ្នកឯទៀតឈប់សំណាក់ក្នុងទីលំនៅរបស់ខ្លួនមួយយប់។ ទានទាំងប្រាំពីរប្រភេទនេះ នរណាក៏អាចធ្វើបានដែរ។

8. សម័យមួយនោះ មានព្រះរាជាមួយព្រះអង្គ ព្រះនាម **សត្តៈ**។ ថ្ងៃមួយ ព្រះសត្តៈយាងទៅប្រពាតព្រៃ ជាមួយនឹង

ព្រះរាមរបស់ព្រះអង្គពីរព្រះអង្គ។ នៅក្នុងព្រៃ ក្សត្របងប្អូនទាំងបីព្រះអង្គបានឃើញមេខ្លាមួយ ដោយឃ្លានពេកបម្រុងនឹងហែកកូនរបស់ខ្លួនទាំងប្រាំពីរស៊ី ដើម្បីសម្រន់ការអត់ឃ្លាន។

ព្រះរាមច្បងទាំងពីរ ភ័យជាខ្លាំង ហើយរត់បាត់ទៅ។ ចំណែក **ព្រះសត្វៈ** ព្រះអង្គទ្រង់ឡើងទៅលើចំណោតខ្ពស់មួយ ហើយលោតទម្លាក់ខ្លួនមកឲ្យមេខ្លាស៊ីជាចំណី ដើម្បីសង្គ្រោះកូនខ្លាទាំងប្រាំពីរ។

**ព្រះសត្វៈ** ទ្រង់ធ្វើអំពើសប្បុរសនេះ ដោយចិត្តមេត្តាដែលចេញមកដោយឯកឯង។ ប៉ុន្តែព្រះអង្គបានគិតក្នុងចិត្តថាៈ «រូបកាយនេះ វាប្រែប្រួល វាមិនឋិតថេរទេ។ អញស្រឡាញ់ថ្នាក់ថ្នមរូបកាយនេះ ដោយឥតមានចិត្ត ចង់បោះបង់វាចោលទេ ប៉ុន្តែនៅពេលនេះ អញដាក់ទានទៅឲ្យមេខ្លា ក្នុងបំណងឲ្យបានសម្រេចពន្លឺត្រាស់ដឹង»។ ការជញ្ជឹងគិតនេះ បង្ហាញឲ្យឃើញថា បំណងពិតប្រាកដរបស់**ព្រះសត្វៈ** គឺការបានសម្រេចពន្លឺត្រាស់ដឹង។

9. មានសភាពចិត្តធំធេងឥតព្រំដែនបួនយ៉ាង ដែលអ្នកស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែបណ្ដុះបណ្ដាលគឺៈ ចិត្តមិនប្រាថ្នាប្រយោជន៍ ចិត្តមានមេត្តាអាសូរ ចិត្តជ្រះថ្លា និងចិត្តប្រកបដោយសមភាព។ គេអាចបំបាត់ចំណង់ ដោយសារចិត្តមិនប្រាថ្នាប្រយោជន៍។ គេអាចបំបាត់កំហឹង ដោយសារចិត្តមានមេត្តាអាសូរ។ គេអាចបំបាត់ទុក្ខ ដោយសារចិត្តជ្រះថ្លា។ គេអាចបំបាត់គំនិតវែកញែករវាងមិត្តនឹងសត្រូវ ដោយសារបណ្ដុះចិត្តប្រកបដោយសមភាព។

ការមិនប្រាថ្នាប្រយោជន៍ បានន័យថា ធ្វើឲ្យអ្នកផងទាំងពួងបានសុខសប្បាយ បានពេញចិត្ត។ ការមានមេត្តាអាសូរ បានន័យថា បំបាត់ចោលអ្វីៗ ដែលបណ្ដាលឲ្យអ្នកផងទាំងពួងមិនបានសុខសប្បាយ មិនបានពេញចិត្ត។ ការមានចិត្តជ្រះថ្លា បានន័យថា រីករាយសប្បាយនឹងឃើញបុគ្គលណាម្នាក់បានសុខសប្បាយ បានពេញចិត្ត។ ការមានចិត្តជាសមភាព បានន័យថា មានមនោសញ្ចេតនាចំពោះសត្វលោកទាំងអស់ ដោយស្មើភាពគ្នា គឺប្រាថ្នាចង់ឲ្យបុគ្គលរាល់រូបបានសុខសប្បាយ បានពេញចិត្ត។

ត្រូវតែផ្ចឹតផ្ចង់បណ្តុះបណ្តាលសភាពចិត្តជំពេង ឥតព្រំដែនទាំងបួននេះ ហើយត្រូវតែកំចាត់ចោលសេចក្តីលោភ ការខឹងក្រោធ ការព្រួយបារម្ភ និងការវែកញែករវាងមិត្តនឹងសត្រូវ។ ប៉ុន្តែកិច្ចទាំងនេះមិនមែនស្រួលនឹងធ្វើទេ។ ការកំចាត់ចោលនូវសភាពចិត្តអាក្រក់ ជាការពិបាក តែការកំចាត់ចោលនូវសភាពចិត្តល្អ ជាការងាយស្រួល។ ការកំចាត់ចោលនូវសភាពចិត្តអាក្រក់ វាពិបាកដូចជាការលុបបំបាត់អក្សរដែលឆ្លាក់ជាប់នៅលើផ្ទាំងថ្ម។ ប៉ុន្តែ ការបំបាត់ចោលនូវសភាពចិត្តល្អ វាងាយដូចជាលុបអក្សរដែលសរសេរទុកលើផ្ទៃទឹក។ ប៉ុន្តែនៅក្នុងជីវិតនេះ មានកិច្ចមួយពិបាកជាទីបំផុត ជាងនេះទៅទៀត គឺការព្យាយាមហាត់រៀន ដើម្បីបានសម្រេចពន្លឺត្រាស់ដឹង។

10. មានបុរសម្នាក់ឈ្មោះ ***សោណៈ*** កើតក្នុងត្រកូលអ្នកមានតែសុខភាពរបស់គាត់ខ្សោយជាពន់ពេកណាស់។ ដោយគាត់ប្រាថ្នាយ៉ាងមុតមាំចង់បានសម្រេចពន្លឺត្រាស់ដឹង គាត់ក៏បានទៅជាសិស្សម្នាក់របស់ព្រះពុទ្ធ។ គាត់បានបំពេញការខំព្យាយាម

យ៉ាងតឹងតែងជាទីបំផុត រហូតដល់ឈាមហូរចេញពីបាតជើង តែគាត់មិនបានសម្រេចពន្លឺត្រាស់ដឹងសោះ។

ព្រះបរមគ្រូ មានចិត្តអាណិតគាត់ជាខ្លាំង ព្រះអង្គក៏មានពុទ្ធដីកាទៅកាន់គាត់ថា: «ម្នាល**សោណៈ**ជាកូន ! កាលឯងនៅផ្ទះ ឯងដែលបានហាត់រៀនលេងពិណាឬទេ? ឯងដឹងឬទេថា ពិណាមិនអាចបញ្ចេញសំឡេងពីរោះបានទេ បើកាលណាខ្សែពិណានោះតឹងពេក ឬធូរពេក។ ពិណាអាចប្រគំជាតន្ត្រីពីរោះបាន លុះណាតែគេរឹតខ្សែពិណានោះតឹងល្មម»។

«ការព្យាយាមដើម្បីបានសម្រេចពន្លឺត្រាស់ដឹង ក៏ដូចជាខ្សែពិណាដែលគេរឹតតឹងល្មមនោះដែរ។ ឯងមិនអាចបានសម្រេចពន្លឺត្រាស់ដឹងទេ បើកាលណាហើយខ្សែចិត្តរបស់ឯង វាធូរពេក ឬតឹងពេក។ ដូច្នេះ ឯងត្រូវតែគិតពិចារណាឲ្យបានហ្មត់ហ្មង ហើយព្យាយាមប្រតិបត្តិដោយគតិបណ្ឌិត»។

**សោណៈ** បានយល់ថាពាក្យទូន្មានទាំងនេះសំខាន់ណាស់ ក៏ប្រព្រឹត្តតាម ហើយទីបំផុតគេក៏បានទទួលវត្ថុ ដែលគេស្វែងរក គឺពន្លឺត្រាស់ដឹង។

11. ក្នុងសម័យមួយនោះ មានស្តេចមួយព្រះអង្គ ស្ទាត់ជំនាញក្នុងការកាន់អាវុធណាស់។ ថ្ងៃមួយ នៅពេលត្រឡប់មកពីទីលានហាត់ហ្វឹកហ្វឺនមកដំណាក់វិញ ព្រះអង្គបានជួបនឹងយក្សមួយ មានសាច់គង់កាប់មិនមុត។

យក្សនោះ ឈរស្កឹងនៅមុខព្រះអង្គ តែស្តេចគ្មានខ្លាចញញើតសោះ។ ស្តេចបាញ់ព្រួញមួយទៅ តែមិនមុតយក្សសោះ។ ស្តេចចោលលំពែងទៅទៀត តែមិនអាចមុតធ្លុះស្បែកយក្សបានឡើយ។ ស្តេចចោលច្បូក ចោលស្នរជាបន្តបន្ទាប់ទៅទៀត តែយក្សគ្មានឈឺស្បៀបបន្តិចឡើយ។ ស្តេចក៏គ្រវីដាវលោតទៅកាប់យក្ស តែដាវនោះ ត្រូវបាក់ទៅទៀត។ ស្តេចក៏វាយប្រហារយក្សនោះ ដោយប្រើដៃជើងព្រះអង្គ តែគ្មានលទ្ធភាពសោះ ព្រោះយក្សនោះចាប់ឱបរឹតព្រះអង្គយ៉ាងមាំនៅក្នុងរង្វង់ដៃដ៏ធំរបស់វា។ ស្តេចសាកល្បងយកព្រះកេសាព្រះអង្គប្រយុទ្ធតទល់ទៀត តែជាអសារឥតការ។

យក្សថ្លែងថា: «តស៊ូឥតប្រយោជន៍ទេ យើងនឹងហែកឯងស៊ីឥឡូវនេះហើយ»។ ស្តេចឆ្លើយឡើងថា: «ឯងស្មានថាយើងអស់អាវុធ នឹងប្រើប្រាស់តែប៉ុណ្ណោះហើយឬ? យើងគ្មាន

អ្វីនឹងការពារខ្លួនទៀតទេឬ ? តាមពិត យើងនៅមានអាវុធមួយទៀត។ បើហែកយើងស៊ី យើងនឹងបានចូលទៅខ្វះបំផ្លាញក្រពះពោះវៀនឯងជាពុំខាន»។

សេចក្តីក្លាហានរបស់ស្តេច បានធ្វើឲ្យយក្ស ភ័យជាខ្លាំង ។ យក្សសួរថាៈ «តើឯងធ្វើរបៀបម៉េច?»។ ស្តេចឆ្លើយថាៈ «យើងយកឥទ្ធិពលនៃសេចក្តីពិតមកប្រើ»។

យក្សក៏លែងស្តេចទៅ ហើយអង្វរសុំឲ្យបង្រៀនសេចក្តីពិតនោះ។

រឿងនិទាននេះ ប្រដៅអ្នកបួសរៀនទាំងឡាយ ឲ្យមានចិត្តក្លាហាន មានការព្យាយាមខំប្រឹងប្រែង កុំខ្លាចញញើតឧបសគ្គជាច្រើនរាប់មិនអស់ ដែលកើតមានឡើងនៅចំពោះមុខ។

12. ការឡឹតគួរឲ្យស្អប់ និងការឥតអៀនខ្មាស ជាទោសចំពោះមនុស្សលោក។ ប៉ុន្តែការអាប់យស និងការខ្មាសអៀន ការពារមនុស្សលោក។ បុគ្គលទាំងឡាយគោរពមាតាបិតារបស់គេ

វៀមច្បងរបស់គេ បងស្រីប្រុសរបស់គេព្រោះតែគេចាប់អារម្មណ៍នឹងសេចក្ដីអាប់យស ហើយនិងសេចក្ដីអៀនខ្មាស។ កាលណាគេសញ្ជឹងគិតឲ្យដឹតដល់ទៅ ឃើញថា ការទុកកិត្តិយសឲ្យឆ្ងាយពីខ្លួន ហើយនិងការចេះមានចិត្តអៀនខ្មាសដោយសង្កេតមើលទៅអ្នកដទៃ ជាការសមនឹងបានគុណប្រយោជន៍ជាប្រត្យក្ស។

បើបុគ្គលណាមានចិត្តចេះស្ដាយក្រោយ បាបកម្មទាំងឡាយរបស់បុគ្គលនោះនឹងវិនាសអស់។ ប៉ុន្ដែ បើបុគ្គលនោះមានចិត្តមិនចេះស្ដាយក្រោយ បាបកម្មទាំងឡាយរបស់គេ ស្ថិតនៅជាប់នឹងរូបគេរហូត ហើយនឹងតាមផ្ដន្ទាទោសគេមិនចេះចប់។

មានតែបុគ្គលដែលស្ដាប់ឮ យល់ជាក់ ហើយប្រតិបត្តិតាមសិក្ខាបទពិតប្រាកដនុ៎ះទេ ដែលអាចបានទទួលគុណប្រ-យោជន៍អំពី សិក្ខាបទនោះ។ បើបុគ្គលណាបានស្ដាប់ឮសិក្ខាបទពិតប្រាកដនេះហើយ តែមិនប្រតិបត្តិតាម បុគ្គលនោះមុខតែមិនបានសម្រេចក្នុងការស្វែងរកពន្លឺត្រាស់ដឹងទេ។

ការជឿឈ្មោះថា ការគោរពប្រតិបត្តិ ការចេះស្ដាយក្រោយ ការខំប្រឹងប្រែង និងការមានគតិបណ្ឌិត ជាមហាប្រភពនៃ

កម្លាំងសម្រាប់ស្វែងរកពន្លឺត្រាស់ដឹង។ ក្នុងចំណោមគុណ-សម្បត្តិទាំងនេះ ការមានគតិបណ្ឌិតសំខាន់ជាងគេបង្អស់។ ចំពោះគុណសម្បត្តិឯទៀត វាជាទិដ្ឋភាពនៃការប្រកបដោយគតិបណ្ឌិតប៉ុណ្ណោះ។ បុគ្គលណាដែលកំពុងតែបំពេញការព្យាយាម ហើយត្រេកត្រអាលនឹងរឿងលោកិយ សប្បាយនឹងការជជែកគ្នាឥតខ្លឹមសារ បណ្ដោយខ្លួនឲ្យធ្លាក់ទៅក្នុងភាពងោកងុយស្មុគស្មាញ ... 

13. ក្នុងការព្យាយាមដើម្បីបានសម្រេចពន្លឺត្រាស់ដឹង មានអ្នកខ្លះអាចទៅដល់គោលដៅឆាប់រហ័សជាងអ្នកខ្លះទៀត។ ដូច្នេះមិនត្រូវអស់សង្ឃឹមទេ បើកាលណាហើយ ឃើញគេឯងទៀតបានសម្រេចពន្លឺត្រាស់ដឹងមុនយើង។

អ្នករៀនបាញ់ធ្នូ មិនអាចសង្ឃឹមថានឹងបានសម្រេចភ្លាមៗនោះទេ តែគេដឹងថា បើគេហាត់រៀន ដោយព្យាយាមខ្ជាប់ខ្ជួន គេនឹងបានស្ទាត់ជំនាញច្រើនឡើងៗ ជាពុំខាន។ ទន្លេចាប់កកើតមុនដំបូងជាអូរតូចមួយ ហើយរីកធំឡើងៗ រហូតដល់

ទៅជាទន្លេហូរចាក់ទៅក្នុងសមុទ្រ។ ឧទាហរណ៍ទាំងនេះ បង្ហាញឲ្យឃើញថា បើបុគ្គលណាបំពេញការព្យាយាមយ៉ាង អំណត់និងខ្ជាប់ខ្ជួន បុគ្គលនោះប្រាកដជានឹងបានសម្រេចពន្លឺ ត្រាស់ដឹង។

ដូចបានពន្យល់ពីលើមកហើយ បើគេបើកភ្នែកមើល គេ នឹងឃើញសិក្ខាបទនៅគ្រប់ទិសទី។ ដូច្នេះ គេមានផ្លូវច្រើន នឹងបានសម្រេចពន្លឺត្រាស់ដឹង។

សម័យមួយនោះ មានបុរសម្នាក់ដុតធូប ហើយបានសង្កេត ឃើញក្លិនក្រអូប ទៅក៏មិនទៅ មកក៏មិនមក លេចឡើងក៏មិន លេច បាត់ទៅក៏មិនបាត់។ ដោយសារការរាយរងនេះ បុរស នោះបានសម្រេចពន្លឺត្រាស់ដឹង។

មានម្តងនោះ បុរសម្នាក់មុតបន្លានៅបាតជើង។ គាត់ឈឺ ចុកចាប់ជាខ្លាំង ហើយនឹកគិតថា ការឈឺចុកចាប់នេះគ្មានអ្វី ក្រៅពីប្រតិកម្មនៃចិត្តទេ។ ក្រោយពីនោះមក គាត់បានគិត ឃើញថា ចិត្តវារត់លោតគ្មានចេះឈប់ឈរទេ បើកាលណា គេមិនគ្រប់គ្រងវា។ ប៉ុន្តែវាក៏អាចទៅជាបរិសុទ្ធបានដែរ បើ

កាលណាគេត្រួតត្រាវាបាន។ ដោយសារការគិតយល់នេះ បន្តិចក្រោយមក បុរសនោះក៏បានសម្រេចពន្លឺត្រាស់ដឹង។

មានបុរសម្នាក់ទៀត កំណាញ់ស្វិតស្វាញជាទីបំផុត។ ថ្ងៃមួយ នៅពេលដែលគាត់កំពុងតែគិតទៅដល់ចិត្តលោភលន់ របស់គាត់ គំនិតមួយបានមកដល់គាត់ថា ចំណង់លោភលន់របស់អញនេះគ្មានអ្វីក្រៅពីចំនៀរឈើ និងមែកឈើតូចៗ ដែលគតិបណ្ឌិតអាចដុតបំផ្លាញបាននោះទេ។ ការគិតយល់នេះ ជាការចាប់ផ្ដើមបានសម្រេចពន្លឺត្រាស់ដឹងរបស់គាត់។

មានពាក្យប្រៀនប្រដៅពីបូរាណកាលមួយថ្លៃថ្លាថា: «ចូររក្សាចិត្តឲ្យបានរាបស្មើ! បើចិត្តបានរាបស្មើហើយ ពិភពលោកទាំងមូលនឹងបានរាបស្មើដែរ!។ ចូរយើងគិតពិចារណាចំពោះពាក្យប្រៀនប្រដៅនេះ ! ចូរយើងយល់ថា ភាពខុសគ្នាក្នុងពិភពលោកនេះ បណ្ដាលមកពីចិត្តគិតវែកញែកតែប៉ុណ្ណោះ។ ផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ស្របទាំងស្រុងនឹងពាក្យប្រៀនប្រដៅនេះ។ ផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ពិតជាគ្មានព្រំដែនទេ!។

III

# ផ្លូវនៃជំនឿ (សទ្ធា)

1. *ដែលហៅថាសាវ័ករបស់ព្រះពុទ្ធ គឺបុគ្គលដែលប្រគល់កាយថ្វាយជីវិតចំពោះព្រះរតនត្រ័យ ពោលគឺការទទួលយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទុកជាទីពឹងទីរលឹក។ សាវ័ករបស់ព្រះពុទ្ធ កាន់វិន័យគ្រប់គ្រងចិត្ត ទាំងបួន គឺ: សិក្ខាបទ សទ្ធាទាន និង គតិបណ្ឌិត។*

*សាវ័ករបស់ព្រះពុទ្ធ គោរពប្រតិបត្តិវិន័យប្រាំយ៉ាងគឺ: មិនសម្លាប់សត្វ មិនលួចប្លន់ មិនប្រព្រឹត្តអំពើផិតក្បត់ មិនភូតកុហក មិនសេពគ្រឿងស្រវឹង។*

*សាវ័ករបស់ព្រះពុទ្ធ មានជំនឿយ៉ាងមាំទៅលើគតិធម៌ល្អឥតខ្ចោះរបស់ព្រះពុទ្ធ។ គេខិតខំចៀសវាងការលោភលន់ការខឹងក្រោធ ហើយខិតខំធ្វើទាន។ គេយល់ច្បាស់នូវច្បាប់ស្ដីអំពីហេតុនិងផល ដោយគិតទុកក្នុងចិត្តជានិច្ចអំពីភាពមិនឋិតថេរនៃជីវិត ហើយគេប្រតិបត្តិតាមច្បាប់គតិធម៌។*

ដើមឈើដែលទ្រេតទៅទិសខាងកើត នឹងរលំដួលទៅទិសខាងកើត ជាធម្មតា។ ដូចគ្នានេះ បុគ្គលដែលស្តាប់ហើយធ្វើតាមឱវាទរបស់ព្រះពុទ្ធ ហើយជឿប្រាកដលើព្រះអង្គ ពិតជានឹងបានទៅកើតក្នុងដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ។

2. ដូចបានពោលយ៉ាងជាក់ច្បាស់មកហើយថា បុគ្គលណាជឿហើយប្រតិបត្តិតាមរតនៈទាំងបីរបស់ព្រះពុទ្ធ ពោលគឺៈ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បុគ្គលនោះហៅថា សាវ័ករបស់ព្រះពុទ្ធ។

ព្រះពុទ្ធគឺមនុស្សលោកមួយរូប ដែលបានសម្រេចនូវការត្រាស់ដឹងដ៏ប្រសើរបំផុត ហើយយកការត្រាស់ដឹងនោះមកប្រើ ដើម្បីស្រោចស្រង់សត្វលោក។ ព្រះធម៌គឺសេចក្តីពិត គឺព្រលឹងនៃការត្រាស់ដឹង ហើយនិងសិក្ខាបទដែលពន្យល់បញ្ជាក់អំពីការត្រាស់ដឹងនោះ។ ព្រះសង្ឃ គឺក្រុមអ្នកទ្រទ្រង់ភេទជាបព្វជិត ជឿ និងប្រតិបត្តិតាម ព្រះពុទ្ធ ព្រះធម៌ ដោយចិត្តស្មោះត្រង់សុទ្ធសាធ។

យើងនិយាយអំពី ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហាក់ដូចជាវត្ថុទាំងបីនេះផ្សេងៗគ្នា តែតាមពិត គឺជាវត្ថុតែមួយគត់។ ព្រះពុទ្ធចេញស្តែងឡើងនៅក្នុងព្រះធម៌ ព្រះធម៌សម្តែងឡើងដោយសហគមន៍ព្រះសង្ឃ។ ដូច្នេះ ការជឿតាមព្រះធម៌ ហើយគោរពប្រតិបត្តិព្រះសង្ឃ ដូចគ្នានឹងការមានជំនឿមោះមុតទៅលើព្រះពុទ្ធដែរ។ បើនិយាយបែបម្យ៉ាងទៀត ការមានជំនឿមោះមុតទៅលើព្រះពុទ្ធ បានន័យថា ជឿតាមព្រះធម៌ហើយគោរពប្រតិបត្តិព្រះសង្ឃ។

ដូច្នេះឃើញថា បុគ្គលរាល់រូបអាចចាកផុតពីទុក្ខ ហើយបានសម្រេចពន្លឺត្រាស់ដឹង ដោយគ្រាន់តែមានជំនឿមោះមុតទៅលើព្រះពុទ្ធ។ ព្រះពុទ្ធជាអ្នកបានត្រាស់ដឹងគ្រប់ ព្រះអង្គស្រឡាញ់គ្រប់សត្វលោកទាំងអស់ ដូចជាកូនបង្កើតរបស់ព្រះអង្គ។ បុគ្គលណាទុកព្រះពុទ្ធជាឪពុកបង្កើតរបស់ខ្លួន បុគ្គលនោះជាកូនបង្កើតម្នាក់របស់ព្រះពុទ្ធ ហើយនឹងបានសម្រេចពន្លឺត្រាស់ដឹង។

បុគ្គលដែលទុកព្រះពុទ្ធដូចខាងលើនេះ នឹងត្រូវបានគាំទ្រដោយគតិធម៌របស់ព្រះអង្គ ហើយនឹងត្រូវបានប្រោះព្រំដោយគន្ធពិដោរនៃធម៌មេត្តារបស់ព្រះអង្គ។

3. នៅក្នុងលោកនេះគ្មានអ្វីដែលអាចនាំមកនូវគុណប្រយោជន៍ឲ្យបានធំធេងជាងការមានជំនឿលើព្រះពុទ្ធទេ។ ការបានឮព្រះនាមព្រះពុទ្ធ ហើយមានចិត្តសប្បាយរីករាយ ជឿតាមព្រះអង្គតែក្នុងមួយរយៈវេលាប៉ុណ្ណោះ ជាការបានរង្វាន់ធំឥតឧបមា។

ដូច្នេះ បុគ្គលរាល់រូបត្រូវតែសប្បាយរីករាយក្នុងការខំស្វែងរកសិក្ខាបទរបស់ព្រះពុទ្ធ ទោះជាត្រូវឆ្លងកាត់ភ្លើងដែលកំពុងតែឆេះយ៉ាងសន្ធោសន្ធៅក៏ដោយ។

ការបានជួបប្រទះនឹងគ្រូអាចារ្យ ដែលអាចពន្យល់ព្រះធម៌បាន ជាការក្រ។ ការបានជួបនឹងព្រះពុទ្ធ ជាការក្រជាងនេះ។ តែការជឿតាមសេចក្ដីប្រៀនប្រដៅរបស់ព្រះពុទ្ធ ជាការរឹតតែកម្រណាស់ទៅទៀត។

នៅពេលនេះ យើងបានជួបនឹងអ្នកចេះពន្យល់ព្រះធម៌ ដែលកម្រនឹងបានជួប ហើយយើងបានស្តាប់ឮសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលកម្រនឹងបានស្តាប់ យើងត្រូវតែសប្បាយរីករាយ ជឿតាម ហើយទុកចិត្តលើព្រះពុទ្ធ។

4. ក្នុងរយៈដំណើរដ៏វែងឆ្ងាយនៃជីវិតមនុស្សលោក ជំនឿមោះមុតជាមិត្តរួមដំណើរប្រសើរជាងគេបង្អស់ ជាគ្រឿងធ្វើឲ្យបានត្រជាក់ស្រួលប្រសើរជាងគេបង្អស់ ជាសម្បត្តិធំជាងគេបង្អស់។

ជំនឿមោះមុត ជាដៃដែលទទួលយកព្រះធម៌ គឺជាដៃបរិសុទ្ធដែលទទួលយកគ្រប់គុណធម៌។ ជំនឿមោះមុត ជាភ្លើងដែលឆេះបំផ្លាញគ្រប់អសុចិភាពនៃចំណង់លោកិយ ជាអ្នកនាំផ្លូវទៅកាន់គោលដៅ។

ជំនឿមោះមុត កំចាត់សេចក្តីលោភលន់ សេចក្តីខ្លាចញញើត សេចក្តីឡឹត។ ជំនឿមោះមុត បង្រៀនឲ្យចេះមានការគួរសម មានការគោរពរាប់អានអ្នកដទៃ។ ជំនឿមោះមុតរំដោះឲ្យរួចពីចំណងនៃកាលៈទេសៈ បណ្តាលឲ្យមានសេចក្តីក្លាហាន

នៅចំពោះមុខឧបសគ្គ ផ្តល់កម្លាំងដើម្បីជម្នះនូវចំណង់អាក្រក់។ ជំនឿមោះមុត ធ្វើឲ្យមនុស្សអាចរក្សាអំពើទាំងឡាយរបស់ខ្លួនបាន នៅភ្លឺថ្លា នៅបរិសុទ្ធ។ ជំនឿមោះមុត ធ្វើឲ្យសតិបានប្រកបដោយគតិធម៌។

ជំនឿមោះមុតបណ្តាលឲ្យមានសេចក្តីក្លាហាន ក្នុងដំណើរផ្លូវវែងឆ្ងាយគួរឲ្យធុញទ្រាន់។ ជំនឿមោះមុតដឹកនាំយើងទៅកាន់ពន្លឺត្រាស់ដឹង។

ជំនឿមោះមុតបណ្តាលឲ្យយើងស្រមៃឃើញ ហាក់ដូចជាបានស្ថិតនៅជិតព្រះពុទ្ធ។ ជំនឿមោះមុត នាំយើងទៅដាក់ដល់ទីកន្លែងដែលព្រះហស្តព្រះពុទ្ធនៅរង់ចាំទទួលជ្រោងយើង។ ជំនឿមោះមុត ធ្វើឲ្យចិត្តរឹងរូសប្រកបដោយអត្តទត្ត-ភាពរបស់យើងទៅជាទន់។ ជំនឿមោះមុតបណ្តាលឲ្យយើងមានចិត្តជាមិត្ត មានចិត្តចេះយោគយល់។

5. បុគ្គលណា មានជំនឿមោះមុត បុគ្គលនោះនឹងបានប្រកបដោយគតិបណ្ឌិត ចេះទទួលស្គាល់គ្រប់សេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធដែលគេបានស្តាប់ៗ។ បុគ្គលណាមានជំនឿមោះមុតបុគ្គលនោះនឹងបានប្រកបដោយគតិបណ្ឌិតអាចនឹងមើល

ឃើញថា វត្ថុទាំងឡាយគ្រាន់តែជាសភាពខាងក្រៅ ដែលកើតមានឡើងស្របទៅតាមច្បាប់ស្តីពីហេតុ និងផលតែប៉ុណ្ណោះ។ ដូច្នេះ បុគ្គលទាំងឡាយដែលមានជំនឿមោះមុត អាចនឹងមានចិត្តចេះព្រមទទួលដោយក្តីអំណត់ នូវគ្រប់រឿងហេតុដែលមកដល់ខ្លួន ហើយនិងមានកម្លាំងគ្រប់គ្រាន់ដើម្បីនឹងសម្របខ្លួនទៅតាមកាលៈទេសៈដោយចិត្តស្ងប់។

ជំនឿមោះមុត ផ្តល់ដល់បុគ្គលអ្នកជឿនូវគតិបណ្ឌិតចេះទទួលស្គាល់អំពីភាពមិនឋិតថេរនៃជីវិត នូវការមិនចេះភ្ញាក់ផ្អើល ឬកើតទុក្ខនឹងគ្រប់រឿងហេតុទាំងអស់ ដែលកើតមានដល់ខ្លួន សូម្បីរឿងហេតុនោះជាទីអវសាននៃជីវិតរបស់ខ្លួនក៏ដោយ ព្រោះគេយល់ថាកាលៈទេសៈ ហើយនិងសភាពជាខាងក្រៅអាចប្រែប្រួល តែសភាពពិតជាខាងក្នុង នៃជីវិតនៅឋិតថេរជានិច្ច មិនចេះប្រែប្រួលទេ។

ជំនឿមោះមុតមានទ្រង់ទ្រាយសំខាន់បីគឺៈ ការចេះដាក់ខ្លួនឲ្យសុភាពរាបសា ការចេះមានសេចក្តីរីករាយ មានសេចក្តីគោរពដោយស្មោះចំពោះគុណធម៌អ្នកដទៃ ការចេះមានសេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅចំពោះព្រះពុទ្ធ។

បុគ្គលរាល់រូប តោងតែបណ្តុះរក្សានូវសភាពទាំងបីនៃជំនឿមោះមុតនេះ គឺថា: ទី១ ត្រូវតែឆាប់ដឹងកំហុស និងអំពើសៅហ្មងរបស់ខ្លួន ត្រូវតែចេះខ្មាសអៀនហើយទទួលសារភាពនូវអំពើសៅហ្មងទាំងនោះ។ ទី២ ត្រូវចេះទទួលស្គាល់ដោយយកចិត្តទុកដាក់ នូវគុណសម្បត្តិ និងអំពើល្អរបស់អ្នកដទៃ ហើយកោតសរសើរអំពើល្អរបស់អ្នកទាំងនោះ។ ទី៣ ត្រូវចេះមានសេចក្តីប្រាថ្នាចង់ប្រព្រឹត្តតាមព្រះពុទ្ធ និងរស់នៅជាមួយព្រះអង្គ។

ចិត្តដែលពេញទៅដោយជំនឿមោះមុត គឺចិត្តស្មោះត្រង់ចិត្តជ្រៅ ចិត្តដែលមានសេចក្តីសប្បាយរីករាយដោយបានព្រះពុទ្ធដឹកនាំទៅដែនដីបរិសុទ្ធរបស់ព្រះ អង្គ។

ព្រះពុទ្ធផ្តល់អានុភាពទៅជំនឿមោះមុត ដែលដឹកនាំសត្វលោកទៅដាក់ក្នុងដែនដីបរិសុទ្ធ អានុភាពដែលធ្វើឲ្យសត្វលោកបានបរិសុទ្ធ អានុភាពដែលការពារសត្វលោកឲ្យរួចផុតពីសេចក្តីយល់ច្រឡំអំពីអាត្មាអញ។ បុគ្គលទាំងឡាយណាមានជំនឿមោះមុតតែក្នុងមួយរយៈពេលក៏ដោយ ឲ្យតែបានស្តាប់

ឮព្រះនាមព្រះពុទ្ធ ដែលផ្សព្វផ្សាយពាសពេញពិភពលោកទាំងមូល បុគ្គលទាំងនោះ នឹងបានទៅកើតក្នុងដែនដីបរិសុទ្ធ។

6. ជំនឿមោះមុត ពុំមែនជាវត្ថុមួយ ដែលត្រូវបានបន្ថែមទៅក្នុងវិញ្ញាណមនុស្សលោកិយទេ តែគឺជាការសម្ដែងចេញឲ្យឃើញឡើងនូវវិញ្ញាណក្នុងសភាពជាព្រះពុទ្ធ។ ហេតុនេះអ្នកដែលយល់ ស្គាល់ព្រះពុទ្ធ គឺជាព្រះពុទ្ធមួយអង្គ។ អ្នកដែលមានជំនឿមោះមុតទៅលើព្រះពុទ្ធ គឺជាព្រះពុទ្ធមួយអង្គ។

ការស្វែងរកឲ្យឃើញសភាពព្រះពុទ្ធរបស់ខ្លួនទុំះ ជាការក្រ។ ការរក្សាវិញ្ញាណរបស់ខ្លួនឲ្យបាននៅបរិសុទ្ធនាកណ្ដាលភាពជោរនោចនៃសេចក្ដីលោភលន់ សេចក្ដីខឹងក្រោធ សេចក្ដីប្រាថ្នាលោកិយ ជាការក្រ។ តែជំនឿមោះមុតអាចធ្វើឲ្យការខំប្រឹងប្រែងទាំងនេះប្រព្រឹត្តទៅបាន។

នៅក្នុងព្រៃ ឈើឥរន្ធដែលប្រកបដោយជាតិពុល មានតែដើមឥរន្ធទេដែលអាចដុះបាន ដើមចន្ទន៍ដែលមានក្លិនក្រអូបមិនអាចដុះបានទេ។ គឺជាអព្ភូតហេតុមួយ ដែលដើមចន្ទន៍ប្រកបដោយក្លិនក្រអូបឈ្មុយឈ្ងប់មួយដើមដុះក្នុងព្រៃឈើ

ឥវន្ទ។ ក៏ពិតជាអព្ភូតហេតុមួយដែរ ដែលជំនឿមោះមុតទៅលើព្រះពុទ្ធ អាចកើតឡើងបាននៅក្នុងចិត្តមនុស្សលោក។

ហេតុនេះ ការជឿមោះមុតចំពោះព្រះពុទ្ធ ហៅថា «ជំនឿគ្មានឫស» បានន័យថា គ្មានឫសនៅក្នុងចិត្តមនុស្សលោកទេ ឫសនៃជំនឿមោះមុតនេះ មាននៅក្នុងចិត្តប្រកបដោយសេចក្ដីករុណាអាសូរនៃព្រះពុទ្ធ។

7. ជំនឿមោះមុត ផ្ដល់ផលដ៏ប្រសើរវិសុទ្ធវិសាល។ ប៉ុន្តែជំនឿមោះមុតកម្រនឹងកើតមាននៅក្នុងចិត្ត ដែលព្រងើយកន្តើយ។ ជាពិសេស មានមន្ទិលប្រាំយ៉ាងដែលលាក់បំពួនខ្លួននៅក្នុងចិត្តមនុស្សលោក ហើយដែលចេះតែខារខាំងរាំងរាចិត្តមនុស្សកុំឲ្យមានជំនឿមោះមុត។

ទី១ គឺមន្ទិលសង្ស័យចំពោះគតិធម៌របស់ព្រះពុទ្ធ។ ទី២ គឺមន្ទិលសង្ស័យចំពោះសិក្ខាបទរបស់ព្រះពុទ្ធ។ ទី៣ គឺមន្ទិលសង្ស័យទៅលើអ្នកដែលផ្សាយសិក្ខាបទព្រះពុទ្ធ។ ទី៤ គឺមន្ទិលសង្ស័យចំពោះរបៀបនិងវិធីព្យាយាមហាត់រៀនផ្សេងៗ ដែលត្រូវយកមកប្រតិបត្តិ ក្នុងការដើរតាមផ្លូវប្រសើរឧត្តម។ ទី៥គឺ

មានបុគ្គលខ្វះ ដោយហេតុតែមានចិត្តក្រអឺតក្រអោង និងខ្វះសេចក្តីអំណត់ មានមន្ទិលសង្ស័យទៅលើសេចក្តីស្មោះត្រង់នៃអ្នកដែលយល់ហើយប្រតិបត្តិតាមសិក្ខាបទព្រះពុទ្ធ។

ដោយពិត គ្មានអ្វីដែលគួរឲ្យខ្លាចជាងការមានទម្លាប់មានមន្ទិលសង្ស័យទាំងនេះទេ។ គឺមន្ទិលសង្ស័យទាំងនេះហើយដែលប្រឆាំងនឹងមនុស្សលោក។ គឺជាពិសពុលមួយ ដែលបំបែកបំបាក់មិត្តភាព ដែលបំបែកបំបាក់ចំណងមេត្រីភាពជាមួយអ្នកដទៃគឺជាបន្លា ដែលមុតឈឺចុកចាប់ គឺជាដាវដែលកាត់ផ្តាច់ជីវិត។

ពន្លកនៃជំនឿមោះមុត ត្រូវបានសាបព្រោះបណ្តុះដោយសេចក្តីករុណាអាសូររបស់ព្រះពុទ្ធ អស់កាលជាយូរណាស់មកហើយ។ កាលណាគេមានជំនឿមោះមុត គេត្រូវតែយល់រឿងនេះឲ្យជាក់ ហើយត្រូវតែមានសេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅដល់សប្បុរសធម៌របស់ព្រះពុទ្ធ។

បុគ្គលទាំងឡាយត្រូវតែដឹងថា ជំនឿមោះមុតកើតមានឡើងអំពីសេចក្តីករុណាអាសូររបស់ព្រះពុទ្ធ។ តាំងពីយូរអង្វែងណាស់មកហើយ ព្រះពុទ្ធបានបញ្ចូលពន្លឺបរិសុទ្ធនៃសទ្ធានេះ ទៅក្នុងចិត្តមនុស្សលោក បណ្តេញកំចាត់អន្ធភាពនៃសេចក្តីល្ងង់

ខ្ញៅពីមនុស្សលោក។ អ្នកដែលរីករាយនឹងសទ្ធាជ្រះថ្លានៅពេលបច្ចុប្បន្ននេះ នឹងបានទទួលមរតកសម្បត្តិទៅអនាគត។

ទោះបីជាប្រកបការរស់នៅ យ៉ាងសាមញ្ញរបៀបណា ក៏ដោយអ្នកដែលភ្ញាក់រលឹក មានសទ្ធាជ្រះថ្លាដែលបំភ្លឺជានិច្ចនិរន្តរ៍ដោយសេចក្តីករុណាអាសូររបស់ព្រះពុទ្ធ នឹងបានទៅកើតក្នុងដែនដីបរិសុទ្ធ។

ពិតណាស់ការកើតនៅក្នុងលោកនេះ ជាការក្រ។ ការបានស្តាប់ឮព្រះធម៌ ជាការក្រ។ ប៉ុន្តែ ការមានសទ្ធាជ្រះថ្លា រឹតតែក្រជាងនេះទៅទៀត។ ដូច្នេះ បុគ្គលរាល់រូបតោងតែខំប្រឹងស្តាប់សេចក្តីទូន្មានរបស់ព្រះពុទ្ធ។

IV

## ពុទ្ធឱវាទ

1. «វាបានជេរអញ វាបានចំអកឡកឡឺយឲ្យអញ វាបានវាយអញ»។ ដរាបណា បុគ្គលណានៅតែរក្សាគំនិតទាំងនេះ កំហឹងរបស់គេនឹងមិនចប់ទេ។

ដរាបណាគំនុំនៅតែមានក្នុងចិត្ត កំហឹងក៏នៅតែមានដែរ។ ប៉ុន្តែបើកាលណាគំនុំវិនាសអស់ហើយកំហឹងក៏វិនាសអស់ទៅដែរ។

ផ្ទះដែលដំបូលធ្វើមិនល្អ ធ្លុះធ្លាយដោយអន្ទើ ទឹកភ្លៀងនឹងលិចចូលទៅក្នុងផ្ទះ។ យ៉ាងណាមិញ ចិត្តដែលបង្ហាត់មិនបានល្អ ហើយដែលមិនអាចត្រួតត្រាបាននោះ គំនិតលោភលន់នឹងចូលទៅញាំញីបាន។

ការនៅទំនេរស្ងៀម ជាផ្លូវទៅកាន់សេចក្តីស្លាប់។ ការឧស្សាហ៍រៀសរវៃ ជាផ្លូវសម្រាប់ជីវិតរស់នៅ។ បុគ្គលឆ្កួតលេលា នៅទំនេរស្ងៀម។ ចំណែកបុគ្គលជាបណ្ឌិត មានការឧស្សាហ៍រៀសរវៃ។

អ្នកធ្វើព្រួញ ខំធ្វើព្រួញឲ្យបានត្រង់។ ដូចគ្នានេះ បុគ្គលជាបណ្ឌិត ខំរក្សាចិត្តរបស់គេឲ្យបានត្រឹមត្រង់។

ចិត្តសៅហ្មង កម្រើកជានិច្ច លោតពីទីមួយទៅទីមួយ ពិបាកនឹងគ្រប់គ្រងណាស់។ ផ្ទុយទៅវិញ ចិត្តស្ងប់ មានភាពសុខស្ងប់។ ដូច្នេះ ការរក្សាចិត្តឲ្យបាននៅស្ងប់ ជាគតិបណ្ឌិត។

ពុំមែនសត្រូវទេ គឺពិតជាចិត្តរបស់ខ្លួនផ្ទាល់តែម្តង ដែលដឹកនាំមនុស្សទៅកាន់ផ្លូវអាក្រក់។

បុគ្គលដែលចេះការពារចិត្តរបស់ខ្លួន ទប់ទល់នឹងសេចក្តីលោភលន់ សេចក្តីខឹងក្រោធ អំពើអាក្រក់ នឹងបានប្រកបសេចក្តីសុខស្ងប់ពិតប្រាកដមិនចេះចប់។

2. មានវាចាល្អតែមិនធ្វើតាម អាចប្រៀបបានទៅនឹងផ្កាមានពណ៌ស្រស់ល្អតែឥតក្លិនក្រអូប។

គន្ធពិដោរនៃផ្កា មិនក្រអូបបញ្ច្រាសខ្យល់ទេ។ តែកេរ្តិ៍ឈ្មោះរបស់មនុស្សល្អ ផ្សព្វផ្សាយគ្រប់ទិសទីបញ្ច្រាសខ្យល់បាន។

រាត្រីកាលហាក់ដូចជាយូរណាស់ ចំពោះអ្នកដេកមិនលក់ ផ្លូវដើរហាក់ដូចជាឆ្ងាយណាស់ ចំពោះអ្នកធ្វើដំណើរដោយលំបាក។ ដូចគ្នានេះ ពេលវេលានៃការយល់ច្រឡំនិងទុក្ខព្រួយហាក់ដូចជាវែងណាស់ ចំពោះអ្នកមិនយល់សិក្ខាបទពិតប្រាកដ។

កាលណាគេធ្វើដំណើរ គេគួរតែដើរជាមួយនឹងមិត្តម្នាក់

ដែលមានសតិប្រាជ្ញាស្មើនឹងគេ ឬខ្ពស់ជាងគេ។ ប៉ុន្តែ គេគួរដើរម្នាក់ឯងល្អជាងដើរជាមួយនឹងមនុស្សឆ្កួតលេលា។

គេខ្លាចសត្វសាហាវ តែគេគួរខ្លាចមិត្តអាក្រក់ ច្រើនជាងសត្វសាហាវ។ សត្វសាហាវបណ្តាលឲ្យមានរបួសត្រឹមតែរូបកាយ តែមិត្តអាក្រក់បណ្តាលឲ្យមានរបួសដល់បេះដូង។

ដរាបណា គេមិនអាចគ្រប់គ្រងចិត្តរបស់គេបាន គេមិនអាចបោះបង់គំនិតថា «នេះជាកូនរបស់អញ» «នេះជាទ្រព្យកំណាប់របស់អញ» បានទេ។ បុគ្គលឆ្កួតលេលា រងទុក្ខនឹងគំនិតរបៀបនេះ។

ឆ្កួតហើយដឹងខ្លួនថាឆ្កួត វាប្រសើរជាជាងឆ្កួតហើយនឹកស្មានថាខ្លួនជាបណ្ឌិត។

ស្លាបព្រាមិនអាចដឹងរសជាតិនៃម្ហូប ដែលដួសឡើងទុំះទេ។ យ៉ាងណាមិញ បុគ្គលឆ្កួតមិនអាចយល់គតិបណ្ឌិតរបស់អ្នកប្រាជ្ញបណ្ឌិតបានទេ ទោះបីជាបុគ្គលឆ្កួតនោះរស់នៅជាមួយអ្នកប្រាជ្ញបណ្ឌិតនោះក៏ដោយ។

តាមធម្មតា ដូចជាទឹកដោះស្រស់ដែលមិនងាយនឹងកករឹងភ្លាមៗ អំពើអាក្រក់មិនផ្តល់ហេតុផលភ្លាមៗទេ។ អំពើអាក្រក់

ដូចជារងើកភ្លើងដែលកប់ក្នុងផេះ ហើយដែលនៅទីបំផុតឆេះឆ្លោឡើង។

ការសង្វាតរកប្រយោជន៍ឯកសិទ្ធិ រកបានទ្ធរស័ក្តិ រកកម្រៃ រកកិត្តិយស ជាការឆ្កួត។ ការប្រាថ្នាទៅលើវត្ថុទាំងនេះមិនអាចនាំមកនូវសុភមង្គលបានទេ ផ្ទុយទៅវិញវារឹតតែបន្ថែមសេចក្តីទុក្ខព្រួយ។

មិត្តល្អដែលបង្ហាញសេចក្តីយល់ច្រឡំ និងកំហុសរបស់អ្នកដល់អ្នក ដែលស្តីប្រដៅអ្នកអំពីអំពើអាក្រក់របស់អ្នក គួរជាទីគោរព បីដូចជាមិត្តនោះបានប្រាប់ទីលាក់កំណប់មួយដល់អ្នក។

3. បុគ្គលដែលសប្បាយរីករាយនឹងទទួលការទូន្មានល្អ អាចដេកលក់ដោយសុខស្ងប់ព្រោះចិត្តរបស់គេត្រូវបានលាងស្អាត។

ជាងធ្វើផ្ទះ ខំធ្វើធ្នឹមផ្ទះឲ្យបានត្រង់ល្អ។ អ្នកធ្វើព្រួញខំធ្វើព្រួញឲ្យបានត្រឹមត្រូវតាមកំហឹត។ អ្នកជីកប្រឡាយបង្ហូរទឹកបញ្ចូលស្រែ ខំធ្វើយ៉ាងណាឲ្យទឹកបានហូរស្រួល។ ដូចគ្នានេះ បុគ្គលជាបណ្ឌិត ខំគ្រប់គ្រងចិត្តរបស់គេឲ្យមានដំណើរស្រួលឲ្យមានភាពត្រឹមត្រង់។

ដុំថ្មធំ មិនអាចរញ្ជួយដោយសារខ្យល់ទេ។ ដូចគ្នានេះ ចិត្តរបស់បុគ្គលជាបណ្ឌិត មិនអាចរញ្ជួយដោយសារកិត្តិយស ឬការប្រមាថមើលងាយទេ។

ជម្នះខ្លួនឯងបាន ជាមហាជោគជ័យមួយ ធំជាងឈ្នះសត្រូវមួយពាន់នាក់ក្នុងលានប្រយុទ្ធទៅទៀត។

រស់តែមួយថ្ងៃ ហើយបានស្តាប់ឮសេចក្តីប្រៀនប្រដៅវិសុទ្ធល្អ ប្រសើរជាជាងរស់មួយរយឆ្នាំ ហើយពុំបានស្តាប់ឮសេចក្តីទូន្មានល្អវិសុទ្ធ។

បើស្រឡាញ់ខ្លួន តោងតែឃ្លាំមើលវាជានិច្ចកុំឲ្យវាធ្លាក់ទៅក្នុងចំណង់អាក្រក់។

លោកនេះជាភ្លើងឆេះជានិច្ច ឆេះដោយភ្លើងលោកលន់ភ្លើងកំហឹង ភ្លើងល្ងង់ខ្លៅ។ តោងតែរត់គេចពីគ្រោះថ្នាក់ទាំងនេះជាបន្ទាន់។

លោកនេះដូចជាពពុះទឹក ដូចជាសរសៃសំបុកពីងពាង ដូចជាក្អែលនៃក្អមកខ្វក់។ បុគ្គលរាល់រូបតោងតែរក្សាការពារភាពបរិសុទ្ធនៃចិត្តរបស់ខ្លួនជានិច្ច។

4. ចូរចៀសវាងអំពើអាក្រក់ទាំងអស់ ចូរស្វែងរកអំពើល្អ ចូរ

រក្សាចិត្តឲ្យបានបរិសុទ្ធៈ ទាំងនេះហើយ ជាសេចក្ដីទូន្មានរបស់ព្រះពុទ្ធ។

សេចក្ដីអំណត់ ជាវិន័យមួយក្នុងចំណោមវិន័យដែលពិបាកជាងគេបង្អស់។ ប៉ុន្តែ មានតែអ្នកមានអំណត់ទេ ដែលត្រូវបានទទួលជោគជ័យ នៅទីបំផុត។

កាលណាគេកើតមានគំនុំ គេត្រូវតែកំចាត់គំនុំនោះចោល។ កាលណាគេមានទុក្ខព្រួយ គេត្រូវតែកំចាត់ទុក្ខព្រួយនោះចោល។ កាលណាគេមានចិត្តបាក់ទៅលើ សេចក្ដីលោភលន់ គេត្រូវតែកំចាត់សេចក្ដីលោភលន់នោះចោល។ ដើម្បីរស់នៅក្នុងជីវភាពប្រកបដោយសប្បុរសធម៌ ត្រូវតែមើលមកខ្លួនឯងថា គ្មានអ្វីទាំងអស់ ដែលជាកម្មសិទ្ធិរបស់ខ្លួន។

មានសុខភាពល្អ ជាអត្ថប្រយោជន៍ធំមួយ។ សប្បាយរីករាយនឹងឃើញគេឯទៀតមានបាន វាប្រសើរជាជាងមានសម្បត្តិស្ដុកស្ដម្ភផ្ទាល់ខ្លួនឯង។ ធ្វើឲ្យអ្នកឯទៀតមានការទុកចិត្តជាសញ្ញាមិត្តភាពពិតប្រាកដ។ បានសម្រេចពន្លឺត្រាស់ដឹងជាសុភមង្គលខ្ពស់បំផុត។

កាលណា គេបានវៀរចាកអំពើអាក្រក់ កាលណាគេបាន

ប្រកបអារម្មណ៍ស្ងប់ កាលណាគេបានមានចិត្តរីករាយនឹងទទួលយកដំបូន្មានល្អ គេនឹងបានចាកផុតពីសេចក្តីបារម្ភខ្លាច។

ចូរកុំជំពាក់ចិត្តនឹងអ្វីៗ ដែលអ្នកចូលចិត្ត ចូរកុំរុញច្រានចោលអ្វីៗ ដែលអ្នកមិនចូលចិត្ត។ សេចក្តីព្រួយ សេចក្តីខ្លាច និងសេចក្តីជាប់ជំពាក់ទាំងនេះ មកអំពីការចូលចិត្ត និងការមិនចូលចិត្តនេះឯង។

5. ច្រែះកើតចេញមកអំពីដែក ហើយស៊ីទម្លុះដែក។ ដូចគ្នានេះ អំពើអាក្រក់កើតចេញអំពីចិត្ត ហើយស៊ីទម្លុះចិត្ត។

សៀវភៅដែលគេមិនបើកមើលជារឿយៗ ឆាប់ជាប់ធូលី។ ផ្ទះដែលគេមិនជួសជុលឲ្យទាន់ពេលវេលា មុខជានឹងទ្រុតទ្រោមបាក់បែក។ ដូចគ្នានេះ បុគ្គលដែលរស់នៅក្នុងភាពទំនេរខ្ជិល នឹងទៅជាអសុចិមួយរំពេច។

អំពើអាសអាភាស នាំឲ្យខូចកិត្តិនាមនារី។ ការកំណាញ់ស្វិត នាំឲ្យខូចទាន។ ដូចគ្នានេះ អំពើអាក្រក់នាំឲ្យខូចជីវិតបច្ចុប្បន្ន និងជីវិតអនាគត។

មន្ទិលសៅហ្មងដែលគួរខ្លាចជាងគេបង្អស់ គឺមន្ទិលសៅ

ហ្មង់នៃសេចក្តីល្ងង់ខ្លៅ។ គេមិនអាចសង្ឃឹមនឹងធ្វើខ្លួន ហើយនិងចិត្តរបស់គេ ឲ្យបានបរិសុទ្ធទេ ដរាបណាគេមិនកំចាត់សេចក្តីល្ងង់ខ្លៅចេញ។

ការរអិលធ្លាក់ទៅក្នុងអំពើឥតអៀនខ្មាស ការឡើងចិត្តគឃើន ការឡើងឡឹតក្រអឺតក្រអោងដូចមាន់គក ការប្រព្រឹត្តអាក្រក់ទៅលើអ្នកដទៃ ដោយគ្មានចិត្តចេះនឹកស្តាយក្រោយជាការងាយស្រួលណាស់។

ប៉ុន្តែ ការធ្វើខ្លួនឲ្យសុភាពរាបសា ការចេះគោរពនិងផ្តល់កិត្តិយសដល់អ្នកដទៃ ការមិនជាប់ជំពាក់ចិត្ត ការរក្សាគំនិតនិងអំពើរបស់ខ្លួនឲ្យបានស្អាតបរិសុទ្ធ ការធ្វើខ្លួនឲ្យបានជាបណ្ឌិតជាការពិបាក។

ការមើលឃើញកំហុសអ្នកដទៃ ជាការងាយស្រួល ប៉ុន្តែការមើលឃើញកំហុសរបស់ខ្លួនឯងផ្ទាល់ ជាការពិបាក។ គេប្រកាសកំហុសអ្នកដទៃយ៉ាងព្នរំពង តែគេលាក់កំហុសរបស់គេផ្ទាល់ដូចជាអ្នកលេងបៀលាក់សន្លឹកបៀ។

មេឃាមិនទុកដាននៃសត្វបក្សាបក្សី ដាននៃផ្សែង ឬដាននៃខ្យល់ព្យុះទេ។ សេចក្តីទូន្មានអាក្រក់ មិនដឹកនាំទៅកាន់ពន្លឺ

ត្រាស់ដឹងទេ។ នៅក្នុងលោកនេះ គ្មានអ្វីដែលមិនប្រែប្រួលទេ។ ប៉ុន្តែ អ្នកបានសម្រេចពន្លឺត្រាស់ដឹង នឹងបានស្ថិតនៅក្នុងសេចក្តីសុខស្ងប់ ឥតប្រែប្រួលរហូត។

6. ដូចជាឆ្មាំដែលយាមរក្សាទ្វារវាំងប្រាសាទ បុគ្គលរាល់រូបត្រូវតែរក្សាការពារចិត្តរបស់ខ្លួន ទប់ទល់នឹងសត្រូវទាំងខាងក្រៅទាំងខាងក្នុង ហើយកុំប្រហែសវាឲ្យសោះ។

យើងជាម្ចាស់លើខ្លួនយើង យើងទីពឹងលើខ្លួនយើង។ ហេតុនេះយើងតោងតែគ្រប់គ្រងខ្លួនយើងផ្ទាល់។

ជំហានទីមួយ ក្នុងការរំដោះវិញ្ញាណឲ្យរួចពីច្រវាក់ និងចំណងលោកិយ គឺត្រូវតែគ្រប់គ្រងចិត្តរបស់ខ្លួន ត្រូវតែចៀសវាងការនិយាយច្រើនឥតប្រយោជន៍ ត្រូវតែមានស្មារតីប្រុងប្រយ័ត្ន។

ព្រះអាទិត្យបំភ្លឺលោកនៅពេលថ្ងៃ ព្រះចន្ទធ្វើឲ្យរាត្រីកាលមានសម្រស់ អាវក្រោះធ្វើឲ្យទាហានរឹតតែបានឡើងខែង។ ដូចគ្នានេះ ការចម្រើនភាវនាដោយស្ងប់ជាកិច្ចសម្គាល់អ្នកដែលស្វែងរកពន្លឺត្រាស់ដឹង។

បើកាលណា គេមិនអាចរក្សាការពារវិញ្ញាណទាំងប្រាំរបស់គេ ពោលគឺភ្នែក ត្រចៀក ច្រមុះ អណ្តាត និងរូបកាយបានទេនុ៎ះ គេមិនអាចព្យាយាមដើម្បីសម្រេចពន្លឺត្រាស់ដឹងបានទេ។ បុគ្គលណាដែលចេះរក្សាការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំ ហើយចេះគ្រប់គ្រងចិត្ត បុគ្គលនោះអាចព្យាយាមប្រកបដោយជោគជ័យដើម្បីសម្រេចពន្លឺត្រាស់ដឹង។

7. បើកាលណាគេលុះក្នុងអំណាចនៃការចូលចិត្ត និងការមិនចូលចិត្ត គេមិនអាចយល់ឲ្យបានត្រឹមត្រូវអំពីន័យនៃទេស-កាលទេ ហើយដោយហេតុនេះ គេតែងតែខំដណ្តើមយកឈ្នះចាញ់។ បើកាលណាគេចាកផុតពីការជំពាក់ចិត្ត គេនឹងយល់យ៉ាងត្រឹមត្រូវអំពីទេសកាល ហើយអាស្រ័យហេតុនេះគេនឹងឃើញថាវត្ថុទាំងអស់តែងតែប្រែប្រួល។

សុភមង្គលតាមក្រោយទុក្ខព្រួយ ទុក្ខព្រួយតាមក្រោយសុភមង្គល។ ប៉ុន្តែបើកាលណាគេមិនធ្វើការរើកញែករវាងសុភមង្គលនឹងទុក្ខព្រួយ រវាងល្អនឹងអាក្រក់ នុ៎ះគេអាចបានស្គាល់នូវសុខសិរីពិតប្រាកដ។

ព្រួយបារម្ភនឹងអនាគត ហើយស្តាយស្រណោះនឹងអតីត ប្រដូចបានទៅនឹងដើមបបុសដែលគេកាត់ហាលស្ងួត។

សេចក្តីជាអាថ៌ដើម្បីសុខសួស្តីនៃរូបកាយនិងវិញ្ញាណ គឺ មិនសោកស្រណោះនឹងអតីត មិនព្រួយបារម្ភនឹងអនាគត មិន រីករវនឹងរឿងដែលនឹងត្រូវមកដល់ ផ្ទុយទៅវិញគឺចេះរស់នៅ ក្នុងភាពបច្ចុប្បន្នប្រកបដោយគតិបណ្ឌិត ក្នុងភាពជាធម្មតា។

ចូរកុំគិតទាក់ទាមនឹងអតីត ចូរកុំរង់ចាំអនាគត កិច្ចតែ មួយគត់គឺ ត្រូវចេះរស់នៅប្រកបដោយចិត្តនឹងនក្នុងបច្ចុប្ប-កាលនេះ។

ការបំពេញកិច្ចបច្ចុប្បន្នឲ្យបានល្អ ជាការប្រសើរមួយៈ ចូរកុំនឹកខំចៀសវាងកិច្ចបច្ចុប្បន្នប្តុទុកវាទៅថ្ងៃស្អែក។ បើអ្នក បំពេញកិច្ចបច្ចុប្បន្នឲ្យបានសមរម្យល្អបាន គឺអ្នករស់នៅដោយ សប្បាយរីករាយបានមួយថ្ងៃ។

គ្មានអ្នកបំភ្លឺផ្លូវណាប្រសើរជាងគតិធម៌ទេ គ្មានមិត្តណា ប្រសើរជាងជំនឿជ្រះថ្លាទេ។ បុគ្គលទាំងឡាយតោងតែខំរត់ គេចចេញពីអន្ធភាពនៃសេចក្តីល្ងង់ខ្លៅនិងទុក្ខព្រួយ ហើយខំ ស្វែងរកពន្លឺត្រាស់ដឹង។

កាលណាគេគ្រប់គ្រងកាយ និងចិត្តរបស់គេបាន នេះជាសញ្ញានៃអំពើប្រកបដោយគុណធម៌ នេះជាករណីយកិច្ចខ្ពង់ខ្ពស់បំផុត។ ពេលនោះ ជំនឿជ្រះថ្លានឹងបានជាសម្បត្តិ សេចក្ដីស្មោះត្រង់នឹងផ្ដល់រសជាតិផ្អែមត្រជាក់ដល់ជីវិត ហើយការប្រមូលសន្សំកុសលបុណ្យនេះនឹងបានជាករណីយកិច្ចមួយប្រសើរបំផុត។

ក្នុងដំណើរនៃជីវិត ជំនឿជ្រះថ្លាជាចំណីអាហារ គុណធម៌ជាទីជម្រក គតិធម៌ជាពន្លឺនៅពេលថ្ងៃ ការចេះប្រុងប្រយ័ត្នដ៏ត្រឹមត្រូវជាសម្ភារៈការពារនៅពេលយប់។ បុគ្គលណាចេះរស់នៅក្នុងជីវិតស្អាតបរិសុទ្ធ គ្មានអ្វីអាចមកបំផ្លាញគេបានទេ។ បុគ្គលណាបានឈ្នះសេចក្ដីលោភលន់ គ្មានអ្វីអាចកំណត់ព្រំដែននៃសេរីភាពរបស់គេបានទេ។

គេតោងតែបំភ្លេចខ្លួនគេ ដើម្បីសេចក្ដីស្នេហាដល់គ្រួសារគេ។ គេតោងតែបំភ្លេចគ្រួសារគេ ដើម្បីសេចក្ដីស្នេហាដល់ភូមិស្រុកគេ។ គេតោងតែបំភ្លេចភូមិស្រុកគេ ដើម្បីសេចក្ដីស្នេហាដល់ប្រទេសជាតិគេ។ ទីបំផុត គេតោងតែបំភ្លេចអ្វីៗទាំងអស់ ដើម្បីសេចក្ដីស្នេហាពន្លឺត្រាស់ដឹង។

អ្វីៗទាំងអស់សុទ្ធតែប្រែប្រួល អ្វីៗទាំងអស់កើតឡើងហើយ

វិនាសទៅវិញជាធម្មតា គ្មានសេចក្តីសុខស្ងប់ទេ ដរាបណាគេមិនបានរួចផុតពីដំណើរប្រែប្រួល នៃការរស់ និងការស្លាប់នេះ។